01675445

F1/10.1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Court Suprême

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីសវនាការបណ្ដឹងសាទុក្ខ

## ក្នុងសំណុំរឿង ០០២/០២

## សាធារណៈ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អជតក

**ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២១**

**ម៉ោង ០៨:៥៩នាទី**

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 25-Aug-2021, 10:38
CMS/CFO: Sann Rada

**ចៅក្រមជំនុំជម្រះ៖**

ចៅក្រម គង់ ស្រ៊ីម ជាប្រធាន

ចៅក្រម យ៉ា ណារិន

ចៅក្រម ម៉ូរីន ហាឌីង ក្លាក
*(Judge Maureen Harding CLARK)*

ចៅក្រម សោម សិរីវឌ្ឍ

ចៅក្រម ចាន់ដ្រា នីហាល ចាយ៉ាស៊ីញហេ
*(Judge Chandra Nilhal JAYASINGHE)*

ចៅក្រម ម៉ុង មន្នីចរិយា

ចៅក្រម ផ្លរិនស៍ ដេផេល វ៉ែរឈិន-ម៉ុមបា
*(Judge Florence N. MWACHANDE-MUMBA)*

**ក្រឡាបញ្ជី៖**

លោក ស៊ា ម៉ៅ

កញ្ញា ភីស ម៉ាល្លេនី *(Ms. Peace Malleni)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោកស្រី ប្រេនដា ហូលិស
*(Ms Brenda J. HOLLIS)*

លោក ស្រ៊ា រតនៈ

លោក សេង ប៊ុនឃាង

លោកស្រី នីសា ប៉ាតែល *(Ms Nisha Patel)*

លោកស្រី ហេឡេន វើសនុប *(Ms Helen Worsnop)*

លោកស្រី រូថ ម៉ារី ហេគ្ល័រ
*(Ms Ruth Mary Hackler)*

លោក វីល្លៀម ស្មីត *(Mr.William Smith)*

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr.Vincent de wilde d'Estmael)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី មេហ្គិន ហ៊ឺសត៍ *(Ms. Megan Hirst)*

លោកស្រី ទី ស្រ៊ីនណា

**មេធាវីការពារក្តីលោក ខៀវ សំផន**

លោក គង់ សំអុន

លោកស្រី អង់តា ហ្គីសសេ *(Ms. Anta GUISSE )*

**ជនជាប់ចោទ៖**

លោក ខៀវ សំផន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោកស្រី ស្វ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម គង់ ស្រ៊ឹម (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ម៉ូរីន ហាឌីង ក្លាក | អង់គ្លេស |
| ចៅក្រម យ៉ា ណារិន | ខ្មែរ |
| ចៅក្រម ម៉ុង មុន្នីចរិយា | ខ្មែរ |
| លោកស្រី ហេឡេន វើសនុប | អង់គ្លេស |
| លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោកស្រី រូថ ម៉ារី ហេកគ័រ | អង់គ្លេស |
| លោកស្រី នីសា ប៉ាតែល | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី មេហ្គិន ហ៊ីសត៍ | អង់គ្លេស |
| លោកស្រី អង់តា ហ្គីសសេ | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| ក្រឡាបញ្ជី | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

[០៨:៥៨:៤០]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

ថ្ងៃនេះជាថ្ងៃទី២ អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សូមប្រកាសបន្តសវនាការ ហើយសវនាការថ្ងៃនេះគឺបន្តដោយពីម្សិលមិញគឺយើងបានធ្វើសារណាទាក់ទងនឹងទឡ្ហីករណ៍បណ្តឹងសាទុក្ខពាក់ព័ន្ធនឹងយុត្តាធិការបស់អង្គជំនុំជម្រះសាលាដំបូង។

លោកក្រឡាបញ្ជី សូមរាយការណ៍អំពីវត្តមាន។

**ក្រឡាបញ្ជី៖**

បាទ សូមគោរពឯកឧត្តមប្រធាន និងសូមគោរពដល់ក្រុមប្រឹក្សាជំនុំជម្រះ។ ថ្ងៃនេះ វត្តមានរបស់ភាគីមានគ្រប់ចំនួន។ ទី១ គឺមានវត្តមានរបស់សហព្រះរាជអាជ្ញា លោកជំទាវ ជា លាង លោកស្រី ហេឡេន វើសនុប ហើយខាងសហមេធាវីជនជាប់ចោទលោក ខៀវ សំផន គឺមានលោកមេធាវី គង់ សំអុន លោកស្រីមេធាវី អង់តា ហ្គីសសេ និងជនជាប់ចោទ មានវត្តមានដោយផ្ទាល់ គឺលោក ខៀវ សំផន។ រីឯខាងសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី មានលោកមេធាវី ពេជ អង្គ លោកស្រីមេធាវី លោកស្រីមេហ្កិន ហ៊ីសត៍ និងមានដើមបណ្តឹងរដ្ឋប្បវេណីចំនួនប្រាំរូបបន្ថែមទៀតសម្រាប់ថ្ងៃនេះ គឺមានអ្នកស្រី មាស សារុំ, អ្នកស្រី ហង់ ហឿន, អ្នកស្រី ឱក ថាលី, លោក ស៊ុំ រិទ្ធី និងអ្នកស្រី យឹម សុវណ្ណ។

បាទ សូមអរគុណឯកឧត្តមប្រធាន។

[០៩:០១:៣៨]

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងជាបន្ត ថ្ងៃនេះយើងបន្តប្រធានបទទាក់ទងនឹងទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខពាក់ព័ន្ធទៅនឹងយុត្តាធិការបស់អង្គជំនុំជម្រះសាលាដំបូង។ ហើយកាលពីល្ងាចម្សិលមិញ គឺយើងបានធ្វើសារណា ស្តាប់ការធ្វើសារណារបស់សហព្រះរាជអាជ្ញារួចហើយ។ ដូច្នេះព្រឹកនេះ គឺសូមអញ្ជើញសហមេធាវីនាំមុខ

តំណាងដើមបណ្ដឹងរដ្ឋប្បវេណីធ្វើសារណា។ សូមអញ្ជើញ!

**លោកស្រី មេហ្គិន ហ៊ីសត៍៖**

សូមគោរពឯកឧត្តមប្រធាន លោក លោកស្រីចៅក្រម អស់លោក លោកស្រីទាំងអស់ជាភាគី។ ខ្ញុំមានកាតព្វកិច្ចត្រូវតែលើកឡើងពីបញ្ហាមួយចំនួនទាក់ទងទៅនឹងអ្វី ដែលមេធាវីបានលើកឡើងកាលពីម្សិលមិញ។ ដើមបណ្ដឹងរដ្ឋប្បវេណីមិនមានគោលជំហរណាមួយទាក់ទងទៅនឹងវិសាលភាពនេះទេ ប៉ុន្តែយើងមានហេតុផលមួយចំនួន។ ទី១ ខ្ញុំគិតថាវាពិបាកនៅក្នុងការស្វែងយល់ ថាតើមានទំនាក់ទំនងយ៉ាងម៉េចរវាងផលប្រយោជន៍ដើមបណ្ដឹងជាមួយនឹងវិសាលភាពនៃសំណុំរឿង។ ទី១ វិសាលភាព ទោះបីថាយើងនៅក្នុងវិសាលភាព ឬក៏អត់ក៏ដោយ អានេះគឺវា -- វាគឺ -- គឺវាជាអ្នកសម្រេចឧក្រិដ្ឋកម្មដែលពួកគាត់ទទួលរងហើយវាជាឆន្ទានុសិទ្ធិរបស់តុលាការ។ ទោះបីថាអាចមានលទ្ធភាពនៃការជឿជាក់ចំពោះឧក្រិដ្ឋកម្មបានប្រព្រឹត្តហើយក៏ដោយ។ នៅពេលដែលយើងនិយាយអំពីវិសាលភាពនេះ គឺថា ដើមបណ្ដឹងរដ្ឋប្បវេណីជាទូទៅតែងតែចាញ់។ ទឡ្ហីករណ៍ដែលយើងនឹងនិយាយនៅថ្ងៃនេះ គឺពាក់ព័ន្ធទៅនឹងផលប្រយោជន៍ជារួម ជាទ្រង់ទ្រាយធំរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដូចដែលខ្ញុំបាននិយាយកាលពីម្សិលមិញរួចមកហើយ។ អ្វីដែលខ្ញុំភ្ញាក់ផ្អើលទី២ទៀតនោះ កាលពីម្សិលមិញ គឺមេធាវីការពារក្ដីបានលើកឡើងនូវគោលជំហរថ្មីមួយទៀត គាត់និយាយថា ដើមបណ្ដឹងរដ្ឋប្បវេណីមានប្រយោជន៍ពិសេស គឺមិនមែនផលប្រយោជន៍ជាទូទៅទេ ប្រយោជន៍ជាពិសេសតែម្ដង។ ខ្ញុំមិនដឹងថាតើគាត់លើកពីអ្វីនោះទេ ហើយខ្ញុំក៏មិនដឹងថាតើភាពខុសគ្នាហ្នឹងវាយ៉ាងម៉េចនោះទេ។ គឺនៅក្នុងឯកសារ F10/2 របស់លោក លោកស្រីចៅក្រមហ្នឹង គឺមានការសម្រេច ប៉ុន្តែមិនមែនជាអ្វីដែលលោក លោកស្រីចៅក្រមបាននិយាយ បានសម្រេចនៅក្នុងកថាខណ្ឌ៨១ នៃសាលដីកាសំណុំរឿង០២/១ នោះឡើយ។ អ្វីដែលលើកឡើងនៅក្នុងកថាខណ្ឌនោះ គឺជារឿងផ្សេងមួយទាំងស្រុង។ គឺបាននិយាយថាការដាក់របស់ដើមបណ្ដឹងរដ្ឋប្បវេណី គឺថា គ្រាន់តែជាការថ្លឹងថ្លែងទៅលើដើមបណ្ដឹងរដ្ឋប្បវេណីតែប៉ុណ្ណោះ គឺជាការផ្ដល់នូវយុត្តិកម្មសម្រាប់ការសម្រេច។

[០៩:០៥:១៧]

ទី៣ ដែលខ្ញុំភ្ញាក់ផ្អើលផងដែរនោះ គឺយើងបានឮមេធាវីការពារក្ដីនិយាយថា គឺមានការផ្លាស់ប្ដូរទៅលើជំហររបស់យើងទៅវិញ។ នេះគឺជារឿងបត់បែនមួយដ៏លំបាក ព្រោះដើមបណ្ដឹងរដ្ឋប្បវេណី មានប្រវត្តិយ៉ាងយូរអង្វែងជាមួយតុលាការនេះរួចទៅហើយ ហើយយើងបានលើកឡើងអំពីវិសាលភាពហ្នឹង

រួមទាំងបញ្ហាដូចជាការរំលោភ ក្រៅការរៀបការដោយបង្ខំ ហើយនិងបទចោទផ្សេងៗទៀត។ នៅក្នុង F60/1/1 ជើងទំព័រលេខ១០ យើងបានដាក់នូវសារណាមួយដែលយើងបាននិយាយអំពីវិសាលភាព ហើយខ្ញុំក៏មានការដកស្រង់នៅក្នុងសារណាបញ្ចប់ការពិភាក្សាដេញដោលរបស់យើងផងដែរ។ គឺនិយាយអំពីបញ្ហាមួយចំនួន គឺមិនមានការផ្លាស់ប្តូរគោលជំហរនោះឡើយ។ ដូច្នេះ បញ្ហាប្រឈម គឺថាយើងបានលើកអំពីសារណា នៅក្នុងសារណា F60/1/1 នៅក្នុងកថាខណ្ឌមួយចំនួន។

[០៩:០៦:៤៦]

ចំពោះវិសាលភាពនៃរឿងក្តីគោលជំហររបស់យើងគឺនៅដដែល គឺថាទឡ្ហីករណ៍ជាច្រើនរបស់មេធាវីការពារក្តីគឺលើកឡើងហួសពេលទៅហើយ។ គឺថាលើកនៅរាប់សិបឆ្នាំ -- រាប់ឆ្នាំ ក្រោយពេលដែលមេធាវីការពារក្តីបានដឹងពីរឿងនេះទៅឡើយ គឺរាប់ឆ្នាំ តាំងពីមានការសម្រេច។

ខ្ញុំនឹងចាប់ផ្តើមឆ្លើយទៅនឹងទឡ្ហីករណ៍មួយចំនួន ដែលលើកឡើងដោយមេធាវីការពារក្តីកាលពីម្សិលមិញ។ ទី១ គឺលោក លោកស្រីចៅក្រម បានសួរថា ហេតុអីបានជាមេធាវីការពារក្តីមិនលើកបញ្ហាហ្នឹងនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត? កាលពីម្សិលមិញ មេធាវីការពារក្តីទទួលស្គាល់ថា គេមិនបានលើកនូវបញ្ហានេះនៅក្នុងដំណាក់កាលបុរេជំនុំជម្រះ ហើយពួកគេនិយាយថា ហេតុអីបានគេមិនប្តឹងទៅដីកាដំណោះស្រាយ។ ប៉ុន្តែអ្វីដែលគេមិនបានពន្យល់នោះ គឺថា ហេតុអ្វីបានបញ្ហាហ្នឹងមិនបានលើកនៅមុនពេលដែលមានដីកាដំណោះស្រាយទៅវិញ គឺហាក់ដូចជាមិនមានបញ្ហាផ្លូវច្បាប់ ដែលថាគេអាចលើកនៅក្នុងសំណើធម្មតា តាមរយៈវិធាន៧៦(២) នៃវិធានផ្ទៃក្នុង។ ហើយខ្ញុំចង់ចំណាយពេលតិចតួចដើម្បីគូសបញ្ជាក់ថាតើ មេធាវីការពារក្តី ខៀវ សំផន មានឱកាសច្រើនប៉ុនណា ដើម្បីដោះស្រាយទៅលើបញ្ហានុ៎ង នៅមុនពេលដែលមានចេញដីកាដំណោះស្រាយ ប៉ុន្តែពួកគេមិនធ្វើ។

ឥឡូវនេះ ខ្ញុំលើកយកពីបញ្ហាមួយចំនួន។ មូលដ្ឋាន ៥៣ និង៥៤ បានលើកឡើងអំពីបញ្ហាទាំងអស់នោះ ហើយនៅក្នុងមូលដ្ឋានទាំងអស់នោះ មេធាវីការពារក្តីបាននិយាយថា ដីកាបញ្ជូនរឿងឲ្យស៊ើបសួរមិនបានលើកអំពីបញ្ហាទាំងអស់នោះទេ។ មិនបាននិយាយអំពីការធ្វើទារុណកម្ម ឬក៏ការធ្វើបាបនោះឡើយ។ យើងគិតថា នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ គឺលើកឡើងអំពីបញ្ហានេះ។ ប៉ុន្តែមេធាវីការពារក្តីគួរតែលើកអំពីបញ្ហាទាំងអស់នេះកាលពីប៉ុន្មានឆ្នាំមុនមកម្ល៉េះ។ គឺថាពួកគេអាចដឹងច្បាស់តាំងពីឆ្នាំ២០០៨ ដែលថាបញ្ហាទាំងអស់នោះ នឹងត្រូវបញ្ចូលទៅក្នុងវិសាលភាពនៃសំណុំរឿង។ ឯកសារបានជូន -- ដែលបានជូនដំណឹងទៅដល់ភាគីនៅក្នុងការស៊ើបអង្កេត គឺមានឯកសារ E3/8350

គឺរបាយការណ៍ស្ដីពីការចាត់ឲ្យស៊ើបសួរជំនួសនៅក្នុងឆ្នាំ ដែលបានដាក់នៅក្នុងឆ្នាំ២០០៨ បានរៀបរាប់អំពីសាក្សីជាច្រើននៅក្រាំងតាចាន់ ការឃុំខ្លួន ការសួរចម្លើយ និងការសម្លាប់។ រៀបរាប់អំពីភស្តុតាងសាក្សីម្ដងហើយម្ដងទៀតដែលនិយាយអំពីការធ្វើទារុណកម្ម ការបង្អត់អាហារ ជំងឺ ហើយនិងការសម្លាប់។ បន្ថែមពីលើនេះ ដីកាចាត់ឲ្យស៊ើបសួរជំនួស E38356 ដែលដាក់ប្រហែលជានៅថ្ងៃ៣ ខែមីនា ឆ្នាំ២០០៨ ហ្នឹងក៏បាននិយាយពីក្រាំងតាចាន់ដែរ គឺនិយាយអំពីសាក្សីបួនរូប ភាគច្រើនពួកគេនិយាយអំពីការសួរចម្លើយនៅនៃក្រាំងតាចាន់។ ហើយមាននិយាយពីការធ្វើទារុណកម្មនៅក្រាំងតាចាន់ ខ្វះអនាម័យ មិនមានអាហារ ការដាក់ខ្នោះឃ្នាង ជំងឺ និងការអត់អាហារ។ ពួកគេនិយាយអំពីការប្រព្រឹត្តដែលគេ ពួកគេហៅថាការធ្វើទារុណកម្ម មានតែការវ៉ៃនៅពេលសួរចម្លើយ ការវ៉ៃដោយដំបង និងរំពាត់ផ្ដៅជាដើម។

[០៩:១០:៥៨]

បន្ថែមពីលើរបាយការណ៍ស្ដីពីការស៊ើបសួរជំនួសហ្នឹង គឺមានកំណត់ហេតុស្ដាប់ចម្លើយសាក្សីដែលបាននិយាយផងដែរ ដូចនៅក្នុងរបាយការណ៍ស្ដីពីការចាប់ឲ្យស៊ើបសួរជំនួសផងដែរ គឺក្នុងនោះមានប្រាំបួននាក់យ៉ាងតិច ដែលបាននិយាយអំពីការធ្វើទារុណកម្ម ការសួរចម្លើយ និងស្ថានភាពគុក។ ក្រៅពីនេះគឺរបាយការណ៍ E35828 ដែលបានដាក់នៅខែកញ្ញា ឆ្នាំ២០០៩ ក៏បានលើកឡើងអំពីការធ្វើទារុណកម្ម ការសួរចម្លើយ ជំងឺ និងការអត់អាហារ។

ដូច្នេះគឺថាវាច្បាស់ណាស់ដែរថា តាំងពី ២០០៨ និង ២០០៩ ម្ល៉េះ ដែលពួកគាត់ មេធាវីការពារក្ដីបានទទួលរបាយការណ៍ទាំងអស់នោះ ហើយគាត់ដឹងថាសហចៅក្រមស៊ើបអង្កេតបានស៊ើបសួរអំពីការធ្វើទារុណកម្ម និងការធ្វើបាបនៅក្រាំងតាចាន់។ ដូច្នេះហើយគឺថាវាមិន -- មេធាវីការពារក្ដីជឿជាក់ហើយថា ពេលនុំងថាប្រាកដជាហួសវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងស៊ើបសួរ ប៉ុន្ដែពួកគាត់អាចនឹងដាក់សំណើសុំមោឃភាព តាមវិធាន ៧៦(២)។

អ្វីដែលនៅសេសសល់ទាក់ទងទៅនឹងវិសាលភាពផងនោះ គឺអាចនឹងជួសជុលបានដោយដីកាដំណោះស្រាយ គឺមានការលើកឡើងអំពីស្ថានភាពនៃការឃុំឃាំងការដាក់ទារុណកម្ម នៅក្នុងកថាខណ្ឌ ៥០១ ៥០២ ៥០៦ ៥០៩។ អាហ្នឹងហើយ អ្វីៗហ្នឹងត្រឡប់ទៅអ្វីដែលខ្ញុំនិយាយទាក់ទងទៅនឹងកាលពីម្សិលមិញ ថាហេតុអ្វីបានជាមេធាវីការពារក្ដីមិនជំទាស់ទៅនឹងដីកាដំណោះស្រាយ។ គឺថាមេធាវីការពារក្ដីអាចប្ដឹងទៅតាមវិធាន៧៤(៣) ទៅលើដីកាដំណោះស្រាយ។ ប៉ុន្ដែបន្ថែមពីលើហ្នឹង ក្រៅពីការប្ដឹងជំទាស់ ប្ដឹងឧទ្ធរណ៍ទៅលើដីកាដំណោះស្រាយហ្នឹងគឺនៅថ្ងៃដែលហ្នឹង គឺនៅថ្ងៃ១៨ ខែ៩ ២០១០

ហ្នឹងគឺមេធាវីការពារក្តីបានដាក់នូវរបាយ -- បណ្តឹងមួយ ប៉ុន្តែគួរឲ្យសោកស្តាយណាស់ គឺឯកសារនេះអត់មាននៅក្នុង *ហ្សាយឡេប* ទេ ហើយខ្ញុំបានទាក់ទងជាមួយខាងពាក់ព័ន្ធ ថាតើរកយ៉ាងណាដើម្បីឲ្យឃើញនៅក្នុង *ហ្សាយឡេប* ប៉ុន្តែអាចរកឃើញបែបនៅតាមអនឡាញ ឬក៏យ៉ាងម៉េច គឺគេហៅថា ដីកាសម្រេចទៅលើបណ្តឹងឧទ្ធរណ៍បន្ទាន់របស់មេធាវី ខៀវ សំផន គឺនៅថ្ងៃ១២ ខែមករា ២០១១។

[០៩:១៣:៥៤]

ក្រៅពីនេះ គឺមេធាវីការពារក្តី ខៀវ សំផន បានលើកឡើងពីបញ្ហាច្រើន ហើយបណ្តឹងនោះគឺស្របទៅតាមវិធាន៧៤(៣)។ ខ្ញុំអត់បានឮការពន្យល់ពីមេធាវីការពារក្តីហេតុអីបានជាមិនមានការពន្យល់បែបនេះទេ។ ប៉ុន្តែឥឡូវនេះយើងអាចនឹងសួរទាក់ទងទៅនឹងបញ្ហាវិធាន៧៤(៣)។ គោលជំហររបស់មេធាវីការពារក្តីគឺហាក់ដូចជាចង់និយាយថា នៅឆ្នាំ២០១០ មេធាវីការពារក្តីបានមើលទៅលើវិធានផ្ទៃក្នុង ហើយដូចជាសម្រេចថាមិនអាចប្តឹងឧទ្ធរណ៍ទៅលើដីកាដំណោះស្រាយទៅវិញ។ ដូច្នេះ គឺថានៅពេលដែលយើងស្តាប់មេធាវីការពារក្តីកាលពីម្សិលមិញ ខ្ញុំឃើញថា វិធាន៧៦(៣) គឺបានហាមឃាត់ច្បាស់មិនឲ្យមេធាវីការពារក្តីប្តឹងដីកាដំណោះស្រាយទាក់ទងទៅលើរឿងបណ្តឹង។ ប៉ុន្តែអត់មានទេ វិធានហ្នឹងអត់មានចែងអ៊ីចឹងទេ។ វិធាន៧៤(៣)(ក) បាននិយាយថា មេធាវីការពារក្តីអាចប្តឹងទៅលើបញ្ហាយុត្តាធិការ បញ្ហាដូចដែលខ្ញុំបញ្ជាក់អ៊ីចឹង គឺបញ្ហាអត្ថន័យនៃពាក្យយុត្តាធិការ។

យើងមានការពិភាក្សានៅថ្ងៃនេះ ដែលថាយើងនឹងដែកលើបញ្ហាយុត្តាធិការនៅថ្ងៃនេះផងដែរ។ មេធាវីការពារក្តីកាលពីម្សិលមិញបាននិយាយថា ការជំទាស់របស់ពួកគេគឺនិយាយអំពីបញ្ហាយុត្តាធិការដាច់ខាត គឺនៅក្នុងកថាខណ្ឌ៣១ នៃបណ្តឹងសាទុក្ខ។ ដូច្នេះវិធាន៧៤(៣)(ក) គឺគ្រាន់តែជាការបកស្រាយថាតើយុត្តាធិការហ្នឹងមានន័យថាយ៉ាងដូចម្តេចតែប៉ុណ្ណោះ។ ប្រាកដណាស់ថាអង្គ -- យុត្តិសាស្ត្រអង្គបុរេជំនុំជម្រះគឺវាអាចមានបញ្ហាបន្តិចបន្តួច ហើយមេធាវីការពារក្តីក៏បាននិយាយអំពីវិធាន៧៤(៣)(ក) ដែលអាចជំទាស់ទៅលើយុត្តាធិការពេលវេលា យុត្តាធិការសំណុំរឿង និងយុត្តាធិការទីតាំងរបស់តុលាការ។

[០៩:១៦:៤៥]

ក្រៅពីនេះទៀតគឺមានបណ្តឹងទៅលើ -- ក្រៅពីនេះ យើងដឹងដែរថា សាលាអង្គបុរេជំនុំជម្រះគឺមានសិទ្ធិក្នុងការសម្រេចក្រៅពីវិធាន៧៤(៣) ដើម្បីរាំងការរំលោភបំពានទៅលើសិទ្ធិទៅរកការជំនុំជម្រះប្រកបដោយយុត្តិធម៌។ នេះគឺជាអ្វីដែលបានប្រើប្រាស់ដើម្បីស្តាប់ទៅលើការជំទាស់ការស៊ើបអង្កេតដែលហួសពីការចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ គឺឯកសារ D97 -- 9771455។

ក្រៅពីនេះទៀតគឺមានគោលជំហរច្រើនរបស់អង្គបុរេ ដែលថាអង្គបុរេមានសិទ្ធិក្នុងការពិនិត្យទៅលើនីតិវិធីដែលបានធ្វើនៅដំណាក់កាលស៊ើបអង្កេត។

នៅកថាខណ្ឌ១៣៤ គឺបានដកស្រង់នៅកថាខណ្ឌមួយនៃសេចក្តីពិចារណារបស់អង្គបុរេ គឺនៅក្នុងសំណុំរឿង០០៣។ ចៅក្រមអន្តរជាតិបានបញ្ជាក់ច្បាស់នៅក្នុងឯកសារ D66/27 នៃសំណុំរឿង០០៣ នៅកថាខណ្ឌ១២៣ ដល់ ១២៩ និង ២៦៧ ២៦៨ នៅក្នុងឯកសារទាំងនោះគឺនិយាយអំពីវិការៈនីតិវិធីនៃការស៊ើបអង្កេត គឺមិនអនុញ្ញាតឲ្យមានឡើយ គឺសាលាដំបូងមិនអាចសម្រេចអំពីវិការៈនីតិវិធីបានឡើយ សូម្បីតុលាការកំពូលក៏មិនអាចសម្រេចបានដែរ។

[០៩:១៨:៤៤]

ដូច្នេះ ឥឡូវនេះ យើងនឹងជជែកនៅក្នុងវិធាន៧៦(៧) គឺថាបណ្តឹងដីកាដំណោះស្រាយ គឺអាចនឹងកែជួសជុលនូវវិការៈនានា ដើម្បីនៅក្នុងការស៊ើបអង្កេត។ គឺមិនមានការលើកអំពីបញ្ហាទាំងអស់នេះនៅសាលាដំបូង ឬតុលាការកំពូលនោះឡើយ។

ទាក់ទងទៅនឹងយុត្តា -- យុត្តិសាស្ត្ររបស់សាលាអង្គបុរេ គឺថាមេធាវីការពារក្តីព្យាយាមលើកបញ្ហាអំពីបណ្តឹងនៅក្នុងបណ្តឹងសាទុក្ខរបស់ពួកគេ ប៉ុន្តែយើងមិនបានរកឃើញថាអង្គបុរេបានបកស្រាយយ៉ាងណាទៅលើ -- គឺថាអង្គបុរេមិនបានបកស្រាយឲ្យបានច្បាស់លាស់ទៅវិធាន៧៤(ក) នោះឡើយនៃវិធានផ្ទៃក្នុង។ យើងតែងតែឆ្ងល់ថា ហេតុអីមេធាវីការពារក្តីមិនលើកបញ្ហាបែបនេះមក ទៅលើវិធាន ៧៤(៣)(ក) នោះ។

[០៩:២០:០៦]

ហេតុអីបានជាគេដឹងថាមេធាវីការពារក្តី -- សុំទោស ហេតុអីបានគេដឹងថាអង្គបុរេមិនសម្រេចជ្រើសរើសវិធានបែបនេះ? វិធានផ្ទៃក្នុងគឺចាំបាច់ត្រូវបកស្រាយ ដើម្បីឲ្យវិធានទាំងអស់នោះវាស្របជាមួយគ្នា ដូច្នេះហើយដើម្បីឲ្យវិធានហ្នឹងអាចបកស្រាយជាមួយគ្នាបាន។ វិធាន៧៦(៧) បាននិយាយថា ក្រោយពេលដែលមានបញ្ហានៅក្នុងដីកាដំណោះស្រាយ គឺអាចមានការជួបវិការៈនៅ -- បន្ថែមពីលើនេះទៅទៀត គឺច្បាប់ណាស់ថា នីតិវិធីដែលមិនបានដោះស្រាយនៅអង្គបុរេ គឺមិនអាចធ្វើឡើងឲ្យហួសពីវិសាលភាពនៃអង្គជំនុំជម្រះបានឡើយ។ វិធីសាស្ត្រដ៏ត្រឹមត្រូវ គឺការបកស្រាយដែលនិយាយអំពីរចនាសម្ព័ន្ធ ក៏ដូចជាក្របខ័ណ្ឌនៃតុលាការ ហើយពួកគេត្រូវតែលើកឡើងអំពីចំណុចនេះ។ ចំណុចទី១ គឺថាក្របខ័ណ្ឌនីតិវិធីគឺនិយាយអំពីភាពច្បាស់លាស់ និងភាពត្រឹមត្រូវនៅអង្គ -- នៅដំណាក់កាលបុរេជំនុំជម្រះ។

ទី២ គឺអង្គបុរេជំនុំជម្រះគឺជាអង្គបុរេ -- គឺជាអង្គជំនុំជម្រះមួយដែលជាអ្នកគ្រប់គ្រងត្រួតពិនិត្យមើលទៅលើដំណាក់កាលស៊ើបអង្កេត។ ប្រសិនបើមានបញ្ហាថាតើចៅក្រមស៊ើបគោរពទៅតាមនីតិវិធីត្រឹមត្រូវ ឬក៏មិនត្រឹមត្រូវនោះទេ គឺថាបញ្ហាហ្នឹងគឺត្រូវសម្រេចនៅដំណាក់កាលមុនជំនុំជម្រះ។ ហេតុអីបានទុកទៅដល់ក្រោយជំនុំជម្រះ ទុកទៅដល់ដំណាក់កាលក្រោយទៅវិញ។ ហេតុអីបានជាយុត្តិសាស្ត្រនៅពេលដែលប្រើប្រាស់នូវវិធាន៧៦(៣)(ក) បែរជាមិនគ្របដណ្ដប់ទៅលើបញ្ហាយុត្តាធិការដែលកើតឡើងក្នុងពេលស៊ើបអង្កេតទៅវិញ។ ដូច្នេះហើយគឺថាបញ្ហានៃការជំនុំជម្រះគឺថាយើងព្យាយាមធ្វើយ៉ាងណាស្វែងរកសច្ចភាពសម្រាប់ការជំនុំជម្រះបានល្អ។ ដូច្នេះយើងជឿជាក់ថាអ្វីដែលកើតឡើងហ្នឹងគឺអាចធ្វើទៅបាន។ ទោះជាក្នុងករណីណាក៏ដោយ ទោះបីជាយើងនិយាយបែបនេះមិនត្រឹមត្រូវក៏ដោយ អ្វីដែលសាលា -- អង្គបុរេបានសម្រេចនៅក្នុងសេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងដំណោះស្រាយ វាត្រូវតែបានជួសជុលនូវវិការៈទាំងអស់។ ហើយម្យ៉ាងទៀតបញ្ហាទាំងអស់នេះអាចលើកឡើងជាអញ្ញត្តិកម្មនៅអង្គជំនុំជម្រះសាលាដំបូង។ ហើយប្រសិនបើមេធាវីការពារក្ដីបាននិយាយថាមិនអាចលើកឡើងនៅដំណាក់កាលបុរេជំនុំជម្រះ មានន័យថាពួកគេអាចលើកឡើងជាអញ្ញត្តិកម្មបាន ហើយពួកគេគួរតែលើកនៅពេលនោះ។

[០៩:២៣:៤៥]

ចំណុចមួយផ្សេងទៀតគឺថាមេធាវីការពារក្ដីមិនបានធ្វើដូច្នេះទេ។ គេមិនបានលើកនៅ អង្គបុរេមិនបានលើកនៅដំណាក់ជំនុំជម្រះ។ ហើយប្រសិនបើខ្ញុំយល់សារណារបស់មេធាវីការពារ ខៀវ សំផន ច្បាស់លាស់ គឺថាគោលជំហររបស់ពួកគេគឺចង់និយាយថា នៅពេលដែលពួកគេដឹងថាវិសាលភាពនៃបណ្ដឹងឧទ្ធរណ៍ -- វិសាលភាពនៃការស៊ើបអង្កេតដែលបានប្ដឹងហ្នឹង គឺថាពួកគេអាចប្ដឹងនៅពេលដែលបញ្ចប់ការជំនុំជម្រះទៅវិញនោះ គឺបានន័យថាជំនុំជម្រះសិន ហើយបន្ទាប់មកទើបសម្រេចថាតើវិសាលភាពហ្នឹងមានអីខ្លះទៀត វាជារឿងពិបាកស្មានណាស់។ ប្រសិនបើគិតអ៊ីចឹងមែន វាមិនអាចទៅរួចទេដែលថា ជំនុំជម្រះហើយបានចាប់ផ្ដើមគិតថាវិសាលភាពអីដែលត្រូវគ្របដណ្ដប់ទៅវិញនោះ។

ដូច្នេះនៅក្នុងៗសាលដីការបស់តុលាការកំពូលនៅក្នុងកថាខណ្ឌ២៣៩ បាននិយាយពីចំណុចនេះដែរ។ ខ្ញុំមានចំណុចបន្ថែមមួយទៀតដែលខ្ញុំចង់ពិភាក្សាមុនពេលដែលខ្ញុំឆ្លើយតបបន្ថែមទៀតនោះ គឺថាខ្ញុំចង់សុំការអនុញ្ញាតពីឯកឧត្ដមប្រធាន លោក លោកស្រីចៅក្រមប្រហែលជាបួនប្រាំនាទីប៉ុណ្ណោះបន្ថែមទៀត។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទសូមអញ្ជើញបន្តទៅចុះ។

[០៩:២៥:៣៣]

**លោកស្រី មេហ្គិន ហ៊ឺសត៍៖**

សូមអរគុណឯកឧត្តមប្រធាន។

ចំណុចចុងក្រោយគឺនិយាយអំពីព្យសនកម្ម គឺយើងនិយាយអំពីព្យសនកម្មដែលកើតឡើង។ ឥឡូវនេះខ្ញុំលើយកឧទាហរណ៍មួយដែលខ្ញុំនិយាយអំពីមូលដ្ឋាន៣៩ គឺទាក់ទងទៅនឹងវិសាលភាពភូមិសាស្ត្រនៃបទចោទទាក់ទងទៅនឹងសហករណ៍ត្រាំកក់។ ទោះបីថាដីកាដំណោះស្រាយនិយាយច្រើនអំពីត្រាំកក់ក៏ដោយ ប៉ុន្តែកថាខណ្ឌ៣០២ បាននិយាយតែភូមិប្រាំបី ក្នុងចំណោម -- ឃុំប្រាំបី ក្នុងចំណោមឃុំ១៥ ស្រុកត្រាំកក់ ហើយនៅក្នុងកថាខណ្ឌ៤៣ នៃដីកាសន្និដ្ឋានបញ្ជូនរឿងស៊ើបសួរក៏បាននិយាយដែរ។ ឥឡូវមេធាវីការពារក្តីបាននិយាយថា ការចោទប្រកាន់ទាក់ទងទៅនឹងស្រុកត្រាំកក់ហ្នឹងគឺកម្រិតតែឃុំប្រាំបីហ្នឹងទៅវិញ។ ប៉ុន្តែមេធាវីការពារក្តីមិនបាននិយាយអំពីបញ្ហានេះទេ ទាំងនៅពេលដំណាក់កាលស៊ើបអង្កេត និងនៅពេលជំនុំជម្រះ។ ដូច្នេះឃើញថាមានភស្តុតាងជាច្រើនដែលយើងបានស្តាប់ឮនៅក្នុងផ្នែកនិយាយអំពីស្រុកត្រាំកក់ គឺនៅពេលនុ៎ង គឺគេនិយាយមិនមែនត្រឹមតែប្រាំបីឃុំហ្នឹងទេ និយាយហួសពីប្រាំបីឃុំហ្នឹងទៅទៀត។ ហើយសាលាដំបូងបានស្តាប់នូវភស្តុតាងជាច្រើនទាក់ទងទៅនឹងហេតុការណ៍ដែលកើតឡើងនៅឃុំលាយបូរ ឃុំជាងទង ឃុំពពេល ហើយឃុំទាំងពីរទាំងបីហ្នឹងគឺអត់មានចែងនៅក្នុងកថាខណ្ឌ៣០២ នៃដីកាដំណោះស្រាយទេ។

ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមលាង ដើមបណ្តឹងរដ្ឋប្បវេណី អ៊ំ សារឿន ទាំងពីរនាក់ហ្នឹងគាត់រស់នៅឃុំលាយបូរ ហើយគាត់បានផ្តល់សក្ខីកម្មអំពីបទពិសោធន៍។ គេនិយាយ ពួកគាត់លើកឡើងអំពីបទពិសោធន៍គាត់នៅឃុំហ្នឹងជាងបីថ្ងៃ។ នាង តួច ហៅ តាសាន ត្រូវបានគេបញ្ជូនទៅត្រាំកក់នៅឆ្នាំ៧៧ ហើយរស់នៅក្នុងឃុំលាយបូរ។ គាត់ផ្តល់ភស្តុតាងជាងបីថ្ងៃកន្លះ ហើយសាក្សី គង់ ហឿន ហៅយាយហឿន ហ្នឹងជាមេឃុំជាងទង ជាមេឃុំជាងទង។ គាត់ផ្តល់ភស្តុតាងអំពីឃុំជាងទង ហើយនិងឃុំពពេល ហើយគាត់ចំណាយពេលពីរថ្ងៃមកផ្តល់សក្ខីកម្ម។ សក្សី មាស សុខា ដែលរស់នៅក្នុងឃុំជាងទង គាត់ផ្តល់សក្ខីកម្មថាគាត់ជាអ្នកទោសនៅត្រាំតាចាន់។ ប៉ុន្តែក្រៅពីហ្នឹង គាត់ក៏បាននិយាយអំពីស្ថានភាពនៅជាងទងផងដែរ។ គាត់ផ្តល់សក្ខីកម្មជាងបីថ្ងៃ។

[០៩:២៨:១២]

ខ្ញុំអាចលើកឧទាហរណ៍បន្ថែមទៀតបាន ប៉ុន្តែសង្ឃឹមថាច្បាស់លាស់ហើយប៉ុណ្ណោះហ្នឹង។ ដូច្នេះ ខ្ញុំឃើញថាសាលាដំបូងបានស្តាប់ភស្តុតាងរាប់សិបថ្ងៃ ដែលនិយាយអំពីហេតុការណ៍នៅត្រាំកក់ ដែលកើតឡើងនៅក្រៅឃុំទាំងប្រាំបីដែលលើកឡើងហ្នឹង។ ជាពិសេសគឺបាននិយាយពីដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីដែលផ្អែកលើការដឹងឮ និងបទពិសោធន៍របស់ពួកគាត់នៅឃុំផ្សេងៗទៀតនៅស្រុកត្រាំកក់។ ហើយមេធាវីការពារក្តីនៅពេលនុំងអត់មាននិយាយអីមួយម៉ាត់សោះ។ បញ្ហាលំបាកគឺថាសាលាដំបូងមានពេលវេលាខ្លី ហើយសវនាការនីមួយៗគឺត្រូវតែមានពេលវេលាកំណត់។ ដូច្នេះហើយពេលវេលាហ្នឹងត្រូវប្រើប្រាស់ទៅលើធនធានទាំងអស់នុំងបាន ពួកគាត់ត្រូវនិយាយ ហើយពួកគាត់បាននិយាយជាច្រើនក្រៅពីឃុំប្រាំបី នៃស្រុកត្រាំកក់។ ប្រសិនបើពេលនុំង មេធាវីការពារក្តីគាត់ជំទាស់ ហើយប្រសិនបើអង្គជំនុំជម្រះសាលាដំបូងឯកភាព គឺបានន័យថាគេអាចរកឃើញភស្តុតាងផ្សេងទៀត ហើយស្តាប់អំពីភស្តុ-តាងផ្សេងទៀតនៅក្នុងឃុំទាំងប្រាំបីនុំង។ អានេះគ្រាន់តែជាឧទាហរណ៍មួយប៉ុណ្ណោះ ប៉ុន្តែយើងចង់បង្ហាញថាទឡ្ហីករណ៍របស់យើងគឺមិនមែនជារឿងបញ្ហាបច្ចេកទេសទេ គឺថាវាជាការ ជាព្យសនកម្មយ៉ាងខ្លាំង ប្រសិនយើងឲ្យមេធាវីការពារក្តីលើកអំពីការជំទាស់បែបនេះ គឺថាឱកាសយើងបាត់បង់ឱកាសជាច្រើន ហើយសាលាដំបូងប្រាកដជាបាត់ឱកាសមិនបានស្តាប់សាក្សី ឬក៏ដើមបណ្តឹងរដ្ឋប្បវេណីដទៃទៀត។ ដូច្នេះយើងឃើញថា សាលាដំបូងមានតួនាទីក្នុងការស្វែងរកការពិត។ ដូច្នេះខ្ញុំស្នើសុំដល់អង្គជំនុំជម្រះសាលាកំពូលតម្កល់នូវវិធីសាស្ត្ររបស់សាលាដំបូងហើយសម្រេចថា ទឡ្ហីករណ៍-- ហើយសម្រេចថា មិនអាចលើកបញ្ហាពីវិសាលភាពហ្នឹងបានទេ ហើយស្នើសុំឲ្យច្រានចោលនូវមូលដ្ឋានទាំងអស់នេះ។

សូមអរគុណឯកឧត្តមប្រធាន លោក លោកស្រីចៅក្រម។ ខ្ញុំសូមបញ្ចប់សារណារបស់ខ្ញុំ។

[០៩:៣១:៣១]

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងសូមអញ្ជើញចៅក្រមនៃអង្គជំនុំជម្រះតុលាការកំពូលហ្នឹង បើមានសូមអញ្ជើញធ្វើសំណួរ។

**ចៅក្រម ម៉ូរីន ហាឌីង ក្លាក៖**

ខ្ញុំសូមសួរមួយសំណួរ ដែលខ្ញុំមានការចាប់អារម្មណ៍តាំងពីដំបូងម្ល៉េះ។ តើវាមានសមមូលពាក់ព័ន្ធនៅក្នុងសវនាការព្រហ្មទណ្ឌទៅនឹងទង្វើណាមួយទេ? ខ្ញុំគិតថាសំណួរនេះសំណួរពិបាកយល់បន្តិច ប៉ុន្តែខ្ញុំសូមឲ្យឆ្លើយទៅនឹងសំណួររបស់ខ្ញុំនេះ ថាតើវាមានសមធម៌គោលការណ៍សមធម៌ដែលអាចអនុវត្តទៅនឹងទង្វើណាមួយរបស់ភាគីនៅក្នុងសវនាការលើរឿងក្តីព្រហ្មទណ្ឌដែរឬទេ?

**លោកស្រី អង់តា ហ្គីសសេ៖**

សូមអភ័យទោសលោកស្រីចៅក្រម មើលទៅដូចជាអ្នកបកប្រែមិនយល់ពីសំណួររបស់លោកស្រីនោះទេ ហើយខ្ញុំអត់បានស្តាប់ការបកប្រែ -- អត់បានឮការបកប្រែជាបារាំងទេ។ អ៊ីចឹងសូមលោកស្រីចៅក្រមមេត្តាសួរសំណួរនេះឡើងវិញ។

**ចៅក្រម ម៉ូរីន ហាឌីង ក្លាក៖**

ខ្ញុំ -- ចាំខ្ញុំសួរសំណួរនេះទៅលោកស្រីមេធាវីការពារក្តីតែម្តង។

**លោកស្រី មេហ្គិន ហ៊ីសត៍៖**

សូមអរគុណលោកស្រីចៅក្រម ក្លាក ចំពោះសំណួរនេះ តាមការពិតជំហររបស់យើងគឺថាវាមានលក្ខណៈស្រដៀងគ្នាទាក់ទងទៅនឹងទ្រឹស្តីច្បាប់ពាក់ព័ន្ធទៅនឹងបញ្ហានេះ។ សំណួរនេះគេបានសួរញឹកញាប់ណាស់នៅតុលាការអចិន្ត្រៃយ៍អន្តរជាតិ ដែលថា គឺគេប្រើពាក្យលះបង់សិទ្ធិ។ អ៊ីចឹងគោលការណ៍នេះគឺថាប្រសិនណាភាគីមិនរក្សាភាពនៅស្ងៀមស្ងាត់ មានន័យថា ខ្លួនលះបង់សិទ្ធិពាក់ព័ន្ធទៅនឹងលះបង់បណ្តឹងសាទុក្ខរបស់ខ្លួនហើយ។ ពាក់ព័ន្ធទៅនឹងអ្វីដែលបានកើតឡើង គឺថាភាគីដទៃទៀត គឺគាត់សំអាងទៅលើភាពស្ងៀមស្ងាត់របស់ភាគីដែលដឹងបញ្ហា ហើយអត់លើកបញ្ហានេះនៅក្នុងពេលវេលាដែលពាក់ព័ន្ធនោះទេ។ ហេតុដូច្នេះឯងទើបមានការហាមឃាត់មិនឱ្យលើកឡើង។ អ៊ីចឹងនៅក្នុងកិច្ចដំណើរការនីតិវិធីនេះ គឺគេតែងតែរំឭកជាញឹកញាប់។ អ៊ីចឹងខ្ញុំនិយាយថា ទោះបីជាពាក្យពេចន៍ហ្នឹងវា -- ប៉ុន្តែនៅក្នុងប្រព័ន្ធច្បាប់ខំមិនឡូរបស់យើង គឺគោលការណ៍ក៏វាមានលក្ខណៈស្រដៀងគ្នាដែរ គឺគោលការណ៍ដែលខ្ញុំយោងទៅក្នុងសំណើសារណាបណ្តឹងសាទុក្ខរបស់យើងខ្ញុំ គឺក្នុងកថាខណ្ឌ១៣៣ នៅក្នុងសារណាបណ្តឹងសាទុក្ខរបស់យើងខ្ញុំ ហើយនៅក្នុងជើងទំព័រ។ ដូចដែលខ្ញុំបញ្ជាក់លម្អិតនៅក្នុងសារណាបណ្តឹងសាទុក្ខហើយ អ៊ីចឹងយើងបានដាក់បញ្ចូលកថាខណ្ឌមួយ ប៉ុន្តែយុត្តិសាស្រ្តមកពីតុលាការអចិន្ត្រៃយ៍មានបញ្ជាក់លក្ខណៈលម្អិតអំពីគោលការណ៍នេះ។ ហើយក៏មានការលើកឡើងនៅក្នុងរឿងក្តីជាច្រើនទៀតផងដែរលោកស្រីចៅក្រម។

[០៩:៣៥:៥១]

**ចៅក្រម ម៉ូរីន ហាឌីង ក្លាក៖**

សូមអរគុណសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី។

**លោកស្រី ហេឡេន វើសនុប៖**

អរុណសួស្ដីលោកស្រីចៅក្រម ជំហររបស់យើងខ្ញុំ ក៏ដូចជាជំហររបស់ដើមបណ្ដឹងរដ្ឋប្បវេណីដែរ ដោយសារថាភាគីនុំងបានលះបង់សិទ្ធិហើយ ហើយខ្ញុំសូមទាញចំណាប់អារម្មណ៍អង្គជំនុំជម្រះពាក់ព័ន្ធទៅនឹងសាលដីកាក្នុងសំណុំរឿង០០១ ដែលបានប្រើប្រាស់ ហើយក៏មានការលើកឡើងពាក់ព័ន្ធទៅនឹងបញ្ហានេះផងដែរ ពាក់ព័ន្ធទៅនឹងយុត្តាធិការដាច់ខាត ហើយនៅក្នុងបរិបទនៅក្នុងជើងទំព័រ៧៨ នៅក្នុងកថាខណ្ឌ៣១ តុលាការកំពូលនិយាយអំពី លើកឡើងអំពីការលះបង់សិទ្ធិ ហើយនៅចុងក្រោយនៃសម្រង់ៗយុត្តិសាស្ត្រគឺតុលាការកំពូលបានដកស្រង់អំពីការលះបង់សិទ្ធិរបស់បុគ្គលណាម្នាក់ ឬរបស់ភាគីមួយដែលថា មិនអនុញ្ញាតឲ្យលើកឡើងពីបញ្ហានេះទៀតទេ។ អ៊ីចឹងហើយបានជាបញ្ហាយុត្តាធិការត្រូវបានប្រើប្រាស់ជាញឹកញាប់។ ដូច្នេះខ្ញុំសូមបញ្ជាក់ថា បញ្ហានេះមិនអាចយកមកពិភាក្សាទេ ដោយសារតែវាពាក់ព័ន្ធទៅនឹងការលះបង់សិទ្ធិរួចទៅហើយ។ សូមអរគុណ។

[០៩:៣៧:៤៣]

**លោកស្រី អង់តា ហ្គីសសេះ**

ខ្ញុំសូមរំឭកថា វាច្បាស់ថា សហព្រះរាជអាជ្ញាទើបលើកឡើងអម្បាញ់មិញនេះគឺនៅក្នុងសាល-ដីកា០០១ ឯកសារ F28 ដែលខ្ញុំបានលើកឡើងអម្បាញ់មិញនេះ គឺមិនមានសញ្ញាណទេ ប៉ុន្តែភាសាបារាំងច្បាស់ នៅពេលដែលមានបញ្ហាដែលអាចបញ្ចប់ការចោទប្រកាន់ហ្នឹង គឺមានសរសេរនៅក្នុងកថាខណ្ឌ ៣៥ នៃឯកសារ F28 នេះ គឺសាលដីកា ឌុច។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងបើគ្មានសំណួរបន្តទៅទៀតទេ យើងចូលដល់វគ្គបន្ត។ អ៊ីចឹងសូមអញ្ជើញលោកសហចៅក្រមរបាយការណ៍ ធ្វើរបាយការណ៍វគ្គបន្ត គឺទឡ្ហីករណ៍នៃបណ្ដឹងសាទុក្ខពាក់ព័ន្ធនឹងបទឧក្រិដ្ឋដែល ខៀវ សំផន ត្រូវបានសម្រេចដាក់ពិរុទ្ធភាព។ សូមអញ្ជើញ!

[០៩:៣៩:៤៤]

**ចៅក្រម យ៉ា ណារិន៖**

បាទ សូមអរគុណឯកឧត្តមប្រធាន។ ខ្ញុំសូមអានរបាយការណ៍។ របាយការណ៍របស់សហចៅក្រមរបាយការណ៍ស្ដីពីវគ្គទឡ្ហីករណ៍នៃបណ្ដឹងសាទុក្ខពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋ ដែល ខៀវ សំផន ត្រូវបានសម្រេចដាក់ពិរុទ្ធ។

អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ជនជាប់ចោទមានពិរុទ្ធពីបទឧក្រិដ្ឋមួយចំនួនក្នុង

ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ អំពើប្រល័យពូជសាសន៍លើជនជាតិវៀតណាម តាមរយៈការចូលរួមរបស់គាត់ក្នុងគោលបំណងរួម និងរួមចំណែកក្នុងចេតនាឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្ម ក្នុងសហឧក្រិដ្ឋកម្មរួម។ គាត់ត្រូវបានសម្រេចដាក់ពិរុទ្ធភាពពីបទឧក្រិដ្ឋខាងក្រោមដែលត្រូវបានប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃការអនុវត្តគោលនយោបាយរបស់បក្សកុម្មុនីស្តកម្ពុជាក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ក) ឧក្រិដ្ឋ -- បទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមានដូចជា ការធ្វើមនុស្សឃាត់ ការសម្លាប់រង្គាល ការនិរទេស ការដាក់ឱ្យប្រើជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ សាសនា ពូជសាសន៍ និងអំពើអមនុស្សធម៌ដទៃទៀត តាមរយៈការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្ស។ អំពើដែលត្រូវបានចាត់ទុកថាជាការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ ការផ្លាស់ទីដោយបង្ខំ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបការដោយបង្ខំ។ ខ) បទឧក្រិដ្ឋនៃអំពើប្រល័យពូជសាសន៍ តាមរយៈការសម្លាប់សមាជិកនៃជនជាតិភាគតិចវៀតណាមជាក្រុមពូជសាសន៍។ គ) ការរំលោភបំបានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ដោយការធ្វើមនុស្សឃាតដោយចេតនា ការធ្វើបាបយ៉ាងអមនុស្សធម៌ ការបង្កឱ្យមានការរងទុក្ខ ឬព្យសនកម្មធ្ងន់ធ្ងរដល់រូបកាយ ឬសុខភាព ការដកដោយចេតនាពីឈ្លើយសឹក ឬពីជនស៊ីវិលនូវសិទ្ធិទទួលបានការជំនុំជម្រះត្រឹមត្រូវ និងទៀងទាត់ និងការឃុំឃាំងខុសច្បាប់លើជនស៊ីវិលតាមអនុសញ្ញាទីក្រុងហ្សឺណែវនៅមន្ទីរសន្តិសុខស-២១។

[០៩:៤២:៣០]

អង្គជំនុំជម្រះសាលាដំបូងក៏បានយល់ឃើញផងដែរថា ជនជនជាប់ចោទ -- ជនជាប់ចោទបានជួយទំនុកបម្រុងដល់បទឧក្រិដ្ឋនៃបទឧក្រិដ្ឋកម្មមនុស្សជាតិ មានដូចជា ការធ្វើមនុស្សឃាតដោយចេតនាប្រយោលនៅសហករណ៍ត្រាំកក់ ការដ្ឋានធ្វើការទំនប់១មករា ការដ្ឋានធ្វើការទំនប់ត្រពាំងថ្ម ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង មន្ទីរសន្តិសុខស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ និងភ្នំក្រោលពាក់ព័ន្ធនឹងការស្លាប់កម្មករ កសិករនៅសហករណ៍ ការដ្ឋានធ្វើការនៅមន្ទីរសន្តិសុខទាំងនេះ។

ជនជាប់ចោទបច្ចុប្បន្នជំទាស់រាល់ការពិរុទ្ធភាពពីបទឧក្រិដ្ឋខាងលើ និងបានលើកំហុសអង្គហេតុ និងអង្គច្បាប់។ អំណះអំណាងរបស់ជនត្រូវចោទបានសង្ខេបដូចខាងក្រោម៖

កំហុសអង្គច្បាប់។ ជនជាប់ចោទបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងរំលោភបំពានលើគោលការណ៍នីត្យានុកូលភាព ដោយខកខានក្នុងការអនុវត្តតាមលក្ខណៈវិនិច្ឆ័យគតិយុត្ត ក្នុងការពិនិត្យ

លើបញ្ហាថាតើបទឧក្រិដ្ឋ ឬទម្រង់នៃការទទួលខុសត្រូវនោះ ជនជាប់ចោទបានដឹងគ្រប់គ្រាន់ថាជាបទល្មើស និងមានច្បាប់ចែងក្នុងឆ្នាំ១៩៧៥ ដែរ ឬយ៉ាងណា? ការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើកត្តាទាំងបីក្នុងការវិភាគរបស់ខ្លួនត្រូវបានជំទាស់។ កត្តាទាំងនោះមានអាទិភាពជាបទឧក្រិដ្ឋ ឬជាទម្រង់នៃការទទួលខុសត្រូវក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅពេលប្រព្រឹត្តបទល្មើស។ ភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ និងចុងក្រោយតួនាទីរបស់ជនជាប់ចោទជាសមាជិកនៃរដ្ឋអំណាចគ្រប់គ្រងរបស់កម្ពុជាប្រជាធិបតេយ្យ។ ការអះអាងថាការអនុវត្តនូវលក្ខខណ្ឌលក្ខណៈវិនិច្ឆ័យទាំងនេះមានកំហុសអង្គច្បាប់ដែលធ្វើឲ្យការយល់ឃើញ និងការដាក់ពិរុទ្ធភាពទាំងអស់ទៅជាមោឃៈ។ អំណះអំណាងដែលពាក់ព័ន្ធទៅនឹងកំហុសអង្គច្បាប់ស្តីពីគោលការណ៍នីត្យានុកូលភាព ត្រូវបានលើកឡើងជាច្រើនដងក្នុងសារណារបស់ជនជាប់ចោទ។

អង្គជំនុំជម្រះជឿជាក់ថា ការជំទាស់ទៅនឹងនីត្យានុកូលភាពនៃបទឧក្រិដ្ឋជាក់លាក់ជាការសមស្របអាចត្រូវធ្វើឡើងនៅក្នុងផ្នែកស្តីពីបទឧក្រិដ្ឋនេះ។ ជនជាប់ចោទបានជំទាស់ទៅនឹងការផ្តល់និយមន័យផ្នែកច្បាប់នៃអំពើមនុស្សឃាតដោយចេតនាប្រយោល និងលើកឡើងថា ពុំមានអាទិភាពនៃទស្សនៈស្តីពីអំពើមនុស្សឃាតដោយចេតនាប្រយោលក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងឆ្នាំ១៩៧៥ ឡើយ។ អាស្រ័យហេតុនេះរាល់ការយល់ឃើញនៃអំពើមនុស្សឃាតដោយចេតនាប្រយោលនេះត្រូវបដិសេធចោល។

[០៩:៤៤:៥៥]

អាទិភាពនៃអំពើមនុស្សឃាតដោយចេតនាប្រយោលក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងឆ្នាំ១៩៧៥ ត្រូវបានសម្រេចតាំងពីដំបូងរួចមកហើយក្នុងបណ្តឹងសាទុក្ខនៃសំណុំរឿង០០២/០១។ អង្គជំនុំជម្រះស្វាគមន៍ការបំភ្លឺលើមូលហេតុដែលលើកបញ្ហានេះមកតវ៉ាជាថ្មី។ ជាជម្រើសដល់ការជំទាស់ច្រើនចំណុចទៅនឹងការយល់ឃើញនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ លើការស្លាប់ប្រជាជនដោយសារលក្ខខណ្ឌនៃការធ្វើការ ការរស់នៅ ការឃុំឃាំងនៅការដ្ឋានធ្វើការ សហករណ៍ និងមន្ទីរសន្តិសុខផ្សេងៗ ជនជាប់ចោទបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការផ្តល់និយមន័យផ្នែកច្បាប់ស្តីពីកំហុសអសកម្មដែលឈានដល់ការយល់ឃើញពុំត្រឹមត្រូវពាក់ព័ន្ធទៅនឹងការស្លាប់នៅកន្លែងប្រព្រឹត្តបទល្មើសនានា។

បន្ថែមលើនេះ ជនជាប់ចោទបានអះអាងថា ពុំមានភស្តុតាងគ្រប់គ្រាន់សម្រាប់ដាក់ពិរុទ្ធភាពឲ្យហួសពីវិមតិសង្ស័យសម្រាប់អំពើមនុស្សឃាតនៃឧក្រិដ្ឋកម្មមនុស្សជាតិប្រឆាំងជនជាតិចាម និងជនជាតិ

វៀតណាម។ អំណះអំណាងពាក់ព័ន្ធមួយចំនួនៗបានជំទាស់ទៅនឹងភាពគ្រប់គ្រាន់នៃភស្តុតាងក្នុងការបង្ហាញធាតុផ្សំអត្តនោម័តិ និង/ឬសត្យានុម័តសម្រាប់បទឧក្រិដ្ឋនៃការសម្លាប់រង្គាល ដោយរួមបញ្ចូលការសម្លាប់ក្នុងទ្រង់ទ្រាយធំលើជនជាតិវៀតណាម ក្នុងខេត្តស្វាយរៀង កំពង់ឆ្នាំង វត្តខ្សាច់ ក្រចេះ និងនៅទឹកដីកម្ពុជាប្រជាធិបតេយ្យ និងជនជាតិចាមនៅវត្តអូរត្រកួនក្នុងឆ្នាំ១៩៧៧ និងភូមិទ្រា។

[០៩:៤៦:៣៤]

ជនជាប់ចោទបានជំទាស់ទៅនឹងការផ្ដល់និយមន័យរបស់អង្គជំនុំជម្រះសាលាដំបូងអំពីធាតុផ្សំចាំបាច់នៃបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញដោយសារមូលដ្ឋានសាសនា ដែលតាមការលើកឡើងបាននាំឱ្យអង្គជំនុំជម្រះប្រព្រឹត្តកំហុសផ្នែកអង្គច្បាប់ និងអង្គហេតុពាក់ព័ន្ធទៅនឹងការប្រព្រឹត្តលើអ្នកកាន់ពុទ្ធសាសនា និងជនជាតិចាម។ ជាពិសេស ជនជាប់ចោទបានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការផ្ដល់និយមន័យនៃធាតុផ្សំអត្តនោម័តិ សម្រាប់បទឧក្រិដ្ឋទាំងនោះ។ ជនជាប់ចោទបានជំទាស់ទៅនឹងភាពគ្រប់គ្រាន់នៃភស្តុតាងសម្រាប់ការដាក់ពិរុទ្ធពីបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញ ដោយសារមូលហេតុនយោបាយលើប្រជាជនថ្មី អតីតនាយ -- អតីតទាហាននៃរបបសាធារណរដ្ឋខ្មែរ សត្រូវពិតប្រាកដ ឬសត្រូវតាមការសន្មត ឬជនជាតិចាមដែលត្រូវបានកំណត់គោលដៅជាក់លាក់ និងការដាក់ឱ្យឋិតនៅក្រោមការប្រព្រឹត្តដោយរើសអើង។ ជនជាប់ចោទបានជំទាស់ទៅនឹងការយល់ឃើញនូវបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញ ដោយសារមូលហេតុពូជសាសន៍លើជនជាតិវៀតណាម ដែលរស់នៅក្នុងប្រទេសកម្ពុជា ដូចជា ការលើកឡើងដោយជនជាប់ចោទថា ជនជាតិវៀតណាមក្នុងកម្ពុជាប្រជាធិបតេយ្យពុំមែនជាក្រុមពូជសាសន៍ជាក់លាក់នោះឡើយ។ អំណះអំណាងដែលបានលើកឡើងពាក់ព័ន្ធទៅនឹងការដាក់ពិរុទ្ធភាពពីបទធ្វើទុក្ខបុកម្នេញលើជនជាតិវៀតណាមតាមរយៈការនិរទេស ការចាប់ខ្លួន និងការធ្វើមនុស្សឃាតដោយមូលហេតុពូជសាសន៍ និងចេតនារើសអើងក្នុងកម្រិតនៃលក្ខខណ្ឌតម្រូវ។

[០៩:៤៨:២៣]

អំណះអំណាងមួយចំនួនពាក់ព័ន្ធទៅនឹងកំហុសអង្គច្បាប់ បានលើកឡើងទាក់ទងទៅនឹងការផ្លាស់ទីដោយបង្ខំ ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ ការវាយប្រហារលើសេចក្ដីថ្លៃថ្នូររបស់មនុស្ស ការរំលោភសេពសន្ថវៈ និងការរៀបការដោយបង្ខំ ដែលជាបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ដទៃទៀត។

ការជំទាស់ជាបឋមពាក់ព័ន្ធទៅនឹង៖ ក) ការកំណត់និយមន័យរបស់អង្គជំនុំជម្រះសាលាដំបូង អំពីច្បាប់ដែលអាចអនុវត្តបានលើអំពើមនុស្សធម៌ដទៃទៀត។ ខ) ការខកខានក្នុងការពិចារណាលើបញ្ហាថាតើអង្គហេតុដែលជាបទឧក្រិដ្ឋ ត្រូវជនជាប់ចោទបានដឹងគ្រប់គ្រាន់ថាមានច្បាប់ចែងក្នុងឆ្នាំ១៩៧៥ ដែរឬយ៉ាងណា? ពាក់ព័ន្ធទៅនឹងការសម្រេចឲ្យជាប់ពិរុទ្ធពីបទនៃការធ្វើឲ្យបាត់ខ្លួនដោយបង្ខំ ជាទូទៅជនជាប់ចោទបានជំទាស់ទៅនឹងកំហុសផ្នែកអង្គច្បាប់ និងអង្គហេតុ ជាពិសេសលើបញ្ហាថាតើជនជាតិវៀតណាមគឺជាជនរងគ្រោះនៃការធ្វើឲ្យបាត់ខ្លួនដោយបង្ខំនៅសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខភ្នំក្រោលដែរឬយ៉ាងណា? ជនជាប់ចោទបានជំទាស់លើបញ្ហាថាតើការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ដែលថាខ្មែរក្រោមអាចជាជនរងគ្រោះនៃការធ្វើឲ្យបាត់ខ្លួនដោយបង្ខំ ដែលជាអង្គហេតុត្រូវយកមកអំណះអំណាងឋិតនៅក្រៅវិសាលភាពនៃសំណុំរឿង០០២/០២ ដែរឬយ៉ាងណា? និងបានជំទាស់បន្ថែមទៀតថា ភស្តុតាងនៃការប្រព្រឹត្តលើខ្មែរក្រោម ត្រូវបានប្រើប្រាស់ដោយពុំស្របច្បាប់ក្នុងការដាក់ពិរុទ្ធភាពលើជនជាប់ចោទពីបទនៃការធ្វើឲ្យបាត់ខ្លួនដោយបង្ខំនៃជនជាតិវៀតណាម។

[០៩:៥០:១២]

អំពើអមនុស្សធម៌ដទៃទៀតដែលមានចរិតលក្ខណៈ ជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបការដោយបង្ខំ ត្រូវបានជំទាស់ដោយផ្អែកលើមូលដ្ឋានថាបទឧក្រិដ្ឋទាំងនោះពុំត្រូវបានជនជាប់ចោទអាចដឹងច្បាស់ថា មានច្បាប់ចែងជាក់លាក់ដោយសារអំពើនោះពុំមាន -- ពុំមែនជាការដាក់ទោសផ្នែកព្រហ្មទណ្ឌក្នុងច្បាប់កម្ពុជា ឬច្បាប់អន្តរជាតិនៅពេលនោះ។ ការជំទាស់ទៅនឹងអង្គហេតុដែលថា លទ្ធភាពនៃការព្រមព្រៀងគ្នារៀបអាពាហ៍ពិពាហ៍។ ការព្រមព្រៀងគ្នា គឺគោលការណ៍ដែលបានអនុម័តដោយបក្សកុម្មុយនីស្តកម្ពុជា ហើយការរៀបអាពាហ៍ពិពាហ៍ដែលបានរៀបចំឡើងក្នុងអំឡុងពេលនារបបកម្ពុជាប្រជាធិបតេយ្យ ដូចគ្នាទៅនឹងការរៀបការដែលរៀបចំឡើងតាមទំនៀមទម្លាប់ប្រពៃណីខ្មែរ។ ហេតុដូច្នេះ គាត់ជំទាស់ទៅនឹងនីត្យានុកូលភាពនៃការដាក់ពិរុទ្ធភាព ក្រោមប្រធានបទនៃការរៀបការដោយបង្ខំ។

បន្ទាប់ពីការដាក់ពិរុទ្ធភាពនៃអំពើអមនុស្សធម៌ដទៃទៀត ដែលបានកើតចេញពីការរៀបការដោយបង្ខំ ជនជាប់ចោទបានលើកឡើងថា បើទោះបីជាអង្គហេតុដែលបានជំទាស់នោះត្រូវបានបង្ហាញក៏ដោយក៏ពុំអាចស្មើទៅនឹងកម្រិតលក្ខខណ្ឌតម្រូវនៃភាពធ្ងន់ធ្ងរ ដែលលក្ខណៈប្រព័ន្ធជាអំពើអមនុស្សធម៌ដទៃទៀតដែរ ដោយពុំមានការប៉ះពាល់ដល់សារណាដែលជារឿងសំខាន់ ជនជាប់ចោទបានជំទាស់ទៅនឹង

អាទិភាពនៃគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលបង្ខំឲ្យរៀបការ និងការរួមដំណេកអាពាហ៍ពិពាហ៍ដើម្បីបង្កើតកូនចៅសម្រាប់អង្គការ។

[០៩:៥២:០១]

ពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋនៃការដាក់ឲ្យទៅជាទាសករក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ជនជាប់ចោទបានជំទាស់ទៅនឹងយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការជម្រះអង្គហេតុពាក់ព័ន្ធទៅនឹងកន្លែងប្រព្រឹត្តបទល្មើសមួយចំនួន មានដូចជាមន្ទីរសន្តិសុខភ្នំក្រោល។ បន្ថែមលើនេះ គាត់បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ ដោយបានសំអាងលើភស្តុតាងមិនគ្រប់គ្រាន់ និងពុំអាចជឿទុកចិត្តបានក្នុងការយល់ឃើញថា មានអាទិភាពនៃបទឧក្រិដ្ឋនេះ។

ប្រហាក់ប្រហែលគ្នានេះដែរ ពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋនៃការធ្វើទារុណកម្មក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គាត់បានជំទាស់ទៅនឹងភាពគ្រប់គ្រាន់នៃភស្តុតាង ដែលបង្កើតការយល់ឃើញអំពីការធ្វើទារុណកម្មលើជនជាតិចាមនៅមន្ទីរសន្តិសុខភូមិទ្រា។ អង្គជំនុំជម្រះស្វាគមន៍ចំពោះអំណះអំណាងដែលផ្តោតលើការជំទាស់ទាំងនេះ។

ពាក់ព័ន្ធទៅនឹងបទចោទនៃការនិរទេសជនជាតិវៀតណាមក្នុងឧក្រិដ្ឋកម្ម ប្រឆាំងមនុស្សជាតិនៅត្រាំកក់។ ជនជាប់ចោទបានលើកអំណះអំណាងដដែលដូចអំណះអំណាងដដែលថា ឧបសម្ព័ន្ធនៃការបំបែកដំណើរការនីតិវិធី ជាភាសាបារាំងពុំមានបទចោទនេះទេ។ បញ្ហានេះអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូលបានដោះស្រាយកំហុសនៃការខ្វះចន្លោះនេះរួចរាល់ហើយ ដែលកើតដែលបានកើតឡើងដោយសារបញ្ហានៃការបកប្រែភាសាបារាំង ប៉ុន្តែចំពោះភាសាខ្មែរ និងភាសា អង់គ្លេសបានបង្ហាញបទចោទនេះ។

[០៩:៥៣:៤២]

អង្គជំនុំជម្រះតុលាការកំពូលស្នើសុំពន្យល់ពីមូលហេតុដែលបញ្ហាដដែលនេះ ដោយបានលើកឡើងម្តងទៀតក្នុងបណ្តឹងសាទុក្ខ។ ជនជាប់ចោទបានជំទាស់បន្ថែមទៀតទៅនឹងភាពគ្រប់គ្រាន់នៃភស្តុតាងដែលដាក់ពិរុទ្ធភាពពីបទឧក្រិដ្ឋនៃការនិរទេសជនជាតិវៀតណាមក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងថាបទឧក្រិដ្ឋនេះត្រូវបានប្រព្រឹត្តឡើងដោយចេតនា ដែលជាលក្ខខណ្ឌតម្រូវក្នុងការផ្លាស់ទីជនរងគ្រោះដោយបង្ខំឲ្យចេញផុតពីព្រំប្រទល់ជាតិ។ គាត់បានជំទាស់រាល់ការយល់ឃើញផ្នែកអង្គហេតុ និងអង្គច្បាប់ពាក់ព័ន្ធទៅនឹងអំពើមនុស្សឃាតលើជនជាតិវៀតណាម និងអំពើប្រល័យពូជសាសន៍។ ជនជាប់

ចោទបានជំទាស់ទៅនឹងការយល់ឃើញដែលថា អំពើមនុស្សឃាតលើជនជាតិវៀតណាម ត្រូវបានប្រព្រឹត្តឡើងនៅតាមសហករណ៍នានា និងលើទឹកដីកម្ពុជា និងជំទាស់បន្ថែមទៀតថា បទឧក្រិដ្ឋបានប្រព្រឹត្តឡើងដោយចេតនាតម្រូវតាមលក្ខខណ្ឌក្នុងការកម្ទេចក្រុមជនជាតិភាគតិចវៀតណាម។

ជាចុងក្រោយជនជាប់ចោទបានអះអាងថា អ្នកជាប់ឃុំជាជនជាតិវៀតណាមដែលត្រូវបានឃុំខ្លួននៅមន្ទីរស-២១ និងមន្ទីរសន្តិសុខអូរកន្សែង ឬនៅឯសមុទ្រ ពុំមែនជាសមាជិកនៃក្រុមដែលត្រូវបានការពារ ផ្អែកលើមូលដ្ឋានតែមួយគត់ ដែលថាអ្នកទាំងនោះជាជនជាតិវៀតណាមនោះទេ។

ខ្ញុំសូមបញ្ចប់របាយការណ៍ស្តីពីទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋ ដែលជនជាប់ចោទត្រូវបានសម្រេចដាក់ពិរុទ្ធភាពនេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះតុលាការកំពូល សូមប្រកាសសម្រាកនាពេលនេះ ហើយចូលវិញនៅវេលាម៉ោងដប់ និងម្ភៃប្រាំនាទី។ សូមសម្រាក។

*(សវនាការសម្រាកពីម៉ោង ០៩:៥៥ នាទី ដល់ម៉ោង ១០:២៣ នាទី)*

[១០:២៣:២៥]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

ជាបន្តសូមអញ្ជើញមេធាវីការពារក្តី ខៀវ សំផន ធ្វើសារណា។

**លោកស្រី អង់តា ហ្គីសសេះ**

ជម្រាបសួរលោកប្រធាន អស់លោក លោកស្រីចៅក្រមជាទីគោរព។ សូមអរគុណដែលផ្តល់វេទិកាមកខ្ញុំ ដោយពេលវេលាហ្នឹងខ្លី ហើយនិងអលទ្ធភាពក្នុងការឆ្លើយតបទៅនឹងដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងព្រះរាជអាជ្ញា ឥឡូវនេះ ខ្ញុំសូមកម្រិតត្រឹមតែនិយាយអំពីអំពើប្រល័យពូជសាសន៍លើជនជាតិវៀតណាម និងឧក្រិដ្ឋកម្មធ្វើទុក្ខបុកម្នេញ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ហើយនិងអំពើអមនុស្សធម៌ផ្សេងៗទៀត ដូចជាការរៀបការដោយបង្ខំជាដើម។ ហើយខ្ញុំមើលទៅតាមពេលវេលាថាតើនឹងឆ្លើយទៅនឹងសំណួរអស់លោក លោកស្រីចៅក្រមតាមបែបណា?

ខ្ញុំសូមបញ្ជាក់ផងដែរថា ការដែលខ្ញុំផ្តោតទៅលើប្រធានបទទាំង៣ នេះៗគឺមិនមែនបានន័យថា យើងៗផ្អែកទៅលើមូលដ្ឋានថ្មីផងដែរ ហើយយើងបានកំណត់ -- បែបចែកជាប្រធានបទ ឥឡូវដែលយើងចាប់អារម្មណ៍ទៅលើអំពីប្រល័យពូជសាសន៍លើជនជាតិវៀតណាម ដែលលើកឡើងនៅក្នុងសាលក្រម ហើយនិងវិភាគទៅលើអង្គហេតុទាំងអស់នេះ គឺយើងត្រូវត្រឡប់និយាយអំពីបណ្តឹងទាំងមូល ហើយនិងពីសេចក្តីសម្រេចលើអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូង។ ព្រះរាជអាជ្ញាបានលើកឡើងថា នៅក្នុងកថាខណ្ឌ៣២០ របស់ខ្លួន ថាគឺឆ្លុះទាក់ទងទៅលើឋានៈជនជាតិវៀតណាមនៅខេត្តស្វាយរៀង ហើយនិងព្រៃវែង -- ក្រៅពីខេត្តទាំងពីរហ្នឹង។

នេះគឺជាឧទាហរណ៍ដ៏ល្អដើម្បីបញ្ជាក់អំពីការទាមទាររបស់យើងអំពីការបណ្តឹងទាំងមូលទាក់ទងទៅនឹងការលើកឡើងរបស់ខ្ញុំនេះ ខ្ញុំសូមលើកទៅនឹងសារណាបណ្តឹងឧទ្ធរណ៍របស់យើងខ្ញុំគឺ កថាខណ្ឌ៤៣៥, ៤៣៨, ៥២០ និង ៥២២ -- ៥២១ ដែលនៅក្នុងនោះមានយោងទាក់ទងទៅនឹងអង្គហេតុដែលនិយាយលើកឡើងនៅក្នុងសវនាការផងដែរ។ ហើយនិងសារណាស្តាពររបស់យើងខ្ញុំគឺកថាខណ្ឌ ១៨៧៨, ១៨៩៦ និង ១៩៣២ ដល់ ១៩៣៤ ហើយខ្ញុំមានយោងផ្សេងទៀតនៅក្នុងទាក់ទងនឹងចម្លើយរបស់សហព្រះរាជអាជ្ញា គឺកថាខណ្ឌ -- នៅពេលដែលគាត់ -- នៅកថាខណ្ឌ៣១៦ និង ៣២១ នៅក្នុងដីកាដំណោះស្រាយនិយាយអំពីអង្គហេតុដែលកំណត់ដោយសហចៅក្រមស៊ើបអង្កេតថា តើមនុស្សជាតិ *(ឮមិនច្បាស់)* មនុស្សឃាតប្រល័យពូជសាសន៍ ហើយដែលជាធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងនឹងពូជសាសន៍ និងការសម្លាប់រង្គាល។

[១០:២៧:៤៩]

មិនមានការបញ្ជាក់អំពីទីតាំងភូមិសាស្ត្រ ក៏ប៉ុន្តែនៅក្នុងដីកាដំណោះស្រាយនិយាយ ដែលនិយាយអំពីអង្គហេតុនោះ សហចៅក្រមស៊ើបអង្កេតបានចាប់ផ្តើមរំឭកថា ខ្ញុំសុំដកស្រង់៖ “គាត់បានទទួលបណ្តឹងអំពីវិធានការប្រឆាំងនឹងជនជាតិវៀតណាមនៅក្នុងខេត្តព្រៃវែង និងស្វាយរៀង នៅពេលដែលវៀតណាមវាយលុកចូលមក -- ចូលទៅក្នុងប្រទេសវៀតណាម” បន្ទាប់មកទៀតគាត់បាននិយាយលម្អិតផ្នែកពីរ គឺទី១ និយាយអំពីការសម្លាប់ជនជាតិស៊ីវិលវៀតណាមនៅក្នុងខេត្តព្រៃវែង ហើយនិងស្វាយរៀង។ ហើយផ្នែកទី២ ហ្នឹងគាត់និយាយអំពីការសម្លាប់រង្គាលជនជាតិស៊ីវិលវៀតណាមក្រៅខេត្តព្រៃវែង ហើយនិងស្វាយរៀង ដូច្នេះមានផ្នែកតូចៗនេះ២។ ហើយនៅផ្នែកតូចៗទី២ នេះដែលនិយាយពីព្រឹត្តិការណ៍ក្រៅពីខេត្តទាំងពីរនេះនោះ ហើយចាប់ផ្តើមដោយពាក្យដូចទៅការសម្លាប់ជនជាតិស៊ីវិល

វៀតណាមមិនកម្រិតមិនត្រឹមតែខេត្តព្រៃវែង ស្វាយរៀងនេះទេ ដែល -- ក៏ប៉ុន្តែវារៀបចំក្នុងក្របខ័ណ្ឌនយោបាយជាតិតែម្តង។ ហើយបើយើងអានដីកាដំណោះស្រាយនេះ យើងឃើញថាគាត់ទទួលតែអង្គហេតុនៅព្រៃវែង ស្វាយរៀង ហើយនៅពេលដែលវ៉ៃលុកចូលប្រទេសវៀតណាម ហើយបន្ទាប់មកទៀតហ្នឹងគឺចៅក្រមស៊ើបអង្កេតបានបង្ហាញឲ្យឃើញថា មានគោលនយោបាយថ្នាក់ជាតិ។ នៅក្នុងដីកាបញ្ជូនរឿងទៅស៊ើបសួរនោះជន -- ព្រះរាជអាជ្ញាបានប្តឹងទៅចៅក្រមតែរឿងអង្គហេតុព្រៃវែង ស្វាយរៀងនៅពេលវ៉ៃចូលទៅប្រទេសវៀតណាមនោះទេ។ មុននឹងចេញដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានបដិសេធសំណើរបស់សហព្រះរាជអាជ្ញា ហើយនិងដើមបណ្តឹងរដ្ឋប្បវេណី ដែលឲ្យពិនិត្យភស្តុតាងទាក់ទងនឹងឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងខេត្តផ្សេងទៀត។

ហើយនៅក្នុងសេចក្តីសម្រេចបដិសេធនេះគាត់បញ្ជាក់ថា បើសិនជាយើងយោងទៅកថាខណ្ឌ ៩៩ និង -- ៦៩ និង ៧០ សហចៅក្រមស៊ើបអង្កេតបានទទួលបណ្តឹងអំពីការប្រព្រឹត្តទៅលើជនជាតិវៀតណាមដែលនៅខេត្តព្រៃវែង ស្វាយរៀង ហើយនិងជនជាតិវៀតណាម និងនៅប្រទេសវៀតណាមនៅពេលដែលវ៉ៃលុកចូលប្រទេសវៀតណាម។

[១០:៣០:១២]

ព្រះរាជអាជ្ញាមិនដែលបានចេញដីកាបញ្ជូនរឿងទៅស៊ើបសួរបន្ថែមទេ។ ហើយអង្គជំនុំជម្រះបានទទួលតែអង្គហេតុប្រឆាំងនឹងជនជាតិវៀតណាមទៅលើតែខេត្តពីរហ្នឹងទេ គឺព្រៃវែង និងស្វាយរៀង។ ហើយការបំបែកកិច្ចដំណើរការនីតិវិធី ដែលធ្វើឡើងនៅពេលក្រោយនោះ គឺទាក់ទងការវ៉ៃលុកចូលប្រទេសវៀតណាមតែប៉ុណ្ណោះ។ ក៏ប៉ុន្តែនៅក្នុងសំអាងហេតុសាលក្រមថា អង្គហេតុទាំងអស់ហ្នឹងគឺថានៅលើគ្របដណ្តប់លើប្រទេសវៀតណាម -- ប្រទេសកម្ពុជាទាំងអស់ដដែល។ ហើយគាត់និយាយថាអង្គហេតុនៅខេត្តព្រៃវែងមិនគ្រប់គ្រាន់ នៅដែនទឹក ហើយនិងនៅវត្តនៅខេត្តសៀមរាប និងក្រចេះជាដើម។ អ៊ីចឹងយើងត្រូវដឹងថាតើម៉េចបានចេញទៅជាសេចក្តីសន្និដ្ឋានបែបហ្នឹង។ ការបង្ហាញពីកាលប្រវត្តិហ្នឹងអាចធ្វើឲ្យយើងយល់ថាតើការកាត់សេចក្តីហ្នឹងប្រព្រឹត្តទៅយ៉ាងដូចម្តេចដែរ?

ខ្ញុំសូមរំឭកថានៅពេលដែលធ្វើសេចក្តីប្រកាសដំបូងហ្នឹងគឺឯក -- ព្រះអាជអាជ្ញានិយាយតែអំពីព្រៃវែង ហើយស្វាយរៀងទេ គឺហើយគាត់និយាយអំពីការលើកឡើងពីការសម្លាប់រង្គាលនៅកន្លែងផ្សេងទៀតហ្នឹងតែបន្តិចបន្តួចប៉ុណ្ណោះទេ។ ក្នុងគោលបំណងបង្ហាញថាមានអំពើប្រល័យពូជសាសន៍នៅខេត្តព្រៃវែង ស្វាយរៀង ហើយគាត់បានសន្និដ្ឋានថា អង្គាល់ថ្ងៃនោះគាត់និយាយថា នៅ -- គឺឯកសារ

E1/13.1 ប្រហែលជាម៉ោង១៨:២០វិនាទី -- ២៨វិនាទី។ អស់លោក លោកស្រីចៅក្រម ខ្ញុំសុំដកស្រង់ ៖ "ជន -- ភស្តុតាងបញ្ជាក់ថា ការកម្ទេចជាប្រព័ន្ធទៅលើសហករណ៍ -- សហគមន៍វៀតណាមនៅព្រៃវែង ហើយស្វាយរៀងនោះ វាជាអំពើប្រល័យពូជសាសន៍។ អ៊ីចឹងគាត់និយាយលើកឡើងអ៊ីចឹងនៅកាលពីដំបូងទីនៃសំណុំរឿង០០២ ហើយបន្ទាប់មកតើវាវិវត្តន៍ទៅយ៉ាងម៉េចវិញ ពាក់ព័ន្ធនឹងការលើកឡើងរបស់គាត់នៅក្នុងពេលដែលបង្ហាញភស្តុតាង ទាំងយើងទាំងអស់គ្នា គឺយល់ស្របគ្នាថា ភស្តុតាងក្រៅពីព្រៃវែង ហើយនិងស្វាយរៀងនោះគឺធ្វើឡើងដើម្បីតែបង្កើត បង្ហាញអំពីគោលនយោបាយថ្នាក់ជាតិទេ។

[១០:៣២:៥៣]

អង្គជំនុំជម្រះបានកោះហៅសាក្សីប្រាំបួនរូប ហើយនិងដើមបណ្តឹងរដ្ឋប្បវេណីហ្នឹងពីររូប ហើយនៅឆ្នាំ២០១៥ គឺឯកសារ E319/36 កថាខណ្ឌ១១ ព្រះរាជអាជ្ញាបានសុំស្នើសាក្សីថ្មីម្នាក់ទៀត សាក្សីនេះដែលជាអតីតកម្មាភិបាលនៅកងពល១៦៤ ជាកងទ័ពជើងទឹក គឺមានសារៈសំខាន់ខ្លាំងណាស់ទាក់ទងនឹងការចោទប្រកាន់ទាក់ទងទៅនឹងការទទួលបញ្ជាសម្លាប់ជនជាតិវៀតណាមទាំងអស់ ដែលចាប់បាននៅសមុទ្រ ហើយនិងគោលនយោបាយទូទៅនៃកម្ពុជាប្រជាធិបតេយ្យចំពោះជនជាតិវៀតណាម។ ហើយយើងមាន -- យើងបានជំទាស់ទៅលើសាក្សីពីររូបទៀត គឺឯកសារ E1/360.1 ចន្លោះពីម៉ោង ០៩:៣៧:១០ -- ម៉ោង០៩:៤០នាទី អង្គជំនុំជម្រះបានផ្តល់ព្រមតាមសំណើរបស់ព្រះរាជអាជ្ញា ដោយពន្យល់ថាតាមពិតគឺឯកសារ E1/363/1 នៅពេលដែលផ្តល់សក្ខីកម្មនោះ គឺនៅមានមេធាវី នួន ជា គាត់ជំទាស់ ហើយភាគីទាំងអស់គាត់ឆ្លើយយ៉ាងម៉េច។

[១០:៣៤:២៦]

មេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណីនេះឆ្លើយតបទៅនឹង -- គាត់ឆ្លើយថា សាក្សី -- ដើមបណ្តឹងរដ្ឋប្បវេណី ប្រាក់ វឿន នេះមានជាប់ពាក់ព័ន្ធនឹងគោលនយោបាយនៃវិធានការប្រឆាំងនឹងជនជាតិវៀតណាម។ ដូច្នេះ ខ្ញុំសុំសួរថា តើការអនុវត្តជាទូទៅជាទម្លាប់នៅទីនេះគេធ្វើយ៉ាងម៉េច? គឺការអនុវត្តនេះគឺអង្គជំនុំជម្រះគាត់ធ្វើតាំងពី -- ទាក់ទងជាមួយវៀតណាម និងទាក់ទងជាមួយនឹងអង្គហេតុទាំងអស់ ទាក់ទងទៅនឹងសំណុំរឿង០០២ នេះ ០០២/២ នេះ គឺស្តាប់សាក្សី ទោះបីជាគាត់នោះនិយាយមិននៅក្នុងវិសាលភាពនៃសំណុំរឿង រឿងក្តីនេះក៏ដោយ ក៏ប៉ុន្តែយ៉ាងហោចណាស់ចំពោះជនជាតិវៀត-ណាមហ្នឹង គឺតែងតែហៅមកនិយាយហួសពីវិសាលភាព។ នៅថ្ងៃសវនាការនោះបញ្ជាក់ថា គោល-បំណងគឺប្រើភស្តុតាងទាំងអស់នេះដើម្បីបង្ហាញថា មានគោលនយោបាយថ្នាក់ជាតិមួយ គឺការលើក

ឡើងរបស់សហព្រះរាជអាជ្ញា គឺឯកសារ E1/361.1 ម៉ោង ១៥:១០ នាទី គឺអង្គជំនុំជម្រះតែងតែមានទំនោរនិយាយថា តែងតែមានជាប់ពាក់ព័ន្ធ ព្រោះថាមានពាក់ព័ន្ធនឹងគោលនយោបាយ។ល។និង។ល។ ហើយខ្ញុំឆ្លើយតបទៅវិញថា យើងមានពេលវេលាតិច ហើយខ្ញុំៗមានតែមានអារម្មណ៍ថា អង្គជំនុំជម្រះតែងតែជំទាស់នឹងការជំទាស់របស់យើង បដិសេធនឹងការជំទាស់របសយើង។

[១០:៣៦:១៣]

សវនាការថ្ងៃដដែលហ្នឹង អង្គជំនុំជម្រះបដិសេធយើង ហើយថាវាមានជាប់ពាក់ព័ន្ធផ្នែក និងគោលនយោបាយ។ អ៊ីចឹងទទួលសំណើរបស់ព្រះរាជអាជ្ញា។ អ៊ីចឹងគឺជាការវិនិច្ឆ័យលើជនជាប់ចោទលើអង្គហេតុដែលនៅព្រៃវែង ហើយនិងមួយទៀតគឺនិយាយអំពីអង្គហេតុទូទៅ គោលនយោបាយទូទៅទៅវិញ។ យើងបានជំទាស់ជាច្រើនដង ប៉ុន្តែអត់ប្រយោជន៍លើការមកផ្តល់សក្ខីកម្មរបស់សាក្សី គឺឯកសារ E381 ថាសាក្សីនេះគឺបង្ហាញពីប្រភពនៃអំពើចង្រៃទាំងអស់ ថាដើម្បីបង្ហាញអំពីគោលនយោបាយថ្នាក់ជាតិ សំណើរបស់គាត់គឺ 381 ដែលនិយាយអំពី ដែលយើងបានលើកឡើងនៅក្នុងសារណាបណ្តឹងឧទ្ធរណ៍របស់យើង។ អ៊ីចឹងអស់លោក លោកស្រីចៅក្រមឃើញ នឹងឃើញថា នៅថ្ងៃដែលយើងបានពិភាក្សាអំពីធាតុផ្សំទាំងអស់នេះ យើងបានជំទាស់ទៅនឹងការមកផ្តល់សក្ខីកម្មរបស់សាក្សីថ្មីហ្នឹង ដោយលើកឡើងថា អ្នកដែលធ្លាប់បានមកផ្តល់សក្ខីកម្មទាក់ទងនឹងគោលនយោបាយថ្នាក់ជាតិនេះ ហើយដែលថាសំណើរបស់សហព្រះរាជអាជ្ញានោះ គឺដោយសារតែគាត់ពុំមានភស្តុតាងគ្រប់គ្រាន់ពាក់ព័ន្ធនឹងខេត្តព្រៃវែង និងស្វាយរៀង។ ហើយនៅថ្ងៃនោះជន -- ខាងព្រះរាជអាជ្ញាលើកឡើងថា គឺវាជាអង្គហេតុនៅស្វាយរៀងទេ ដែលវាទាក់ទងទៅនឹងការចោទប្រកាន់ទៅលើជនជាប់ចោទ ខៀវ សំផន។ ក៏ប៉ុន្តែវាជាគឺត្រូវនិយាយអំពីគោលនយោបាយជាតិ កាលនោះ។ អ៊ីចឹងមានការដកស្រង់កំណត់ត្រាជើងទំព័រ៧៥៨ នៃសារណារបស់យើង។

[១០:៣៨:២៥]

អង្គជំនុំជម្រះបានឆ្លើយទៅនឹងសំណើជាច្រើនរបស់សហព្រះរាជអាជ្ញា ហើយនិងទទួលព្រមស្តាប់សាក្សី។ នៅអនុស្សរណៈឯកសារ E380/1 ហើយនិងសេចក្តីសម្រេច E380/2 ថា សក្ខីកម្មរបស់ពួកគាត់ទាំងអស់នេះ សុទ្ធតែជាប់ពាក់ព័ន្ធជាមួយនឹងគោលនយោបាយប្រឆាំងនឹងជនជាតិវៀតណាមរហូតដល់ពេលនេះហ្នឹង គឺយើងឃើញថា នៅក្រៅវិសាលភាពព្រៃវែង ស្វាយរៀងហ្នឹង គឺនិយាយអំពីគោលនយោបាយទាំងអស់ ហើយបន្ទាប់មកចូលដល់ពេលយើងនិយាយតតាំងចុងក្រោយ សេចក្តី

សន្និដ្ឋានបញ្ចប់ការដេញដោល--

**ប្រធានអង្គជំនុំ៖**

សូមឲ្យខាងមេធាវី -- ហេឡូៗ!

សហមេធាវី សូមនិយាយឲ្យយឺតបន្តិច ខាងបកប្រែបកអត់ទាន់ទេ។

**លោកស្រី អង់តា ហ្គីសសេ៖**

ខ្ញុំនិយាយថា កាលដែលយើងសន្និដ្ឋានបញ្ចប់ការដេញដោល យើងបានរំឭកអំពីវិសាលភាពនៃបណ្ដឹងទាំងមូល ដែលយើងធ្វើនៅក្នុងសារណាចុងក្រោយរបស់យើងហ្នឹងថា អង្គជំនុំជម្រះបានទទួលតែអង្គហេតុអំពីព្រៃវែង និងស្វាយរៀងនោះទេ ហើយអត់មានភស្តុតាង។ យើងបានរំឭកថា សហចៅក្រមស៊ើបអង្កេតមិនត្រូវបានអនុញ្ញាតឲ្យស៊ើបអង្កេតតែលើអ្វីដែលបានកំណត់តាមច្បាប់នៅក្នុងដីកាដំណោះស្រាយតែប៉ុណ្ណោះ។ នៅពេលធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់ការដេញដោល ដើមបណ្ដឹងរដ្ឋប្បវេណីបានឆ្លើយថា គាត់ផ្ដោតតែទៅលើសារណារបស់ពួកគេគាត់នៅ ពាក់ព័ន្ធនឹងព្រៃវែង ហើយនិងសៀមរាបតែប៉ុណ្ណោះ។ ហើយយើងនៅសវនាការថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៧ ឯកសារ E1/526/1 ម៉ោង ០៩:២១ នាទី គឺថា គឺតែងតែប្រាសចាកចេញពីព្រៃវែង ហើយស្វាយរៀង ដោយសារភស្តុតាងហ្នឹងវាមិនគ្រប់គ្រាន់ អ៊ីចឹងត្រូវតែបន្ថែមអង្គហេតុផ្សេងទៀត ហើយក្រោយមក យើងឃើញបញ្ជាក់ឃើញច្បាស់ហើយនៅក្នុងសំអាងហេតុនៃសាលដីកានោះ អង្គជំនុំជម្រះមិនបានរក្សាយកអង្គហេតុតែព្រៃវែងនោះទេ។ ហើយដោយយើងសង្កេតឃើញថា អង្គជំនុំជម្រះថាខ្លួនបានទទួលអង្គហេតុទាំងអស់ដែលកើតឡើងនៅលើប្រទេសកម្ពុជាទាំងមូលតែម្ដង ហើយដែលនៅក្នុងសវនាការហ្នឹង អត់មានបាននិយាយអ៊ីចឹងទេ គឺថាប្រើតែអង្គហេតុដែលនៅក្រៅព្រៃវែង ស្វាយរៀងហ្នឹង គ្រាន់តែបង្កើតបង្ហាញអំពីគោលនយោបាយតែប៉ុណ្ណោះទេ។ អ៊ីចឹងគឺថា ព្រះរាជអាជ្ញាមិនដែលបានឆ្លើយតបទៅនឹងបណ្ដឹងទាំងមូលនោះទេ ប៉ុន្តែយើងនៅក្នុងប្រព័ន្ធច្បាស់ស៊ីវិលឡូ គឺជនព្រះរាជអាជ្ញាហ្នឹងត្រូវសម្រេចថា ក្របខ័ណ្ឌច្បាប់ហ្នឹង យើងត្រូវធ្វើយ៉ាងម៉េច ហើយព្រះរាជអាជ្ញាត្រូវកំណត់ថា តើអង្គហេតុហ្នឹងពាក់ព័ន្ធតែព្រៃវែង ឬស្វាយរៀង ឬក៏យ៉ាងណា?

[១០:៤២:០០]

ហើយខ្ញុំសូមរំឭកផងដែរថា ព្រះរាជអាជ្ញាមិនដែលបានប្ដឹងឧទ្ធរណ៍អំពីការលើកលែងការចោទប្រកាន់ចំពោះខេត្តព្រៃវែងទេ។

នៅកថាខណ្ឌ៣៤៥១ នៃសាលក្រម ថាពុំមានភស្តុតាងពីអំពើប្រល័យពូជសាសន៍នៅព្រៃវែងនោះទេ។ នៅកថាខណ្ឌ៣៤៥៥ អង្គជំនុំជម្រះថានៅព្រៃវែងពុំមានអំពើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទេដោយសារ ហើយក៏មិនមានភស្តុតាង មានសាក្សីណាគ្រប់គ្រាន់ ហើយសាក្សីនោះក៏ឮតាមរបៀបពីមាត់មួយទៅមាត់មួយទៀត។

ដូច្នេះអស់លោក លោកស្រីចៅក្រមតុលាការកំពូលឃើញថា ទាក់ទងនឹងអំពើប្រល័យពូជសាសន៍នេះ គឺមិនមានភស្តុតាងមូលដ្ឋានអីរឹងមាំនោះទេ មានសាក្សីតែមួយគត់ ហើយតាមពាក្យចចាមអារ៉ាមទៀត គឺ ស៊ិន ចែម សាក្សីហ្នឹង ដែលសាក្សី ស៊ិន ចែម នោះមិនមានការគាំទ្រ ហើយគាត់មិនមែនជាសាក្សីផ្ទាល់ពីហេតុការណ៍ ហើយគាត់បានដឹងរឿងរ៉ាវតាមគេ ហើយគាត់អត់ចាំឈ្មោះអ្នកប្រាប់គាត់ទៀត ហើយផ្ទុយស្រឡះពីការសន្និដ្ឋានរបស់អង្គជំនុំជម្រះហ្នឹង ចែម នេះគាត់ថាមិនដែលឃើញគេចាប់វៀតណាម ហើយមុននឹងបាត់ខ្លួននោះទេ នៅក្នុងសវនាការយើងនេះ គាត់បានលើកឡើងថា ការប្រព្រឹត្តិមិនល្អនេះត្រូវបានធ្វើឡើងដោយខ្មែរប្រឆាំងទៅលើជនជាតិជាតិខ្មែរ ហើយគាត់ថាឃើញខ្មោច ហើយគាត់មិនបានចូលជាសាក្សីផ្ទាល់ទេ ហើយគាត់ក៏មិនដឹងថា ខ្មោចនោះជាខ្មោចអ្នកណានោះដែរ។ គឺសវនាការនៅថ្ងៃទី១៤ ធ្នូ ឆ្នាំ២០១៥ ម៉ោង ១៥:១៦នាទី។

[១០:៤៤:៣០]

អ៊ីចឹងគឺថា ខៀវ សំផន គាត់ត្រូវបានផ្ដន្ទាទោសចំពោះអំពើប្រល័យពូជសាសន៍វៀតណាមនេះ គឺមូលដ្ឋានគាំទ្រហ្នឹង គឺស្រាលណាស់។ អ៊ីចឹងគឺភស្តុតាងមិនគ្រប់គ្រាន់។

ដោយហេតុថា មិនដឹងថាចារីជាអ្នកណា យើងដឹងថាគ្រួសារទាំងអស់នោះត្រូវបានសម្លាប់ដោយអ្នកណាហើយជាពាក្យចរចាមអារ៉ាម ហើយគ្មានការគាំទ្រទៀត មិនមែនស៊ីសង្វាក់ទៀត។ ហើយអ៊ីចឹងតាមអង្គហេតុយើងមិនអាចសន្និដ្ឋានថាមានការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ អំពើមនុស្សឃាតនោះទេ។ ហើយអង្គជំនុំជម្រះក៏ដែរអំពីអង្គហេតុនេះ នៅកថាខណ្ឌ នៅក្នុងសាលាក្រមរបស់ខ្លួននោះ ខ្លួនមិនបានពិចារណាដូចគ្នាទេ ដែលមាន ហើយគឺថាគាត់ប្រព្រឹត្តអត់ដូចគ្នាទេ គឺពិចារណាអត់ដូចគ្នាទេ ក្នុងកថាខណ្ឌមួយនោះនៅក្នុងសាលាក្រមនោះ គឺថាមានតែសាក្សីមួយហើយដូចជាឮតាមពាក្យចរចាមអារ៉ាមផង អង្គជំនុំជម្រះធ្វើសេចក្ដីសម្រេចផ្ទុយទៅវិញ។ អ៊ីចឹងគឺបើគិតតាម អង្គហេតុហ្នឹង វាអត់ត្រូវទេ ហើយតាមអង្គហេតុក៏មិនត្រូវ តាមច្បាប់ក៏មិនត្រូវ។

ឥឡូវខ្ញុំចូលទៅនិយាយពីច្បាប់តែម្ដងដែលទាក់ទងទៅនឹងឧក្រិដ្ឋកម្មការធ្វើទុក្ខបុកម្នេញ។ ខ្ញុំភ្ជាប់

សញ្ញាណពីរខុសគ្នា ពីព្រោះមានធាតុពីរស្រដៀងគ្នា។ ខ្ញុំឆ្លើយតបរៀងវែងបន្តិចទៅនឹងព្រះរាជអាជ្ញា។ ការតវ៉ាទី១ របស់យើងគឺអង្គជំនុំជម្រះបានផ្ដល់និយមន័យនៃការធ្វើទុក្ខបុកម្នេញខុសដោយច្រឡំ ពីព្រោះគាត់បានលុបបំបាត់ចោលពីនិយមន័យនៃគោលដៅដកហូតចេញនូវធាតុដ៏សំខាន់មួយ។ ដើម្បីឆ្លើយតបនឹងយើងហ្នឹង ព្រះរាជអាជ្ញានិយាយនៅក្នុងសំណុំរឿង ឌុច ថា សាលាដីកា ឌុច កថាខណ្ឌ២៤០ គាត់និយាយថានៅក្នុងការអះអាងលក្ខណៈទូទៅមួយនោះ តុលាការក្រោយសង្គ្រាមលោកទី២ មិនតម្រូវឲ្យមានលក្ខខណ្ឌបង្ហាញលក្ខខណ្ឌនេះទេទាក់ទងទៅនឹងអំពើធ្វើទុក្ខបុកម្នេញនោះទេ។ ក៏ប៉ុន្តែពុំមានយុត្តិសាស្ត្រណាមួយគាំទ្រការសន្និដ្ឋានរបស់គាត់នោះទេ។ អ៊ីចឹងវាចោទជាបញ្ហា។ ដូច្នេះគាប្បីទៅពិនិត្យលម្អិតនៃយុត្តិសាស្ត្រនោះ។ ខ្ញុំផ្ដល់ប្រភពបន្ថែម ជាការពិតណាស់ចេតនាដកហូតជនជាតិជ្វីហ្វ គឺជាមូលដ្ឋាននៃការប្រកាសពិរុទ្ធភាពនៅក្នុង -- នៅចំពោះមុខតុលាការយោធាអន្តរជាតិ។

[១០:៤៨:០២]

ខ្ញុំយោងទៅប្រភពក្នុងសារណារបស់យើង។ ហើយអ៊ីចឹងវាខុសពីអ្វីដែលនិយាយដែលព្រះរាជអាជ្ញាលើកឡើង គោលជំហររបស់យើង។ យើងយោងទៅចម្លើយតបរបស់យើងនៅក្នុងសារណាបណ្ដឹងឧទ្ធរណ៍របស់យើង ហើយនិងប្រភពដែលយើងបានលើកឡើង ហើយនិងសាលក្រមរបស់តុលាការយោធាអន្តរជាតិ និងសំណុំរឿងក្ដីមួយចំនួនទៀត ដូចករណីរឿងនៅអូស្ត្រាលី ហើយនិងទម្រង់ធ្វើទុក្ខបុកម្នេញនេះ។ អំពើប្រល័យពូជសាសន៍តម្រូវកម្ទេច ហើយការធ្វើទុក្ខបុកម្នេញគឺដកមនុស្សចេញពីក្រុម។ អ៊ីចឹងវាខុសគ្នាសញ្ញាណពីរនេះ។ ខ្ញុំសុំយោងទៅនឹងការវិភាគនៃ -- ការវិភាគរបស់តុលាការមួយនិយាយពីចេតនាដកហូតចេញពីក្រុមពីសហគមន៍។ ឥឡូវខ្ញុំសូមយោងទៅនឹងការផ្ដន្ទាទោសរបស់ហ្វ៊ីតទំព័រ១៧៦ ការកាត់ទោសផ្ដន្ទាទោស ឈីន ឈីនត្រា *(តាមការបកប្រែ)* ការផ្ដន្ទាទោស ហ្វ្រង់ ទំព័រ១៩៤។ វាច្បាស់ណាស់ថា ចេញពីសាលក្រមទាំងអស់នេះគឺថាឧក្រិដ្ឋកម្មលើការធ្វើទុក្ខបុកម្នេញ គឺត្រូវតែមានចេតនារើសអើង ហើយដែលមានក្នុងបំណងដកហូតពួកជ្វីហ្វចេញពីទ្វីបអឺរ៉ុប។ ខ្ញុំយោងទៅនឹងសារណាបណ្ដឹងឧទ្ធរណ៍របស់យើង។ អ៊ីចឹងគឺអង្គជំនុំជម្រះបានប្រព្រឹត្តកំហុសអង្គច្បាប់។ អំពើប្រល័យពូជសាសន៍នោះគឺជា គឺមានគោលបំណងកម្ទេចក្រុមចោលតែម្ដង យោងទៅនឹងមាត្រា ជីរ៉ូវិចស៍។ សាលាដំបូង -- ក៏ប៉ុន្តែការរើសអើងមិនផ្ទាល់នោះ មិន--

**អ្នកបកប្រែ៖**

លោកប្រធាន គាត់និយាយលឿនពេក។ អ្នកបកប្រែពិបាកតាមណាស់។

[១០:៥១:១៦]

**លោកស្រី អង់តា ហ្គីសសេះ**

ដើមបណ្ដឹងរដ្ឋប្បវេណីបាននិយាយពីការរើសអើងដោយប្រយោល ដែលយើងឆ្លើយតបទៅគាត់វិញ រំឭកថាតាមច្បាប់អន្តរជាតិនោះមិនត្រឹមត្រូវនោះទេ ព្រោះវាមិនមែនជាច្បាប់ព្រហ្មទណ្ឌទេ។ នៅក្នុងសាលាក្រម ជីជីវិច បាននិយាយថាការជ្រើសរើសជនរងគ្រោះ ដើម្បីធ្វើទុក្ខបុកម្នេញ ហើយត្រូវបង្ហាញអំពីចេតនារើសអើងទៅទៀត ក៏ប៉ុន្តែមិនបានធ្វើការបង្ហាញនេះទេ។

ឥឡូវនេះខ្ញុំចូលទៅក្នុងឧក្រិដ្ឋកម្មអំពើប្រល័យពូជសាសន៍។ យើងផ្ដល់ទឡ្ហីករណ៍របស់យើងហ្នឹងនៅក្នុងកថាខណ្ឌ១០៥៩ នៃសារណាបណ្ដឹងឧទ្ធរណ៍របស់យើង។ អង្គជំនុំជម្រះបានប្រព្រឹត្តកំហុសយ៉ាងធ្ងន់ ដោយរំលងនូវធាតុផ្សំពិសេសនៃឧក្រិដ្ឋកម្មអំពើប្រល័យពូជសាសន៍ គឺលក្ខណៈធំធេង។ ហើយនៅក្នុងសំណុំរឿងនោះ មិនមានឃើញបង្ហាញពីក្រុមណាមួយដែលកំណត់ជាគោលដៅនោះទេ។ ហើយខ្ញុំសុំយោងទៅលើអង្គហេតុនៅស្វាយរៀងជាដើម គឺផ្អែកតែលើសាក្សីតែមួយនោះក៏បានទាញការសន្និដ្ឋានថាមានការសម្លាប់លើគ្រួសារវៀតណាមនោះបួនគ្រួសារ ហើយក៏ទាញសន្និដ្ឋានថាមានការធ្វើប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ហើយភស្តុតាងទាំងអស់ហ្នឹងគឺចេញពីពាក្យចរចាមអារ៉ាមទៀត។ ហើយព្រះរាជអាជ្ញាវិញថាមិនមានកម្រិតអប្បបរមាអីទេ។ អ៊ីចឹងយើងយោងទៅនឹងសាលក្រមរបស់ សេលីជីក។ ក្នុងរឿងក្ដីនេះត្រូវតែឲ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មនោះគឺទ្រង់ទ្រាយធំ គឺនៅក្នុងរឿងក្ដីនេះគឺផ្ដល់ប្រភពជាច្រើន នៅក្នុងសាលារណាយើងគឺមានបញ្ជាក់លម្អិត។

ចំណុចផ្សេងទៀតដែលយើងត្រូវតែបង្ហាញថាមានអំពើប្រល័យពូជសាសន៍ហ្នឹងគឺថាមិនចាំបាច់បង្ហាញថា ត្រូវបង្ហាញលក្ខខណ្ឌមួយចំនួនដែលថាគាត់នៅក្នុងជាសមាជិកក្រុមនុ៎ង។ នៅក្នុងរបាយការណ៍និយាយអំពីការបង្ការ ហើយនិងការដាក់ទណ្ឌកម្ម ដូច្នេះត្រូវគិតអំពីចំនួនទាំងអស់។ ហើយចំណុចទាំងអស់នេះគឺអត់មានបានលើកឡើង អត់បានគិតទេ នៅចំពោះខេត្តសៀមរាបហ្នឹង គឺចំនួនសរុបនៃជនរងគ្រោះនោះ ហើយក៏មិនបានមានចេតនារើសអើងរបស់ ខៀវ សំផន ផង ហើយនិងការធ្វើទុក្ខបុកម្នេញផង អំពើប្រល័យពូជសាសន៍ផង។ អ៊ីចឹងវាជាចំណុចសំខាន់ណាស់ពីព្រោះថាវាមានភាពមិនស៊ីសង្វាក់គ្នានឹងចេតនាប្រយោល ដូចដែលមានលើកឡើងដោយសហឧក្រិដ្ឋកម្មរួម ដែលកំណត់ដោយសាលាដំបូងនោះ ហើយយើងនឹងត្រលប់មកនិយាយពីចំណុចនេះឡើងវិញនៅពេលក្រោយ ក៏ប៉ុន្តែយើងសុំរំឭកថា សាលាដំបូងបានទទួលស្គាល់នៅក្នុងសាលក្រមរបស់ខ្លួនថា វាជាការ ជាសំខាន់ណាស់ក្នុងការបង្ហាញ

ពីទំនួលខុសត្រូវ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ ដូចគ្នាដែរទាក់ទងនឹងអំពើប្រល័យពូជសាសន៍ជនជាប់ចោទត្រូវតែមានចេតនាផ្ទាល់ ហើយនិងចេតនារើសអើងហ្នឹងក៏ត្រូវតែបង្ហាញឲ្យឃើញថាមានដែរ។ អង្គជំនុំជម្រះបានរំឭកផងដែរនៅកថាខណ្ឌ៦៩៣ របស់ខ្លួនក្នុងសំណុំរឿង០២/០១ នេះ ចេតនាពិសេសត្រូវតែបង្ហាញឲ្យមានទាក់ទងនឹងឧក្រិដ្ឋកម្មទាំងអស់នេះ មិនត្រូវគ្នានឹងចេតនាប្រយោលនោះទេ ហើយយើងនឹងត្រឡប់មកនិយាយពីចំណុចនេះ នៅពេលដែលយើងនិយាយអំពីសហឧក្រិដ្ឋកម្មរួម។

[១០:៥៦:៤៨]

ឥឡូវនេះ ខ្ញុំនឹងចូលទៅនិយាយអំពីបញ្ហាប្រឆាំងនឹងមនុស្សជាតិក្រោមអំពើអមនុស្សធម៌ដទៃទៀត ហើយនិងលើកឡើងបណ្ដឹងឧទ្ធរណ៍របស់យើងហ្នឹង គឺថានៅឆ្នាំ១៩៧៥-៧៩ ការរៀបការដោយបង្ខំ ហើយនិងការរំលោភសេពសន្ថវៈហ្នឹង មិនត្រូវបានចាត់ទុកថាជាអំពើអមនុស្សធម៌ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនោះទេ។ អង្គជំនុំជម្រះយល់ច្រឡំដោយមិនអនុវត្តតាមលក្ខខណ្ឌតម្រូវនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅសម័យនោះ។

ខ្ញុំយោងទៅសារណាបណ្ដឹងឧទ្ធរណ៍របស់យើងខ្ញុំ ដូច្នេះអង្គហេតុដែលមានកម្រិតធ្ងន់ធ្ងរដែលបានរៀបរាប់នេះ គឺថា គឺជាធាតុផ្សំអត្តនោម័តិពាក់ព័ន្ធទៅកម្រិតនៃការឈឺចាប់។ ខ្ញុំនឹងសង្កត់ធ្ងន់ទៅលើធាតុផ្សំសត្យានុម័ត -- សុំទោស ធាតុផ្សំអត្តនោម័តិ។ យើងនិយាយអំពីការវិភាគ នៅក្នុងសំណុំរឿង ០០២/០១ តុលាការកំពូលបានរំឭក គឺឯកសារ F36 កថាខណ្ឌ៥៧៦ តុលាការកំពូល បាននិយាយថានៅឆ្នាំ៧៥ ហ្នឹង គឺថាអំពើអមនុស្សធម៌ផ្សេងទៀតហ្នឹងចាត់ទុកថាជាអំពើនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ យើងៗឯកភាពលើចំណុចនេះ គឺថាវាមិនមានភាពមិនច្បាស់លាស់ទេ។ តុលាការកំពូល បន្ទាប់មកទៀតរំឭកអំពីចេតនាធម្មជាតិនៃបញ្ហានេះ មុននឹងប្រកាសថាដើម្បីឲ្យស្របទៅនឹងគោលការណ៍នៃនីត្យានុកូលភាព សញ្ញាណនេះត្រូវតែបកស្រាយ និងអនុវត្តធ្វើយ៉ាងណាឲ្យកម្រិតវិសាលភាព ពីព្រោះវាធ្វើនេះដើម្បីធានានូវសិទ្ធិ។ បន្ទាប់មកទៀត អង្គជំនុំជម្រះតុលាការកំពូលនិយាយអំពីធាតុផ្សំនៃឧក្រិដ្ឋកម្ម គឺធាតុផ្សំអត្តនោម័តិដែលវាមានកើតមាន ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ដូច្នេះវាមិនមែនត្រឹមតែជាការពិនិត្យនីត្យានុកូលភាពនៃប្រភេទផ្សេងៗនៃឧក្រិដ្ឋកម្មជាទូទៅ ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានធ្វើនោះទេ។ ដូចដែលសហព្រះរាជអាជ្ញា និងដើមបណ្ដឹងបាននិយាយនោះទេ គឺត្រូវតែពិនិត្យនីត្យានុកូលភាពនៃការបកស្រាយទៅលើនិយមន័យទាំងអស់នេះ។

[១១:០០:២៥]

តុលាការកំពូលក៏បានបញ្ជាក់ពីចំណុចនេះនៅក្នុងសាលដីការបស់ខ្លួនផងដែរ ពីព្រោះថាអង្គជំនុំជម្រះតុលាការកំពូលបានបង្ហាញអំពីភស្ដុតាងពាក់ព័ន្ធទៅនឹងច្បាប់អន្តរជាតិ។ តុលាការកំពូលបានប្រកាសថា ជាទូទៅសកម្មភាពអមនុស្សធម៌ដែលមានកម្រិតខ្លាំងដែលវាប៉ះពាល់ទៅដល់កម្រិតនៃអំពើអមនុស្សធម៌ហ្នឹងវារំលោភទៅលើគោលការណ៍ទូទៅនៃសិទ្ធិមនុស្ស ហើយការហាមឃាត់នូវអំពើអមនុស្សធម៌ទាំងអស់នោះ គឺត្រូវតែមានការចែងឡើងយ៉ាងច្បាស់។

សហព្រះរាជអាជ្ញា និងដើមបណ្ដឹងធ្វើប្រហែសអំពីផ្នែកដ៏សំខាន់មួយនេះ គឺថាធ្វើយ៉ាងម៉េចឲ្យមានការកំណត់អត្តសញ្ញាណនៃអំពើឃោរឃៅ។ ដូច្នេះវាជាចំណុចពីរផ្សេងគ្នា សហព្រះរាជអាជ្ញា និងដើមបណ្ដឹងគឺថាគាត់មើលចំណុចទាំងពីរហ្នឹងមិនត្រឹមត្រូវទេ ក៏ប៉ុន្តែអ្វីដែលតុលាការកំពូលបានរំឭកនោះគឺអំពីលក្ខខណ្ឌនៃអនីត្យានុកូលភាព យើងត្រូវស្វែងរកនូវតុល្យភាព គឺថាយ៉ាងម៉េច? គឺថាយើងមិនត្រូវកាត់បន្ថយកម្រិតធ្ងន់ធ្ងរនៃអំពើអមនុស្សធម៌នោះទេ ប៉ុន្តែយើងក៏មិនត្រូវកាត់បន្ថយវត្តមាននៃគោលការណ៍នីត្យានុកូលភាពពាក់ព័ន្ធនឹងអំពើអមនុស្សធម៌នេះផងដែរ។ ចំណុចនេះហើយជាចំណុចដែលមានការធ្វេសប្រហែស ឬក៏បដិសេធដោយសហព្រះរាជអាជ្ញា និងដើមបណ្ដឹងរដ្ឋប្បវេណីនោះ។ តាមពិតផ្ទុយពីអ្វីដែលសហព្រះរាជអាជ្ញានិយាយនោះ អ្វីដែលតុលាការកំពូលបានរំឭកអំពីលក្ខខណ្ឌអនីត្យានុកូលភាពផ្លូវការនោះ គឺជាការកំណត់នូវការវិភាគទៅលើអំពើអមនុស្សធម៌ផ្សេងទៀតដែលផ្អែកទៅលើយុត្តិសាស្ត្រអន្តរជាតិ។ នេះវាការសមហេតុផល បញ្ជីនៃការវិភាគនេះវាស្ថិតនៅក្នុងសេចក្ដីសម្រេចរបស់សហចៅក្រមអន្តរជាតិ ដែលយើងបានលើកឡើងរួចមកហើយនៅក្នុងក្របខ័ណ្ឌនៃសារណាបណ្ដឹងសាទុក្ខរបស់យើង គឺកថាខណ្ឌ៦៧០, ១១០៤, ១១១០ និង១១១៥ នៃសារណារបស់យើងដែលជាបញ្ជីវិភាគដែលសហព្រះរាជអាជ្ញា និងដើមបណ្ដឹងមិនអើពើនៅក្នុងចម្លើយរបស់ខ្លួន។ ដូច្នេះ ខ្ញុំសូមបញ្ជាក់ថាតុលាការកំពូលមិនប្រើពាក្យដូចគ្នា។ ខ្ញុំនឹងនិយាយអំពីទឡ្ហីករណ៍របស់សហចៅក្រមស៊ើបអង្កេតអន្តរ-ជាតិនៅពេលក្រោយ។

[១១:០៣:៤០]

សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញសេចក្ដីសម្រេចពាក់ព័ន្ធទៅនឹងសំណើសុំបំពេញកិច្ចពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្ម ហើយគាត់បានរំឭកថា មិនបានបង្ហាញថាអំពើហ្នឹងវាកើតឡើងនៅក្នុងចន្លោះឆ្នាំ៧៥-៧៩ ទេ គឺនៅក្នុងកថាខណ្ឌ៤៦ នៃដីការបស់ខ្លួន។ បន្ទាប់មកទៀត កថាខណ្ឌ៤៨ គឺបានរំឭកអំពីធាតុផ្សំនៃឧក្រិដ្ឋកម្មដែលមានចរិត និងលក្ខណៈធ្ងន់ធ្ងរ ប្រហាក់ប្រហែលទៅនឹងអំពើដែលបាន

រៀបរាប់នៅក្នុងកថាខណ្ឌ៤៨។ កថាខណ្ឌ៤៩ គឺបញ្ជាក់ថា យុត្តិសាស្ត្រអន្តរជាតិ បង្ហាញថាតុលាការអន្តរជាតិហ្នឹងព្យាយាមបង្ហាញដើម្បីកំណត់អំពីចរិតលក្ខណៈនៃអកប្បកិរិយារបស់ជនល្មើស ស្របទៅតាមបទដ្ឋានអន្តរជាតិ ពាក់ព័ន្ធទៅនឹងសិទ្ធិមនុស្ស ដើម្បីកំណត់ឲ្យឃើញថា មានកម្រិតនៃការតម្រូវដែរឬទេ ដើម្បីបង្កើតបានទៅជាអំពើអមនុស្សធម៌ផ្សេងទៀត។ នៅកថាខណ្ឌ៥០ គឺយើងត្រូវបញ្ជាក់អំពីដំណើរការនៃការប្រុងប្រយ័ត្នខ្ពស់ ដើម្បីធានានូវគោលការណ៍នីត្យានុកូលភាព និងការបកស្រាយច្បាប់ព្រហ្មទណ្ឌដោយតឹងរ៉ឹង ដែលមានភាពអំណោយផលទៅដល់ជនជាប់ចោទ។ គឺត្រូវរកប៉ារ៉ាម៉ែត្រជាក់លាក់ដើម្បីកម្រិតនូវអំពើជាក់លាក់ដែលស្ថិតនៅក្នុងកម្រិតនៃឧក្រិដ្ឋកម្មនោះ។ ដូច្នេះយើងត្រូវរកឲ្យឃើញនូវកម្រិតនៃការប្រមើលមើល និងការព្យាករណ៍បាន។ នៅក្នុងកថាខណ្ឌ៥២ ដល់ ៦២ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានវិភាគយ៉ាងវែង ដែលអាចឲ្យយើងសន្និដ្ឋានបាននៅកថាខណ្ឌ៦៤ ថាមានវិធាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ សហចៅក្រមស៊ើបអង្កេតបានយកមកធ្វើជារបស់ខ្លួននូវទឡ្ហីករណ៍ទាំងអស់នេះ ដើម្បីពិនិត្យមើលថា តើនៅចន្លោះឆ្នាំ៧៥ និង ៧៩ មាននិយមន័យទូលំទូលាយដែលត្រូវបានទទួលស្គាល់ដែរឬទេ ដោយការមានផ្ទៃពោះដោយការបង្ខំនេះ? តើវាមានកំណត់បានថាជាអំពើអមនុស្សធម៌ផ្សេងទៀតដែរឬទេ ការធ្វើឲ្យមានការផ្ទៃពោះដោយបង្ខំនេះ? ដូច្នេះសហចៅក្រមស៊ើបអង្កេតបាននិយាយថា មិនមានអថិភាពនៃឧក្រិដ្ឋកម្មនេះទេ នៅចន្លោះឆ្នាំ៧៥ ដល់ ឆ្នាំ៧៩។

សហចៅក្រមបានពិនិត្យទៅលើលិខិតតូបករណ៍អន្តរជាតិនៅសម័យនោះ ហើយក៏បានធ្វើការស្រាវជ្រាវទៅលើឧក្រិដ្ឋកម្មទាំងអស់នេះ។ ក៏បានពិនិត្យមើលច្បាប់ជាតិ និងការវិវត្តន៍នាពេលបច្ចុប្បន្ន ហើយសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសន្និដ្ឋានថា ដោយសារតែមិនមានការដាក់ទណ្ឌកម្មទៅកម្ពុជា ក៏ដូចជានៅប្រទេសនានាគឺៗយើងមិនអាចគិតថាវាជាឧក្រិដ្ឋកម្មបានទេ។ ដូច្នេះ គាត់សន្និដ្ឋាននៅកថាខណ្ឌ៧៤ ថាមិនមានភស្តុតាងគ្រប់គ្រាន់បំពាក់ -- ដែលមិនបង្ហាញអំពីការអនុវត្តជាទូទៅរបស់រដ្ឋដើម្បីបង្ហាញថា តើការរំលោភទៅលើស្វ័យភាព រំលោភទៅលើសិទ្ធិរបស់មនុស្សនេះវាពិតជាឧក្រិដ្ឋកម្មមែនដែរឬទេ នៅក្នុងចន្លោះឆ្នាំ៧៥ ដល់ ឆ្នាំ៧៩ នោះ?

[១១:០៧:៥៧]

នេះជាដំណើរការនៃការពិនិត្យហ្មត់ចត់របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលស្របទៅនឹងអ្វីដែលតុលាការកំពូលបានបញ្ជាក់ថា វាជាយន្តការនៅក្នុងការពិនិត្យមើលនូវអំពើអមនុស្សធម៌ផ្សេងទៀត។ ដូច្នេះ ក្នុងអំពើអមនុស្សធម៌ផ្សេងទៀតយើងត្រូវតែកំណត់នូវក្របខ័ណ្ឌឲ្យច្បាស់លាស់ ហើយ

បង្កើតនូវវិធានច្បាប់អន្តរជាតិនៃទំនៀមទម្លាប់ ដែលបានអនុវត្តនៅសម័យនោះ។ ជាពិសេសការអនុវត្ត ជាពិសេសការហាមឃាត់របស់តុលាការកំពូលពាក់ព័ន្ធទៅនឹងចំណុចនេះ។

ដូច្នេះការត្រឹមតែបង្ហាញអំពីការរំលោភ និងកម្រិតធ្ងន់ធ្ងរហ្នឹងក៏វាមិនគ្រប់គ្រាន់ទេ ថ្វីត្បិតតែប្រភេទនៃអំពើអមនុស្សធម៌ផ្សេងទៀតនេះគឺជាប្រភេទដែលច្របូកច្របល់រួមគ្នា ក៏ប៉ុន្តែការរំលោភទៅលើសិទ្ធិមនុស្សហ្នឹងអត់មាននៅក្នុងហ្នឹងទេ អ៊ីចឹងហើយវាចាំបាច់ត្រូវតែពិនិត្យឲ្យបានហ្មត់ចត់នៅចំពោះមុខតុលាការអន្តរជាតិផ្សេងទៀត។ ខ្ញុំសូមរំឭកនូវយុត្តិសាស្ត្រនៅក្នុងប្រភពរបស់យើងហ្នឹងគឺថា នៅក្នុងសាលដីកាស៊ីវិច ដីកាដំណោះស្រាយ អ៊ឹម ចែម ត្រូវនឹងសេចក្តីសម្រេចមួយរបស់អង្គបុរេជំនុំជម្រះ គឺ D267/1/8 វាមាននៅក្នុងប្រភពឯកសាររបស់យើងហើយ ដូច្នេះវាមានសារៈសំខាន់នៅក្នុងការអនុវត្តបញ្ជីនៃការវិភាគទាំងអស់ហ្នឹងសម្រាប់ឆ្នាំ១៩៧៥ ដល់ ១៩៧៩ ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តនៃអំពើរៀបការដោយបង្ខំ និងការរំលោភសេពសន្ថវៈ ដែល -- តើវាអាចគិតថាជាអំពើអមនុស្សធម៌ផ្សេងទៀតដែរឬទេ នៅក្នុងសម័យនោះ? ដូច្នេះ លក្ខខណ្ឌនៃអនីត្យានុកូលភាពជាផ្លូវការមិនអាចបង្កើតបានទេ ដោយសារតែវាមានវិធានច្បាប់។

[១១:១០:១៨]

សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយតបដោយផ្តោតទៅលើលិខិតតូបករណ៍អន្តរជាតិស្តីពីសិទ្ធិមនុស្ស និងសិទ្ធិអំពីគ្រួសារ។ សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីបានបង្ហាញអំពីលិខិតតូបករណ៍សិទ្ធិមនុស្សអន្តរជាតិមួយចំនួនផងដែរ។ ក៏ប៉ុន្តែបើយើងពិនិត្យមើលបរិបទឲ្យបានច្បាស់លាស់នោះ ការគ្រាន់តែបង្ហាញអំពីការគោរពសិទ្ធិស្តីពីគ្រួសារហ្នឹងគឺវាមិនគ្រប់គ្រាន់ទេ អ៊ីចឹងហើយវាមិនអាចបង្ហាញថា វាជាធាតុផ្សំនៃអំពើអមនុស្សធម៌ផ្សេងទៀតនៅក្នុងឆ្នាំ១៩៧៥ ទេ។ នេះជាចំណុចដែលយើងបានដាក់នៅក្នុងប្រភពថ្មីរបស់យើង គឺមានសេចក្តីប្រកាសរបស់សភាជាតិអាមេរិកដែលបង្ហាញផ្ទុយពីនេះទៅវិញ។ ដែលមានការបែងចែកនូវការគោរពសិទ្ធិ និងការហាមឃាត់នៅសម័យនោះ នៅឆ្នាំ៧៤ ហ្នឹងគឺវាសារៈសំខាន់ដែរ។ តើសេចក្តីប្រកាសហ្នឹងនិយាយយ៉ាងម៉េចរបស់មហាសន្និបាតអង្គការសហប្រជាជាតិនេះ? អ្នកណាដែលគេត្រូវផ្តន្ទាទោស ឬក៏ជាឧក្រិដ្ឋជននោះនៅកថាខណ្ឌ១, ២, ៤ និង ៥ នោះ គេនិយាយពីអ្វី? គឺនិយាយអំពី -- គឺការវាយប្រហារទៅលើប្រជាជនស៊ីវិលប្រើប្រាស់គ្រាប់បែក ប្រើប្រាស់អាវុធគីមី អាវុធជីវសាស្ត្រ ហើយមានការធ្វើទារុណកម្ម ការឃុំឃាំង ការសម្លាប់ ការបំផ្លាញផ្ទះសម្បែង ការប៉ះពាល់ទៅដល់សិទ្ធិមនុស្ស ការប៉ះពាល់ទៅដល់គ្រួសារ។

ខ្ញុំសូមរំឭកផងដែរថានៅអន្តរជាតិ ការអនុវត្តហ្នឹងគឺមិនអាចបង្ហាញអំពីវិធាននៃគោលការណ៍ច្បាប់ទំនៀមទម្លាប់អន្តរជាតិបានទេ នេះមានបញ្ជាក់នៅក្នុងសាលដីកា០០២/០១។ ខ្ញុំសូមយោងទៅសាលដីកា ឌុច កថាខណ្ឌ៩៦ ការសិក្សាច្បាប់ជាតិរបស់សហព្រះរាជអាជ្ញាបង្ហាញអំពីការអនុវត្តនៃការដាក់ទណ្ឌកម្មដែលវាមានតិចតួច មិនមានការបង្ហាញអំពីច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅសម័យនោះទេ។ ច្បាប់កម្ពុជា ជាពិសេសនោះគឺមិនបានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ អំពីលក្ខខណ្ឌនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំទេ នេះជាចំណុចមួយដែលយើងត្រូវតែលើកឡើង។ យើងពិនិត្យមើលក្រមរដ្ឋប្បវេណីនៅឆ្នាំ១៩២០ ផងដែរ គឺថាវាត្រូវតែមានអាទិភាពនៃការយល់ព្រម ការព្រមព្រៀងគ្នា។

[១១:១៤:០៦]

សហព្រះរាជអាជ្ញានិងដើមបណ្តឹងគឺគាត់លើកឡើងចំណុចនេះគឺវាត្រឹមត្រូវ ប៉ុន្តែវាគ្រាន់តែលើកឡើងអ៊ីចឹងមិនគ្រប់គ្រាន់ទេ។ គឺយើងនិយាយអ៊ីចឹងគឺថាវាជាការបង្ក្រាបការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនោះគឺវាមិនត្រឹមត្រូវទេ បរិបទវប្បធម៌នៃការរៀបអាពាហ៍ពិពាហ៍ដោយការផ្សំផ្គុំហ្នឹងគឺថា វាមានសារៈសំខាន់ណាស់ ដែលយើងត្រូវតែលើកឡើង។ មកដល់ថ្ងៃហ្នឹងហើយនេះ ២០២១ ហើយនេះ មិនមានការចែងអំពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងច្បាប់កម្ពុជាទេ។ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំហ្នឹងគឺថា វាមិនមែនជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទេ ទោះបីជាមានលក្ខខណ្ឌយ៉ាងណានៃសិទ្ធិមនុស្សក៏ដោយគឺនៅពេលបច្ចុប្បន្នហ្នឹងឆ្នាំ២០២១ ទៅហើយហ្នឹងក៏អត់មានចែងដែរនៅក្នុងច្បាប់កម្ពុជាហ្នឹងថា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំហ្នឹងគឺជាឧក្រិដ្ឋកម្មនោះ។ ដូច្នេះអ្វីដែលខ្ញុំបានលើកឡើងលម្អិតហ្នឹង យើងមិនអាចសន្និដ្ឋានថា មានអំពើអមនុស្សធម៌ផ្សេងទៀតក្នុងទម្រង់ជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំទេ។ ដោយសារតែការរៀបអាពិពាហ៍ពិពាហ៍ដោយបង្ខំនៅឆ្នាំ៧៥ និង៧៩ នោះ មិនអាចបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ស្ថិតនៅក្នុងប្រភេទសំណល់នេះ។ ហើយការអំពើហិង្សាផ្លូវភេទនៅក្នុងការរៀបអាពាហ៍ពិពាហ៍ហ្នឹងក៏វាអត់មានដែរ។ អ៊ីចឹងយើងត្រូវតែច្បាស់ទាំងអស់គ្នា។ យើងមិនដែលនិយាយទេ ហើយយើងមើលប្រតិចារឹកទៅ ប្រតិចារឹកសវនាការបញ្ជាក់ច្បាស់ហើយ យើងមិនដែលនិយាយថា អាពាហ៍ពិពាហ៍ដោយបង្ខំនោះគឺជាការរំលោភសិទ្ធិមនុស្ស។ សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីគាត់និយាយម៉េចនិយាយទៅ តែយើង យើងមិនដែលនិយាយអ៊ីចឹងទេ។ អ្វីដែលយើងនិយាយគឺថា នៅពេលដែលកើតអង្គហេតុនោះ អំពើហ្នឹងវាមិនមានប្រភេទ វាមិនមានលក្ខណៈ និងមានភាពធ្ងន់ធ្ងរដូចជាអំពើអមនុស្សធម៌ ហើយវាមិនអាចទៅចាត់ទុកថាឧក្រិដ្ឋកម្មប្រឆាំង

មនុស្សជាតិបានទេ។ ដូច្នេះវាមានចរិតលក្ខណៈផ្សេងទៀត ដូចជាការរួមដំណេក ហ្នឹងវាជារឿងធម្មតាហើយ។ កាលណារៀបការ ត្រូវតែមានការរួមដំណេកហើយ។

[១១:១៦:៥៥]

ដូច្នេះជំហរនៅក្នុងដីកាដំណោះស្រាយហ្នឹងយ៉ាងម៉េច? ថាតើការរំលោភសេពសន្ថវៈហ្នឹងត្រូវបានចាត់ទុកយ៉ាងម៉េចដោយបក្សកុម្មុនីស្តកម្ពុជា? កថាខណ្ឌ១៤២៩ នៃដីកាដំណោះស្រាយហ្នឹង គឺនិយាយអំពីគោលនយោបាយបក្ខកុម្មុនីស្តកម្ពុជាពាក់ព័ន្ធនឹងការរំលោភសេពសន្ថវៈហ្នឹងគឺថា ដើម្បីដាក់ទោសទៅលើជនល្មើស។ ការរំលោភសពសន្ថវៈហ្នឹង វាមិនមែនជាការប្រើដើម្បីសម្រេចផែនការរួមទេ គោលដៅរួមទេ។ នេះគឺជាអ្វីដែលរំឭកជាច្រើនដងច្រើនសាហើយនៅក្នុងសវនាការនៃតុលាការនេះ។ ហើយសាក្សី ពែរប៉ុងសូដ៍ ហ្នឹងគាត់បានផ្តល់សក្ខីកម្មទៅលើចំណុចទាំងអស់នេះដែរ។ ដូច្នេះអំពើហិង្សាផ្លូវភេទ និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនេះ ទោះបីជាក្នុងពេលថ្លែងបើក ឬនៅក្នុងនៅពេលណាមួយ ឬក៏នៅក្នុងសវនាការបឋមក៏ដោយនោះ គឺថាអំពើហិង្សាការរំលោភសេពសន្ថវៈនោះ គឺវាមិនអាចកាត់ផ្តាច់ចេញបានពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំទេ។ ដូច្នេះមានន័យថា បើការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំមិនមែនជាអំពើអមនុស្សធម៌ផ្សេងទៀតនោះ ការរួមដំណេកដែលកើតចេញពីការរៀបអាពាហ៍ពិពាហ៍ហ្នឹងក៏យើងមិនអាចចាត់ទុកថាជាអំពើអមនុស្សធម៌ផ្សេងទៀតបានដែរ។ ដូច្នេះ វាមិនពាក់ព័ន្ធនឹងការឈឺចាប់របស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលបានលើកឡើងនៅក្នុងសវនាការនេះទេ។ យើងគ្រាន់តែចង់លើកឡើងត្រង់ចំណុចនេះទៅឲ្យអង្គជំនុំជម្រះតុលាការកំពូលពិចារណា។

បរិបទវប្បធម៌គឺមានសារៈសំខាន់ណាស់ បរិបទនេះហើយដែលវាពន្យល់នៅក្នុងសវនាការនេះ ថាយើងបានស្តាប់ឮអ្នកដែលបានរៀបការនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យហ្នឹង គឺគាត់នៅតែរស់នៅជាមួយប្តីប្រពន្ធគាត់ដដែលមកដល់សព្វថ្ងៃនេះ។ ខ្ញុំសូមនិយាយអំពីសក្ខីកម្មរបស់លោកស្រី ផេក ឡឺរិន ដែលគាត់និយាយថា នៅម៉ោង ០៩:១០នាទី ពាក្យ "បង្ខំ"ហ្នឹង បានក្លាយទៅជាពាក្យមួយដែល អ.វ.ត.ក ហ្នឹងតែងតែលើកយកមកនិយាយ ហើយធ្វើឲ្យមានការអាម៉ាស់។ ពួកគេគឺចង់ដឹងថាអ៊ីចេះ តើពេលដែលនិយាយអំពីអាពាហ៍ពិពាហ៍ដោយបង្ខំហ្នឹងនៅជាសាធារណៈហ្នឹង តើវាយ៉ាងម៉េច? នេះគឺជាការវិភាគមួយផងដែរ។ នេះគឺជាចំណុចសំខាន់ដែលខ្ញុំត្រូវលើកឡើង។

[១១:២០:១៨]

ទឡ្ហីករណ៍នៅក្នុងសារណារបស់យើងហ្នឹង គឺកាន់តែមានន័យខ្លឹមសារទៀត ប៉ុន្តែខ្ញុំមានពេលក្នុង

ការនិយាយឱ្យបានវែងឆ្ងាយទេ។ សូមពិនិត្យមើលនៅក្នុងសារណាបណ្តឹងសាទុក្ខរបស់យើង គឺពាក់ព័ន្ធទៅនឹងអង្គហេតុដែលមានកម្រិតធ្ងន់ធ្ងរ ដូចគ្នានឹងអំពើអមនុស្សធម៌ផ្សេងទៀតដែលបានរៀបរាប់ ជាពិសេសចេតនាក្នុងការបង្កនូវការឈឺចាប់ធ្ងន់ធ្ងរ ដែលយើងនឹងត្រឡប់មកនិយាយម្តងទៀត នៅពេលដែលនិយាយអំពីទំនួលខុសត្រូវរបស់លោក ខៀវ សំផន។ ប៉ុន្តែនៅពេលនេះខ្ញុំសូមយោងទៅកថាខណ្ឌ ១១៦៦ ដោយសារតែខ្ញុំឃើញថាម៉ោងខ្ញុំជិតអស់ទៅហើយ ខ្ញុំសូមឆ្លើយតបទៅនឹងសំណួររបស់តុលាការកំពូលនៅកថាខណ្ឌ៣២ នៃរបាយការណ៍របស់ចៅក្រម ដើម្បីបង្ហាញថា យើងមិនបានលើកឡើងអំពីបញ្ហាបកប្រែនៅក្នុងមូលដ្ឋានបណ្តឹងសាទុក្ខរបស់យើងទៅលើបញ្ហានៃការជម្លៀសជនជាតិវៀតណាម។

សូមអភ័យទោស ខ្ញុំច្រឡំសំណួរហ្នឹងហើយ គឺបញ្ហាពាក់ព័ន្ធនឹងការជម្លៀសជនជាតិវៀតណាមនៅត្រាំកក់ យើងបានលើកឡើងនូវបញ្ហា គឺពាក់ព័ន្ធនឹងភាពយុត្តិធម៌នៃយុត្តិនីតិ -- នីតិវិធី គឺនៅកថាខណ្ឌ ១១៥។ នៅពេលដែលបញ្ហាបកប្រែត្រូវបានលើកឡើងនៅក្នុងពេលជជែកដេញដោលនោះ យើងៗបានពិនិត្យឃើញហើយថា មានបញ្ហាដែរ ពេលខ្លះមាននៅក្នុងភាសាបារាំងទៅ ពេលខ្លះក៏អត់មាន។ អ៊ីចឹងនៅក្នុងសាលក្រមនោះ អង្គជំនុំជម្រះគឺគាត់យល់ដែរ ដូច្នេះយើងមិនបានលើកឡើងពាក់ព័ន្ធនឹងបញ្ហាហ្នឹងទេ គ្រាន់តែយើងបញ្ជាក់ថា នៅពេលដែលយើងទទួលស្គាល់ថាមានបញ្ហាដែលគេមិនទទួលយកតាំងពីដំបូង ហើយបន្ទាប់មកមានការទទួលស្គាល់ថាមានការមានកំហុសបកប្រែនោះ។ អ៊ីចឹងហើយបានជាយើងលើកនៅក្នុងសារណារបស់យើងលើចំណុចនេះនោះ។

ពាក់ព័ន្ធនឹងបញ្ហាបន្ទប់មកទៀត គឺការធ្វើឱ្យក្លាយជាទាសករនៅក្នុងភ្នំក្រោល ហើយនិងការធ្វើទារុណកម្មនៅទ្រា ខ្ញុំសូមយោងទៅកថាខណ្ឌ១៣៧២ នៅក្នុងសារណារបស់យើង ដែលយើងបង្ហាញពីវិសាលភាពនៃបណ្តឹងពាក់ព័ន្ធនឹងភ្នំក្រោល។ ហើយអង្គជំនុំជម្រះបានយល់ច្រឡំថា ក-១១ ហ្នឹងវាគ្របដណ្តប់ទៅលើភ្នំក្រោលផងដែរ ហើយដីកាដំណោះស្រាយបានបញ្ជាក់ច្បាស់ហើយថាការធ្វើឱ្យក្លាយជាទាសករហ្នឹងគឺមានតែនៅក-១១ ទេ។ មានការវិភាគមិនត្រឹមត្រូវទៅលើភស្តុតាងដែលអង្គជំនុំជម្រះសាលាដំបូង ពីព្រោះសាលាដំបូងបានបញ្ជាក់ថា មានការបញ្ជាក់អះអាង -- អង្គជំនុំជម្រះបានបញ្ជាក់ថាកំណត់ហេតុរបស់ អ៊ំ ណាល នោះគឺថា បញ្ជាក់ច្បាស់អំពីសក្ខីកម្មនៅក្នុងសវនាការរបស់ ហួរ ណែម។ ដូច្នេះយើងអាចនិយាយបានថាវាមិនមានភាពស៊ីសង្វាក់ ឬមិនមានការគាំទ្រពីភស្តុតាង។ នេះគឺជាកំហុសដែលយើងបានរកឃើញ។ ហើយដោយសារតែយើងមិនអាចសួរដើមបណ្តឹងរដ្ឋប្បវេណីបានគាត់និយាយពីភ្នំក្រោលនុំងតែពេលដែលគាត់ថ្លែងអំពីទុក្ខសោកតែប៉ុណ្ណោះ។ យើងមិនអាចសួរអីគាត់

បានទេ។ អ៊ីចឹងពេលនុ៎ងគឺថាយើង -- វាកំហុសយើងដែរអ៊ីចឹង។ ហើយអង្គជំនុំជម្រះបានបំភ្លៃបំប្លែងសម្ដីរបស់ដើមបណ្ដឹងនេះ ថាគាត់ត្រូវបានគេឃុំ។ កថាខណ្ឌ៣៩៣ ខ្ញុំសូមអាននូវការសន្និដ្ឋានរបស់អង្គជំនុំជម្រះ "ដើមបណ្ដឹងនេះត្រូវបានសួរទៅលើលក្ខខណ្ឌការងារក៏ដោយ ក៏អង្គជំនុំជម្រះសន្និដ្ឋានថាការបញ្ជូនគាត់ទៅក-១១ ហ្នឹង គឺថាបង្ហាញថាគាត់ពិតជាត្រូវបានឃុំឃាំងនៅទីនោះមែន"។ នេះគឺជាការប្រើសក្ខីកម្មមិនត្រឹមត្រូវរបស់ គល់ ណែម។ គល់ ណែម គាត់មិនដែលនិយាយថាគាត់គេឃុំនៅក-១១ ទេ។ គាត់មិនត្រូវបានឃុំនៅក-១១ ទេ គាត់គ្រាន់តែនិយាយថាគេចាត់តាំងគាត់ទៅទីនុ៎ង មិនមែនឃុំទេ។

[១១:២៥:៥៧]

ខ្ញុំសូមយោងទៅសក្ខីកម្មរបស់ គល់ ណែម E1/488.1 ដែលគាត់និយាយថា គឺនៅម៉ោង ១៤:២៨ ដល់ ២៩៖ "គេឲ្យខ្ញុំទៅក-១១ ហ្នឹង ទៅយក ទៅដឹកអង្ករ។ ហើយពេលនុ៎ង គេរៀបឲ្យខ្ញុំរៀបការ"។ អ៊ីចឹងគាត់ហ្នឹង គេហៅមកហ្នឹង គឺហៅមកនិយាយអំពីអាពាហ៍ពិពាហ៍ដោយបង្ខំ ហើយអង្គជំនុំជម្រះហ្នឹងប្រើអង្គហេតុ ប្រើសក្ខីកម្មរបស់គាត់ហ្នឹងទៅលើអង្គហេតុទាំងមូលតែម្ដងនៅលើសំណុំរឿង០០២/០២។ ប្រសិនបើ គល់ ណែម និយាយអំពីលក្ខខណ្ឌការងារលំបាកក៏ដោយ ក៏គាត់មិននិយាយអំពីពេលម៉ោងធ្វើការទេ។ ហើយគាត់ក៏អត់និយាយអំពីការឃុំខ្លួនគាត់ដែរ។ គាត់អត់និយាយថាគាត់ជាអ្នកទោសទេ ដែលខុសពីសក្ខីកម្មរបស់ អ៊ំ ម៉ុល។ ខ្ញុំសូមយោងទៅសារណាបណ្ដឹងសាទុក្ខរបស់យើងត្រង់ចំណុចនេះ។ ម៉ោងខ្ញុំអស់មែនទែនហើយ។ អ៊ីចឹង យើងគ្រាន់តែនិយាយថាធាតុផ្សំហ្នឹងវាមិនគ្រប់គ្រាន់ទេ ពាក់ព័ន្ធនឹងជនជាតិចាមនុ៎ង។ អ៊ីចឹងសូមពិនិត្យមើលនូវសារណាបណ្ដឹងសាទុក្ខរបស់យើងកថាខណ្ឌ៩២៥ ដែលយើងបានពន្យល់អំពីការប្រកាសទោសពាក់ព័ន្ធនឹងភូមិទ្រា គឺមិនគ្រាន់ទេ គ្រាន់តែយកសាក្សីម្នាក់មកនិយាយអ៊ីចឹង ហើយទាញការផ្ដន្ទាទោសនោះ។ អ៊ីចឹងខ្ញុំសូមបញ្ចប់ត្រឹមហ្នឹងហើយ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងយើងបានដល់ម៉ោងសម្រាកបាយថ្ងៃត្រង់ហើយ។ អ៊ីចឹងខ្ញុំសូមជម្រាបជូនថា នៅល្ងាចនេះគឺយើងនឹងចាប់ផ្ដើមនៅវេលាម៉ោងដប់បី និងសាមសិបនាទី។ ដូច្នេះ សូមមន្ត្រីពន្ធនាគារនាំជនជាប់ចោទទៅកន្លែងសម្រាកវិញ ហើយនិងនាំមកវិញហ្នឹងគឺនៅម៉ោងដប់បី និងម្ភៃនាទី។ អ៊ីចឹងតុលាការប្រកាសសម្រាក។

*(សវនាការសម្រាកពីម៉ោង ១១:២៨ នាទី ដល់ម៉ោង ១៣:៣០ នាទី)*

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

អង្គជំនុំជម្រះតុលាការកំពូលប្រកាសតសវនាការ។ លោកក្រឡាបញ្ជី តើភាគី និងមេធាវីបានមកគ្រប់ចំនួនហើយឬនៅ?

**ក្រឡាបញ្ជី៖**

បាទ សូមគោរពឯកឧត្តមប្រធាន។ សូមគោរពអង្គក្រុមប្រឹក្សាជំនុំជម្រះ។ ភាគីមានវត្តមានគ្រប់ហើយបាទ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងសូមអញ្ជើញសហព្រះរាជអាជ្ញាធ្វើសារណា។

**លោកស្រី ហេឡេន វើសនុប៖**

ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម។ ទី១ ខ្ញុំសូមនិយាយពាក់ព័ន្ធទៅនឹងការជំទាស់តវ៉ារបស់មេធាវីពាក់ព័ន្ធទៅនឹងការសម្លាប់ជនជាតិវៀតណាម។ ឯកសារដែលបានដាក់ជូនគឺសម្រាប់អង្គជំនុំជម្រះធ្វើការបកស្រាយ។ ដូចខ្ញុំបានលើកឡើងលម្អិតនៅក្នុងសារណារបស់យើងខ្ញុំ មូលដ្ឋានទី៦ អង្គជំនុំជម្រះបានសម្រេចយ៉ាងត្រឹមត្រូវទៅលើទីតាំងភូមិសាស្ត្រពាក់ព័ន្ធទៅនឹងការសម្លាប់ជនជាតិវៀតណាមនៅទូទាំងប្រទេស ដូចដែលម្ចាស់បណ្តឹងឧទ្ធរណ៍បានយល់ស្របនៅក្នុងផ្នែកពាក់ព័ន្ធស្តីពីឧក្រិដ្ឋកម្ម ការសម្លាប់នៅក្រៅព្រៃវែង និងស្វាយរៀង។ នៅក្នុង -- ដែលស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង០០២ គឺមានមន្ទីរសន្តិសុខ ស-២១ អូរកន្សែង និងក្រាំងតាចាន់។ ចំណុចនេះ គឺពាក់ព័ន្ធទៅនឹងអំពើប្រល័យពូជសាសន៍ ការសម្លាប់រង្គាល និងការធ្វើបាបជនជាតិវៀតណាម។ នៅក្នុងផ្នែកដូចគ្នានេះដែរ អង្គជំនុំជម្រះបានបញ្ជាក់ថា ហេតុអ្វីបានជាមានការសម្លាប់នៅខាងក្រៅទីតាំងភូមិសាស្ត្រទាំងនោះ។ សាលាដំបូងបានចេញសេចក្តីសម្រេចនៅក្នុងរឿងក្តីនេះ គាត់បានលើកឡើងអំពីការសម្លាប់ និងដោយយោងទៅលើការប្រព្រឹត្តទៅលើជនជាតិវៀតណាម ដោយមិនមានកម្រិត។ ហើយយោងទៅលើកថាខណ្ឌទាំងអស់នៅក្នុងដីកាដំណោះស្រាយដែលបានរកឃើញការសម្លាប់ជនជាតិវៀតណាមនៅខាងក្រៅខេត្តព្រៃវែង និងខេត្តស្វាយរៀង។

[១៣:៣៣:៥១]

ឥឡូវខ្ញុំសុំនិយាយអំពីការលើកឡើងថា អង្គជំនុំជម្រះមានកំហុសក្នុងការសម្រេចអំពីការសម្លាប់ក៏ដូចជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ទៅតាមរយៈការបង្ខំឱ្យរៀបការ និងការរំលោភសេពសន្ថវៈ។ ឥឡូវនេះខ្ញុំសូមលើកធ្វើការកត់សម្គាល់ពីរចំណុច អំពើមនុស្សឃាត ការធ្វើទុក្ខបុកម្នេញ និងអំពើអមនុស្សធម៌គឺជាបញ្ហានៅក្នុងសំណុំរឿង០០១ និងសំណុំរឿង០០២/១។ អង្គជំនុំជម្រះតុលាការកំពូលក៏បានធ្វើការស្រាវជ្រាវអង្កេតពីមុនឆ្នាំ២០១៥ ស្តីពីច្បាប់ដែលមានមុនឆ្នាំ១៩៧៥ និងយុត្តិសាស្ត្រ ហើយក៏បានពិនិត្យ និងក៏បានច្រានចោលនូវទឡ្ហីករណ៍ដែលម្ចាស់បណ្តឹងឧទ្ធរណ៍បានលើកឡើងនៅពេលនេះ។ មិនមានអ្វីនៅក្នុងបណ្តឹងសាទុក្ខនេះគឺថា ផ្តល់ហេតុផលដែលធ្វើឱ្យការកែប្រែសេចក្តីសម្រេចនេះ។

ទី២ ទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងទាក់ទងទៅនឹងស្ថានភាពនៃច្បាប់នៅក្នុងឆ្នាំ១៩៧៥ ដែលមានធ្វើការច្របូកច្របល់ពាក់ព័ន្ធទៅនឹងអង្គហេតុជាក់លាក់មួយចំនួន នេះគឺដោយសារតែវាធាតុចេតនា ឬក៏ធាតុសត្យានុម័ត ដែលមាននៅក្នុងអង្គហេតុទាំងអស់នេះ។ មានភស្តុតាងគ្រប់គ្រាន់ដែលធ្វើឱ្យតុលាការទទួលយកនៅក្នុងលក្ខខណ្ឌមួយកម្រិតទៀត ជាពិសេសដោយសារតែអវត្តមានយុត្តិសាស្ត្រផ្ទុយគ្នានេះ។ ឥឡូវខ្ញុំសូមនិយាយអំពីអំពើមនុស្សឃាត។ ជាពិសេស ម្ចាស់បណ្តឹងឧទ្ធរណ៍ធ្វើការជំទាស់នោះ គឺមិនបានបង្កើតទៅជា ច្បាប់ព្រហ្មទណ្ឌអន្តរជាតិនៅឆ្នាំ៧៥ ទេ។ ដូចដែលលោកចៅក្រមបានលើកឡើងរួចមកហើយ ភាពទទួលយកបាន និងការអាចប្រមើលទុកមុនបាន ដែលបានរកឃើញនៅក្នុងសំណុំរឿង០០២/១។ អង្គជំនុំជម្រះបានបង្ហាញនៅក្នុងករណី*មេឌីកាល់* គឺនិយាយអំពីតុលាការសហរដ្ឋអាមេរិកនៅក្នុងទីក្រុងនូរីមប៊ឺក បានធ្វើការផ្តន្ទាទោសដោយសម្អាងទៅលើធាតុចេតនា។ ហើយយើងក៏បានបញ្ជាក់ផងដែរថា យើងមិនបានដឹងពីរឿងនេះទេ។ ហេតុដូច្នេះ ច្បាប់ទំនៀមទំលាប់អន្តរជាតិត្រូវបានដោះស្រាយមិនមានលក្ខខណ្ឌណាដែលសម្រាប់ឱ្យអង្គជំនុំជម្រះសាលាដំបូង ឬក៏តុលាការកំពូលនេះ បង្ហាញអំពីគោលការណ៍ទូទៅនៅក្នុងច្បាប់ជាតិនោះទេ។ ក៏ប៉ុន្តែដើម្បីធានាឱ្យចំណុចទាំងពីរហ្នឹង អង្គជំនុំជម្រះទាំងពីរ ថាមិនមានចេតនាដោយផ្ទាល់ ដែលតម្រូវឱ្យមានភាពស៊ីសង្វាក់គ្នាទៅនឹងប្រព័ន្ធច្បាប់ជាតិនោះទេ។ ក្រោយពីអង្គជំនុំជម្រះ បន្ថែមយុត្តាធិការមកលើការយល់ឃើញរបស់ខ្លួន គឺថាមាន អង្គជំនុំជម្រះបានបញ្ជាក់ថា ភស្តុតាងនេះ គឺវាមានភាពជាក់លាក់យ៉ាងខ្លាំង ហើយគោលការណ៍ទូទៅនៅក្នុងអង្គហេតុក៏កើតមានដែរ។ អ៊ីចឹងក្នុងសារណារបស់យើងខ្ញុំនេះ គឺមានឧទាហរណ៍ជាច្រើន។ អ៊ីចឹងគ្មានអ្វីដែលយល់ទេនៅឆ្នាំ៧៥ រដ្ឋបានទទួលយកនូវនិយមន័យនៃការសម្លាប់ក្រៅផ្លូវច្បាប់ ដែលក្នុងនោះក៏មានរួមបញ្ចូល

ទាំងការ -- បណ្ដាលឲ្យមានការស្លាប់នោះដែរ។

[១៣:៣៧:២០]

ហើយផ្ទុយទៅនឹងការជំទាស់តវ៉ារបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍ -- បណ្ដឹងសាទុក្ខ សាលាដំបូងក៏បានអនុវត្តយ៉ាងបំត្រឹមត្រូវទៅលើគោលការណ៍ធាតុចេតនាជារួមនេះ។ អង្គជំនុំជម្រះបានលើកឡើងថា ចារីនេះ គឺបានប្រព្រឹត្តដោយមានការ សុំដកស្រង់៖ "យល់ដឹងយ៉ាងខ្លាំងដែលអំពើរបស់គាត់ហ្នឹងអាចនាំឲ្យមានការស្លាប់ប្រជាជនជាច្រើន។ ហើយការបញ្ជាក់នេះ ក៏មាននៅក្នុងសាលក្រមទាំងពីរ ហើយអង្គជំនុំជម្រះកំពូលក៏បានបញ្ជាក់ថា ផ្នែកនីមួយៗនេះគឺក្រៅរកឃើញថាវាមានធាតុចេតនានៅក្នុងនោះហើយ"។ តាមពិតទៅគឺថា ឧទាហរណ៍ ប្រសិនបើសិនយើងធ្វើអំពើណាមួយដោយដឹងអំពីភវនីយភាពនៃការបណ្ដាលឲ្យស្លាប់មនុស្សហ្នឹង អ៊ីចឹងយើងទទួលយកហានិភ័យនេះហើយ។ ស្រដៀងគ្នាដែរ ការទទួលយកហានិភ័យនៃលទ្ធភាពអាចបណ្ដាលឲ្យមានការស្លាប់បាន នោះគឺថាយើងនឹងដឹងពីលទ្ធភាពដែលអាចកើតឡើងនោះហើយ។

ឥឡូវខ្ញុំសូមចូលទៅលើការជំទាស់តវ៉ារបស់ម្ចាស់បណ្ដឹងសាទុក្ខអំពីអំពើមនុស្សឃាត ហើយមិនបានបង្ហាញអំពីកាតព្វកិច្ចដែលត្រូវបំពេញទេ ដើម្បីបញ្ជាក់ឲ្យច្បាស់អ្វីដែលអង្គជំនុំជម្រះបានរកឃើញនោះ គឺស្ថានភាពដែលនៅការដ្ឋាន ក៏ដូចសហករណ៍នោះ បណ្ដាលឲ្យមានការស្លាប់មកលើជនរងគ្រោះ ហើយធ្វើឲ្យមាន ឬដោយមិនមានការសម្រាលទៅដល់ស្ថានភាពណាមួយឡើយ។ ដូច្នេះអ្វីដែលម្ចាស់បណ្ដឹងសាទុក្ខលើកឡើងគឺការធ្វេសប្រហែលការខកខាន អវត្តមាននូវវិធានការសមស្របដើម្បីសម្រាលទៅដល់ស្ថានភាពដែលអាជ្ញាធរកម្ពុជាប្រជាធិបតេយ្យខ្លួនឯងបានដាក់អនុវត្តមកលើប្រជាជន។ មានន័យថា ពួកគេបន្តនូវសកម្មភាពវិជ្ជមានរបស់ខ្លួន ទោះជាយ៉ាងណាក៏ដោយ ទោះបីជាគាត់មានការជំទាស់តវ៉ានេះក៏ដោយ ម្ចាស់បណ្ដឹងសាទុក្ខ ប៉ុន្តែខកខានមិនបានបង្ហាញទេ។ វាមានការច្បាស់ហើយគឺថា ពួកគាត់មិនមានជំហរណាមួយ កែប្រែជំហររបស់ខ្លួន។ ហេតុដូច្នេះ សាលាឧទ្ធរណ៍នៃតុលាការ អាយ.ស៊ី.ធី.វ៉ាយ ក្នុងរឿងក្ដី ស្ដីបប៊ីស៊ី នេះក៏បានពន្យល់ដូច្នេះឯង។ ឥឡូវនិយាយទៅដល់ការធ្វើទុក្ខបុកម្នេញ ទី១ ខ្ញុំនិយាយអំពីធាតុចេតនាដែលបានការប្រព្រឹត្តមកលើជនជាតិចាម និងជនជាតិវៀតណាមដែលមានការរើសអើងដោយផ្ទាល់តែម្ដង។

[១៣:៤០:០០]

ចំណុចនេះ គឺស្ថានភាពនិងគោលនយោបាយដែលអនុវត្ត -- គោលនយោបាយ ឬច្បាប់ដែលអនុវត្ត

គ្រប់ មនុស្សទាំងអស់។ ម្ចាស់បណ្ដឹងសាទុក្ខ គឺធ្វើការចោទប្រកាន់មិនត្រឹមត្រូវថា ចំណុចនេះមិនបង្កើតបានទៅជាការរើសអើងនោះទេ ហើយ -- មិនបានបង្កើតទៅជាការរើសអើងនៅក្នុងច្បាប់១៩៧៥ទេ។ អង្គជំនុំជម្រះក៏បានបង្ហាញរួចមកហើយ ថាជំហររបស់ម្ចាស់បណ្ដឹងសាទុក្ខគឺមានកំហុស។ នៅក្នុងសាលដីកានៅក្នុងសំណុំរឿង០០១ គឺមានការសិក្សាស្រាវជ្រាវអំពីច្បាប់មុនឆ្នាំ១៩៧៥ និយាយអំពីការរើសអើងនេះ ថាតើវាពិតជាមានផលវិបាកដោយសារតែការរើសអើងសម្រាប់សមាជិកនៃក្រុមណាមួយ ឬក៏ជនរងគ្រោះត្រូវបានកំណត់ជាគោលដៅណាមួយដែរឬក៏អត់។ តាមរយៈទស្សនៈរបស់គាត់ ម្ចាស់បណ្ដឹងសាទុក្ខនេះ គឺគាត់ត្រូវធ្វើការបំភ្លៃ។ កាលណាគេនិយាយពីការធ្វើទុក្ខម្នេញ គេនិយាយអំពីការបៀតបៀន ការគាបសង្កត់ ឬក៏ចំណុចណាមួយទៅលើក្រុមណាមួយជាក់លាក់។ ដូច្នេះ ជនរងគ្រោះទទួលរងគ្រោះនូវការរើសអើងដោយសារតែគាត់ជាពុទ្ធសាសនិក ឬក៏ជាចាម។ នេះគឺមិនមានការពាក់ព័ន្ធដែលថា បើសិនណាជាជនជាតិចាម គេបង្ខំឲ្យហូបសាច់ជ្រូក ឬក៏ប្រឈមការអត់ឃ្លាន គឺថាពួកគាត់មានការឈឺចាប់ ទទួលរងនូវការឈឺចាប់ ដែលគាត់មិនធ្លាប់មានបទពិសោធន៍ដោយសារតែពួកខ្មែរក្រហមបង្ខំហើយ។ អ្វីដែលមានបញ្ហា គឺនិយាយអំពីផលប៉ះពាល់នៃគោលនយោបាយ មិនមែនតែពាក្យសម្ដីនោះទេ ជួនកាលយល់ឃើញអំពីការរើសអើងដែលមាននៅមុនឆ្នាំ១៩៧៥ ដូចបានបង្ហាញតាមរយៈអនុសញ្ញា ក៏ដូចយុត្តិសាស្ត្រដែលលើកឡើងដោយដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសារណារបស់ពួកគេ។ អ៊ីចឹងតាមរយៈតុលាការអចិន្ត្រៃយ៍អន្តរជាតិនៅក្នុងឆ្នាំ១៩២៣ ឆ្នាំ១៩៣២ និង១៩៣៥ បានរកឃើញថាដើម្បីឲ្យវាមានប្រសិទ្ធភាពបំផុតនោះ គឺការហាមឃាត់ប្រឆាំងនឹងការរើសអើង គឺត្រូវតែធ្វើម៉េចធានាថាកុំឲ្យមានការរើសអើង ក៏ដូចជានៅក្នុងច្បាប់នោះផងដែរ។ តុលាការទាំងនោះបានពន្យល់អំពីការប្រព្រឹត្តមកលើ ក្រុមណាមួយនៅក្នុងស្ថានភាពលក្ខខណ្ឌណាមួយដែលបណ្ដាលឲ្យពួកគាត់មិនមានសមភាព។

[១៣:៤២:២៦]

ឥឡូវខ្ញុំនិយាយទៅលើធាតុចេតនាដែលមាននៅក្នុងមូលដ្ឋានបណ្ដឹងសាទុក្ខ៩៤។ មិនមានអ្វីនៅក្នុងច្បាប់ ឬនៅក្នុងតុលាការ ឬក៏ថាយុត្តិសាស្ត្រមុនសង្គ្រាមលោកលើក -- ក្រោយសង្គ្រាមលោកលើកទី២ ឬក៏តុលាការអចិន្ត្រៃយ៍ដែលគាំទ្រទៅដល់ជំហរថា ធាតុចេតនាសម្រាប់ការធ្វើទុក្ខបុកម្នេញតម្រូវឲ្យមានលើពីត្រឹមតែចេតនាដើម្បីមានការរើសអើងទៅលើក្រុមណាមួយ។

ឥឡូវនិយាយអំពីនៅក្នុងសង្គមកម្ពុជាតែម្ដង។ ជាថ្មីម្ដងទៀត អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់នៅក្នុងសំណុំរឿង០០១ ហើយថា ហើយម្ដងទៀតម្ចាស់បណ្ដឹងសាទុក្ខច្រឡំទៅលើអង្គហេតុ និង

អង្គច្បាប់ ការធ្វើទុក្ខបុកម្នេញ គឺថាវា គឺវារីករាលដាលគ្រប់ពេលវេលាបណ្តាលឲ្យមានចេតនាទៅលើសង្គមទាំងមូលតែម្តង។ និយាយអំពីអង្គហេតុនៅក្នុងរឿងក្តីជាច្រើននៅតុលាការអន្តរជាតិ។ ប៉ុន្តែចំណុចនេះវាមិនមែនជាផ្នែកមួយនៃតេស្តផ្លូវច្បាប់នោះទេ។ ឧទាហរណ៍ នៅតុលាការក្រោយសង្គ្រាមលោកលើកទី២ តែងតែរកឃើញជនជាតិជីហ្វហ្នឹងត្រូវបានទទួលរងការធ្វើទុក្ខបុកម្នេញតាមរយៈអង្គហេតុដែលមិនបានបង្ហាញអំពីធាតុចេតនាដើម្បីដកហូតពួកគេចេញពីសង្គម។ ហើយការធ្វើទុកបុកម្នេញទៅលើជនជាតិយួន តុលាការអន្តរជាតិនេះបានពន្យល់អំពីការញែកដាច់ពីគ្នាច្បាស់។ ខ្ញុំសុំដកស្រង់៖ ដោយការឡើងដណ្តើមកាន់អំណាចនៅក្នុងឆ្នាំ១៩៣៣ ការធ្វើទុក្ខបុកម្នេញលើជនជាតិជីហ្វត្រូវមានភាពតឹងតែងឡើង។ មានមានការរើសអើង -- មានច្បាប់ៗរឹតបន្តឹងការរើសអើង គឺត្រូវបានអនុម័ត ត្រូវបានអនុវត្តមកលើជនជាតិជីហ្វ។

នៅខែ *អុកតូប* ឆ្នាំ១៩៣៨ គោលនយោបាយប្រឆាំងមកលើពួកណាស៊ី គឺថាមកលើជនជាតិជីហ្វហ្នឹងគឺគ្មានគោលបំណងប្រព្រឹត្តផ្ទាល់មកលើជនជាតិជីហ្វពីសំណាក់ជនជាតិអាល្លឺម៉ង់។

[១៣:៤៤:៤៦]

ឥឡូវនិយាយអំពីអមនុស្សធម៌។ ចុងក្រោយ គឺថាឧក្រិដ្ឋកម្មដែលមានមូលដ្ឋាន៩៧ ដែលត្រូវកំណត់ដោយច្បាប់ជាតិ អន្តរជាតិ។ មិនមានអ្វីត្រូវបានយកមកពិភាក្សាដោយអង្គជំនុំជម្រះមួយៗ អ.វ.ត.ក ឬក៏តុលាការអាដហុកនោះទេ ក៏ប៉ុន្តែម្ចាស់បណ្តឹងសាទុក្ខខ្លួនគាត់បានធ្វើការទទួលយក *(ឮមិនច្បាស់)* គ្រប់គ្រាន់ដែលបានបង្ហាញថា គឺវាអាចប្រមើលមើលទៅបាន អាចគិតឃើញទៅបានថា នឹងត្រូវទទួលរងនូវការផ្តន្ទាទោសពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឆ្នាំ៧៥ ហើយពិសេសពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មក្នុងឆ្នាំ១៩៧៥។ ហើយតាមចេតនារបស់ខ្លួនដែលត្រូវបានប្រើប្រាស់ដើម្បី -- ហើយគាត់ដឹងថាគាត់នឹងអាចទទួលរងនូវការទទួលខុសត្រូវព្រហ្មទណ្ឌពាក់ព័ន្ធទៅនឹងស្ថានភាពនៃអំពើអមនុស្សធម៌ និងលក្ខណៈដែលមានភាពស្រដៀងគ្នា ក៏ដូចស្ថានទម្ងន់។

[១៣:៤៥:៤៧]

ឥឡូវនេះខ្ញុំចូលនិយាយអំពីមូលដ្ឋាន៩៨។ ក្នុងសាលដីកាសំណុំរឿង០០២/០១ តុលាការកំពូលបានបង្ហាញមកហើយថា គឺត្រូវតែមានការធានាឲ្យមានគោលការណ៍នីត្យានុកូលភាពគ្រប់ភាគីទាំងអស់។ អង្គជំនុំជម្រះបានពន្យល់ថាចំណុចនេះតម្រូវឲ្យ -- ដែលចំណុចនេះគឺមានទាក់ទងនឹងអំពើអមនុស្សធម៌ ដូចដែលខ្ញុំបាន ដូចដែលបានកំណត់នៅក្រោមលិខិតូបករណ៍ច្បាប់អន្តរជាតិ។ ហើយនេះគឺជាអ្វីដែល

ជំនុំជម្រះសាលាដំបូងបានសម្រេចដូច្នោះមែន។ អ្វីដែលអង្គជំនុំជម្រះមិនតម្រូវនោះគឺថា ផ្នែកជាក់លាក់នីមួយៗមិនមែនគ្រាន់តែមិនមានភាពខុសគ្នាខាងផ្លូវច្បាប់រវាងសិទ្ធិ ហើយនិងការហាមឃាត់នៅក្នុងច្បាប់សិទ្ធិមនុស្សនោះទេ--

**អ្នកបកប្រែ៖**

លោកប្រធានសុំការអនុញ្ញាត ខ្ញុំមិនអាចតាមទាន់ទេ លោកប្រធាន ញាប់ពេក។

**លោកស្រី ហេឡេន វើសនុប៖**

ឥឡូវនិយាយអំពីការរៀបការដោយបង្ខំ និងការរំលោភសេពសន្ថវៈ។ គោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ ពាក់ព័ន្ធទៅនឹងការរៀបការដោយបង្ខំ និងការបង្ខំឱ្យរួមភេទនោះ។ ខ្ញុំនឹងលើកឡើងអំពីចំណុចអង្គច្បាប់។ ពាក់ព័ន្ធទៅនឹងសារណារបស់បណ្ដឹងសាទុក្ខលើកឡើងនៅក្នុងមូលដ្ឋាន ១៦០, ១៧១ និង ១៧២។ ហើយសហការីរបស់ខ្ញុំ រូថ ម៉ារី ហេគ្គ័រ គឺថានឹងពិភាក្សាលើអង្គហេតុទាំងឡាយនេះ។ ម្ចាស់បណ្ដឹងសាទុក្ខបានដឹងអំពីច្បាប់ស្ដីអំពីអំពើអមនុស្សធម៌ហើយ ឯអង្គជំនុំជម្រះតម្រូវឱ្យ -- ប្រសិនបើសម្រុកឃើញមានថាអំពើដែលមានលក្ខណៈស្រដៀងគ្នានឹងស្ថានទម្ងន់ដែលរៀបរាប់នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្ស -- ដែលមាននៅក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការរំលោភសិទ្ធិជាមូលដ្ឋាន។ ការបង្ខំឱ្យរៀបការគ្មានអ្វីឆ្ងល់ទេ គឺជាការរំលោភទៅលើសិទ្ធិមនុស្សហើយដែលបានលើកឡើងយ៉ាងច្បាស់នៅក្នុងលិខិតតូបករណ៍អន្តរជាតិនៅឆ្នាំ៧៥។ សាលាដំបូងជ្រើសរើសសម្រេចលើកយកឧទាហរណ៍មួយដែលជាមូលដ្ឋានដ៏សំខាន់។ ម្ចាស់បណ្ដឹងសាទុក្ខគឺថា អះអាងមិនត្រឹមត្រូវទេដែលថាគាត់ៗ -- ហើយឱ្យបញ្ជីដ៏វែងឆ្ងាយ តទៅទៀតនៅក្នុងសារណាឆ្លើយតបរបស់យើងខ្ញុំ កម្ពុជានឹងបានទទួលយកនូវអនុសញ្ញាបំពេញបន្ថែម ស្ដីអំពីការលុបបំបាត់អំពើទាសករនៅក្នុងខែមិថុនាឆ្នាំ១៩៥៧ មាត្រា១ ថា ភាគីទាំងអស់យល់ព្រមដាក់ឱ្យនៅក្រៅច្បាប់រួម ក្នុងនោះរួមមានគឺថា មិនត្រូវមាន អនុញ្ញាតឱ្យមានសិទ្ធិណាមួយបដិសេធ ឬក៏យ៉ាងណានោះទេ។ ហើយបន្ទាប់មកឆ្នាំ៦២ អនុសញ្ញាស្ដីអំពីការយល់ព្រមរៀបការ និងនៅក្នុងកម្រិតអាយុអប្បបរមាដែលត្រូវតែមានការយល់ស្រប ការយល់ព្រមពីភាគីទាំងពីរ។

[១៣:៤៨:៥២]

ចំណុចមួយទៀត ថាតើការបង្ខំឱ្យរៀបការនោះមានចរិតលក្ខណៈដូចគ្នាយ៉ាងម៉េចដែរ? យើងខ្ញុំនឹងនិយាយអំពីការបង្ខំឱ្យរៀបការនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ ខ្ញុំនឹងលើកឡើងចំណុចសង្ខេប

ពីរ។ ទី១ ខ្ញុំយោងទៅលើសាលក្រមមកពីតុលាការ អេស.ស៊ី.អេស.អិល និង តុលាការ អាយ.ស៊ី.ស៊ី សាលាដំបូងបានបង្ហាញឲ្យឃើញថា តុលាការទាំងពីរបានរកឃើញនៅក្នុងគោលការណ៍ទូទៅអំពីការបង្ខំឲ្យបុគ្គលណាម្នាក់រៀបការនៅក្នុងលក្ខណៈដូចគ្នា ឬក៏ក្នុងស្ថានទម្ងន់ណាមួយ។ ទី២ ខ្ញុំសូមបដិសេធពាក់ព័ន្ធទៅនឹងអ្វីដែលលើកឡើង របស់ម្ចាស់បណ្តឹងឧទ្ធរណ៍ទាក់ទងនឹងការបង្ខំឲ្យរៀបការនៅឆ្នាំ៧៥។ ក្រៅពីអង្គហេតុដែលថាការកំណត់ទោសទណ្ឌព្រហ្មទណ្ឌដោយច្បាប់ជាតិនោះ គឺជាគេស្តផ្អែកផ្លូវច្បាប់មួយ គាត់ធ្វើការលាបពណ៌រូបភាពនៃការបង្ខំឲ្យរៀបការចាប់ផ្តើមនៅថ្ងៃទី២៦ -- នៅសតវត្សរ៍ទី២១។ ហើយការៗរៀបការ ការផ្សំផ្គុំរៀបការវាខុសពីការរៀបការដោយបង្ខំក្នុងរូបភាពជាច្រើន ហើយដោយការធ្វើបែបនេះ ម្ចាស់បណ្តឹងសាទុក្ខនេះគាត់ធ្វើការបំភ្លៃយ៉ាងខ្លាំង ដែលថាការបង្ខំឲ្យរៀបការនេះ គឺពិតជាកើតមានយ៉ាង -- ពិតជាមានមែននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ក្នុងចម្លើយតបទាំងនោះ យើងលើកឡើងចំណុចទី៧ យុត្តាធិការនិយាយអំពីការរៀបការដោយបង្ខំ គឺត្រូវតែមានទោសព្រហ្មទណ្ឌហើយ។

ឥឡូវខ្ញុំនិយាយអំពីពាក់ព័ន្ធទៅនឹង បាហាម៉ុស សាយព្រើស និងម៉ាឡេស៊ី ក៏ដូចជារដ្ឋអ៊ិក្លាហូម៉ា យើងឥឡូវនេះគឺថាសុំបន្ថែមក្នុងនោះមានបន្ថែមទាំងប្រទេសអង់គ្លេស ប្រទេសញូហ្សេលែន ប្រទេសស៊ូម៉ា និងប្រទេសអូស្ត្រាលីនៅរដ្ឋតាស្មានា និងអូស្ត្រាលីខាងត្បូងគិរីប៉ាទី ប្រទេសប៊្រុយណេ សហរដ្ឋអាមេរិកកាលីហ្វ័រញ៉ា លើសពីអ្វីទាំងនេះគឺថាវាច្បាស់ហើយ គឺថាប្រទេសទាំងនេះមានប្រពៃណីក្នុងការរៀបចំផ្គុំផ្គូរផ្គងអាពាហ៍ពិពាហ៍។ ម្ចាស់បណ្តឹងសាទុក្ខ -- ប្រទេសនៅក្នុងប្រទេសអាស៊ីអាគ្នេយ៍ តែៗម្តង ថាក្នុងមានប្រទេស១០ ដែលមានការផ្សំផ្គុំឲ្យរៀបការបាន ទៅបាននៅឆ្នាំ៧៥ នោះ។

[១៣:៥១:៤១]

អ៊ីចឹងការផ្តន្ទាទោសចំពោះអំពើអមនុស្សធម៌ តាមរយៈការបង្ខំឲ្យរៀបការដោយបង្ខំអាចប្រមើលមើលបានហើយនៅក្នុងឆ្នាំ១៩៧៥។ បើទោះបីជាជនរងគ្រោះជាប្រភេទស្រីក៏ដោយ អង្គជំនុំជម្រះបានរកឃើញថា នេះគឺវាជាអំពើមួយបង្កើតបានទៅជាការរំលោភសេពសន្ថវៈហើយ។ ប៉ុន្តែមិនមាន -- ដោយមិនបាននៅរៀបរាប់នូវពាក្យពេចន៍ឲ្យច្បាស់លាស់ អ៊ីចឹងការរំលោភសេពសន្ថវៈគឺពិតជាត្រឹមត្រូវហើយ ពិតជាមានមែន។

អ៊ីចឹងទី១ វារំលោភទៅលើសិទ្ធិមនុស្ស ទី២ គឺវា -- យើងត្រូវបង្ហាញនូវលក្ខខណ្ឌមួយស្តីអំពីស្ថានទម្ងន់។ យើងទទួលស្គាល់ថា សាលាដំបូងខកខានមិនបានប៉ាន់ប្រមាណអំពីលក្ខខណ្ឌដំបូងនេះ ប៉ុន្តែ

យើង តាមពិតទៅគ្រប់តុលាការប្រទេសស៊ីវិល័យទាំងអស់គឺថា ខ្ញុំៗសូមលើកឡើងអំពីច្បាប់អន្តរជាតិ ខ្ញុំគួរតែផ្អាកត្រឹមប៉ុណ្ណេះ ជំហរនេះវាច្បាស់ហើយ ក៏ប៉ុន្តែម្ចាស់បណ្ដឹងឧទ្ធរណ៍ជំទាស់តវ៉ាថាមិនមានការបង្ខំឲ្យរួមសេពសន្ថវៈនៅក្នុងអាពាហ៍ពិពាហ៍នោះទេ។ ធ្វើទីនេះ អ៊ីចឹងយើង -- ថាតើមានការផ្ដន្ទាទោសព្រហ្មទណ្ឌដែលបង្ខំឲ្យប្រជាជនកម្ពុជារាប់ពាន់នាក់រៀបការប្រឆាំងទៅនឹងឆន្ទៈរបស់ខ្លួន ហើយបន្ទាប់មកបង្ខំឲ្យពួកគេរួមភេទជាមួយគ្នា ដោយមានការតាមដានឃ្លាំមើលពីរយៈកងឈ្លបរបស់ខ្លួន ដែលធ្វើឲ្យមានការភ័យខ្លាច ហើយរហូតដល់មានការដាក់ផ្ដន្ទា -- ប្រហារជីវិតទៀត សម្លាប់ចោលទៀត បើមិនរួមភេទ។

អ៊ីចឹងជំហររបស់គាត់នេះគឺមិនអាចប្រកែកបានទេ។ ការរំលោភសេពសន្ថវៈមិនជារឿងមួយដែលត្រូវស្រប -- មិនស្របច្បាប់ទេ ត្រូវតែមានការរៀបការត្រូវតែមានការយល់ស្របគ្នា។ ទី១ គាត់គឺបុរសម្នាក់ហ្នឹងគាត់គឺត្រូវបាន -- គាត់មិនមែនជាអ្នករំលោភសេពសន្ថវៈ តែគាត់គេបង្ខំឲ្យគាត់រំលោភសេពសន្ថវៈ។ តាមពិតទៅមិនមានមូលដ្ឋានអ្វីខុសគ្នារវាងគោលនយោបាយរបស់ ប.ក.ក និងហាក់បីដូចជាចាត់ទុកថាជាការបង្ខំឲ្យដូចជាស្រីបម្រើផ្លូវភេទយ៉ាងដូច្នេះដែរ។ ចំណុចនេះបានលើកឡើងនៅក្នុងអនុសញ្ញាអន្តរជាតិជាច្រើននៅឆ្នាំ១៩៧៥ ហើយចំណុចនេះបានបញ្ជាក់នៅក្នុងលក្ខន្តិកៈ និងយុត្តិសាស្ត្រនៃតុលាការ អាយ.ស៊ី.ធី.វ៉ាយ, អាយ.ស៊ី.ស៊ី និងតុលាការ អេស.ស៊ី.អេស.អិល។

[១៣:៥៤:២២]

ទី២ មានតែមូលហេតុមួយគត់ដែលអាពាហ៍ពិពាហ៍ដោយបែបនេះគឺដោយសារតែពួកគាត់បង្ខំគាត់គឺជាជនរងគ្រោះត្រូវគេបង្ខំ។ ចុងចោទមិនអាចប្រើប្រាស់អំពើព្រហ្មទណ្ឌរបស់គាត់ដើម្បីធ្វើឲ្យអំពើគាត់នេះស្របច្បាប់ឡើងវិញទៅបានទេ។ ដោយការទទួលស្គាល់បែបនេះទាំងតុលាការ អេស.ស៊ី.អេស.អិល តុលាការ អាយ.ស៊ី.ស៊ី មានការផ្ដន្ទាទោស ការបង្ខំឲ្យរួមសេពសន្ថវៈនៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ។ យើងខ្ញុំបានពន្យល់រួចលម្អិតទៅហើយនៅក្នុងសារណាតបរបស់យើងខ្ញុំ។ អ៊ីចឹងជាគោលការណ៍ច្បាប់ហ្នឹងគឺក៏ដូចវាអាចប្រមើលមើលបាននៅឆ្នាំ៧៥ ថាការរៀបការដោយបង្ខំនេះគឺជាអាពាហ៍ពិពាហ៍មួយមិនស្របច្បាប់ទេ ដែលរឿងនេះបង្កឲ្យមានការអំពើរំលោភសេពសន្ថវៈផ្លូវភេទ។

ឥឡូវខ្ញុំសូមជូនវេទិកាហ្នឹងទៅដល់សហការីរបស់ខ្ញុំ នីសា ប៉ាតែល។

**លោកស្រី នីសា ប៉ាតែល៖**

សូមគោរពឯកឧត្ដមប្រធាន ឯកឧត្ដម លោកជំទាវ អស់លោក លោកស្រីចៅក្រម គឺថាមានការ

ផ្តន្ទាទោសប្រាំបីឧក្រិដ្ឋកម្ម ដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ យើងនឹងជំទាស់ទៅលើឧក្រិដ្ឋកម្មនេះជាលម្អិតនៅក្នុងផ្នែក ៧ សេ, ដេ, អឺ នៃចម្លើយតបជាលាយលក្ខណ៍អក្សររបស់យើង។ ថ្ងៃនេះខ្ញុំនឹងពិភាក្សាអំពីការជំទាស់ខុសឆ្គងមួយចំនួនទាក់ទងទៅនឹងការដាក់ទៅជាទាសករ អំពើមនុស្សឃាត និងការធ្វើទុក្ខបុកម្នេញទៅលើប្រជាជនខ្មែរ ហើយ -- ទៅលើប្រជាជនថ្មី ហើយបន្ទាប់មកទៀតសហការីរបស់ខ្ញុំនឹងនិយាយអំពីការប្រព្រឹត្តទៅលើក្រុមគោលដៅ និងការគ្រប់គ្រងអាពាហ៍ពិពាហ៍។ ឥឡូវនេះ ខ្ញុំនឹងនិយាយអំពីការដាក់ទៅជាទាសករ។

[១៣:៥៦:១៦]

ប្រជាជនស៊ីវិលត្រូវបានកេងប្រវ័ញ្ចដើម្បីប្រយោជន៍របស់បក្សកុម្មុយនីស្តកម្ពុជា មិនមែនតែនៅក្នុងសហករណ៍ និងការដ្ឋានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងនៅក្នុងពេលដែលត្រូវបានឃុំខ្លួនដោយខុសច្បាប់នៅមន្ទីរសន្តិសុខ។ ប្រជាជនត្រូវបានចាត់ទុកដូចជាទំនិញ គឺបង្ខំឲ្យធ្វើការតាមកាលវិភាគដែលបានកំណត់នៅក្នុងបរិយាកាសដែលមានការភ័យខ្លាច និងការគ្រប់គ្រង។ មូលដ្ឋាន១៣៣ របស់ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថា មិនមានមូលដ្ឋានគ្រប់គ្រាន់ដើម្បីកំណត់អំពីអំពើទាសករនៅមន្ទីរសន្តិសុខភ្នំក្រោល ប៉ុន្តែពួកគាត់មិនបានគិតអំពីភស្តុតាងនៅការដ្ឋាន ក-១៧ និងគុកភ្នំក្រោលឡើយ។ ចំពោះ ក-១១ ព្រឹកនេះគាត់បានលើកទឡ្ហីករណ៍ថ្មីមួយទៀត ដែលថាអង្គជំនុំជម្រះបានសម្រេចថា គល់ នឹម ត្រូវបានឃុំនៅទីនោះ។ គាត់បានបង្ហាញអំពីចំណុចទាំងអស់នេះនៅកថាខណ្ឌ៣០១ នៃសាលក្រម ហើយចំពោះភស្តុតាងដទៃទៀតនៅចំពោះមុខសាលាដំបូងទាក់ទងទៅនឹងការប្រើប្រាស់ក-១១ នោះគឺបង្ហាញថា មិនមានកំហុសឆ្គងអ្វីឡើយ។

នៅក្នុងកថាខណ្ឌ៣០២៩ នៃសាលក្រមសាលាដំបូងបានពន្យល់ថា ក-១១ គឺជាកន្លែងឃុំឃាំង និងអប់រំរៀនសូត្រ។ អ្នកទោសក-១១ មកពីកងទ័ពដូចជា គល់ នឹម។ កថាខណ្ឌ៣០៦៧ នៃសាលក្រម គល់ នឹម បានប្រាប់សាលាដំបូងថា អ្នកនៅក្នុងកងពលរបស់គាត់ត្រូវបានគេសម្លាប់ និងធ្វើទារុណកម្ម ដោយសារតែជាកងទ័ព។ គាត់និយាយថា គាត់ត្រូវបានគេបញ្ជូនទៅ ក-១១។ ចំពោះមូលដ្ឋានដដែលម្ចាស់បណ្តឹងសាទុក្ខបានជំទាស់នៅក្នុងបណ្តឹងសាទុក្ខ ទាក់ទងទៅនឹងការប្រើប្រាស់របស់កំណត់ហេតុស្តាប់ចម្លើយរបស់ អ៊ឹំ មល គាត់ -- លោក លោកស្រីចៅក្រមមានសិទ្ធិពិនិត្យ ប៉ុន្តែគាត់ថានេះមិនមែនជាសិទ្ធិដាច់មុខនោះទេ ដូច្នេះហើយយើងអាចឃើញថាកំណត់ហេតុស្តាប់ចម្លើយអាចប្រើប្រាស់ធ្វើជាភស្តុតាងរួមទាំងនៅទីនោះផងដែរ។

[១៣:៥៨:៤៣]

ហើយទាក់ទងទៅនឹងការប្រព្រឹត្តអំពើសកម្ម ឬក៏អំពើអកម្មរបស់ម្ចាស់បណ្តឹងសាទុក្ខ បន្ថែមពីលើនេះទៅទៀត ផ្ទុយទៅនឹងការអះអាងរបស់មេធាវីការពារក្តីគឺថា កំណត់ស្តាប់ចម្លើយសាក្សីហ្នឹងមិនមែនមានតម្លៃទាបទេ ពួកគេធ្វើឡើងដោយចៅក្រមស៊ើបអង្កេតដែលឥតលម្អៀង ដោយមានការធានាយ៉ាងសមស្រប ដើម្បីធានាថាមានភាពអាចជឿជាក់បាន។

ឥឡូវនេះ ខ្ញុំនឹងនិយាយអំពីអំពើមនុស្សឃាតនៅសហករណ៍ និងការដ្ឋាន ឧក្រិដ្ឋកម្មគឺផ្អែកទៅលើការធ្វើទុក្ខបុកម្នេញ ហើយនិងការបង្ខំឱ្យធ្វើការដោយបង្ខំទាំងយប់ទាំងថ្ងៃ ដោយមិនមានការសម្រាកគ្រប់គ្រាន់ មិនមានអាហារគ្រប់គ្រាន់ ហើយមិនមានការព្យាបាល។ ស្ថានភាពការងារ និងរស់នៅដ៏អាក្រក់បែបនេះធ្វើឱ្យមានផលប៉ះពាល់ជាបុគ្គល និងជារួមទៅលើប្រជាជន ហើយបណ្តាលឱ្យមានការស្លាប់ ដោយសារជំងឺកង្វះអាហារ អស់កម្លាំង ឬក៏របួស ដោយសារការងារ។ នៅក្នុងមូលដ្ឋាន ១០៦, ១១៦ និង ១១៧ ការអាន ការបកស្រាយមួយផ្នែកៗរបស់ម្ចាស់បណ្តឹងសាទុក្ខទៅលើសាលក្រមគឺមិនបានបង្ហាញអំពីភស្តុតាងគ្រប់គ្រាន់ ដែលថា មានឧក្រិដ្ឋកម្មនៅមន្ទីរស្រុក -- នៅការដ្ឋានស្រុកត្រាំកក់ និងការដ្ឋានទំនប់១មករា។ ឧទាហរណ៍ មានភស្តុតាងហោចណាស់ប្រាំមួយក្នុងចំណោមពលករចំនួន១០នាក់បានស្លាប់ ដោយសារស្ថានភាពបែបនេះនៅទំនប់១ មករា ហើយមានការគាំទ្រដែលភស្តុតាងនៅក្នុងកថាខណ្ឌ១៥៣៥, ១៦២៦ និង ១៦២៧ នៃសាលក្រម គឺមិនមែនមានតែនៅក្នុងកថាខណ្ឌ១៦២៩ ដូចគាត់ថានោះទេ។ ប្រហែលគ្នានេះ ធាតុផ្សំអត្តនោម័តិរបស់ចារីគឺបានពិភាក្សានៅក្នុងកថាខណ្ឌចំនួន ៣៧ កថាខណ្ឌនៃសាលក្រម មិនមែនមានតែពីរកថាខណ្ឌដូចដែលគាត់លើកឡើងនោះទេ។ កថាខណ្ឌទាំងអស់នេះគឺបង្ហាញយ៉ាងច្បាស់ថាចារីបានសង្កេតឃើញ ហើយទទួលបានព័ត៌មានអំពីស្ថានភាពដ៏អាក្រក់ ហើយនិងផលវិបាកនៃស្ថានភាពអាក្រក់នេះទៅលើកម្មករ។ ប៉ុន្តែពួកគេទទួលយកហានិភ័យនៃការស្លាប់ ដោយគេរក្សាស្ថានភាពឱ្យនៅដដែល ហើយបង្គាប់ឱ្យពលករធ្វើការខ្លាំងជាងមុន ហើយគោរពទៅតាមផែនការរបស់បក្សកុម្មុនីស្តកម្ពុជា។ នៅក្នុងមូលដ្ឋាន១០២, ១១៣, ១១៧ និង ១២៣ វិញ ម្ចាស់បណ្តឹងសាទុក្ខបានបកស្រាយដោយខុសឆ្គងទៅលើការសម្រេចរបស់សាលាដំបូង ទៅលើការដ្ឋាន និងសហករណ៍បួន ដោយអះអាងថាអង្គជំនុំជម្រះមិនបានបញ្ជាក់នៅពេលដែលមានធាតុផ្សំអត្តនោម័តិរបស់ចារីផ្ទាល់នោះទេ។ នៅក្នុងការដ្ឋាននីមួយៗនៅពេលដែលយើងនិយាយអំពីដំណើរការ រយៈពេលធ្វើការងារហ្នឹងគឺថាស្ថានភាពវាអាក្រក់មែនទែន នៅពេលដែលចារីផ្ទាល់បានដាក់ -- បានកំណត់អំពី

ស្ថានភាព។ នេះគេដឹងថាប្រហែលជាអាចមានការស្លាប់របស់កម្មករហើយ។ ហើយនៅពេលដែលការស្លាប់ ពួកគេក៏នៅតែបន្តរក្សាស្ថានភាពដដែល។ ដែលការណ៍នេះបង្ហាញថាពួកគេទទួលយកលទ្ធភាពដែលថាមានមនុស្សស្លាប់ ហើយអត់ខ្វល់។ កត្តាក្រៅពីទៀតដែលម្ចាស់សាទុក្ខបានលើកឡើងថាជាកត្តាជំរុញឲ្យមានស្ថានភាពបែបនេះគឺមិនពាក់ព័ន្ធទេ ព្រោះថាធាតុផ្សំអត្តនោម័តិគឺកើតឡើងទាក់ទងទៅនឹងអំពើឧក្រិដ្ឋដោយចេតនារបស់ពួកគេ។

[១៤:០២:២៩]

នៅក្នុងមូលដ្ឋាន១៣២ ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញពីកំហុសរបស់សាលាដំបូង ដោយប្រើកំណត់ហេតុស្តាប់ចម្លើយរបស់ សុខ ឌី រួមជាមួយនឹងភស្តុតាងពាក់ព័ន្ធដទៃទៀត ដើម្បីសម្រេចថាមានការសម្លាប់អ្នកទោសដែលមានចេតនានៅមន្ទីរសន្តិសុខភ្នំក្រោល។ កត្តាផ្ទុយគ្រប់គ្រាន់គឺត្រូវបានសាលាដំបូងប្រើប្រាស់ក្នុងការវាយតម្លៃត្រឹមត្រូវ និងយុត្តិធម៌ទៅលើភាពអាចជឿជាក់បាននៃភស្តុតាងរបស់ សុខ ឌី។ មុនពេលដែលគាត់បានស្លាប់ ទី១ មានការពិនិត្យត្រឹមត្រូវទៅលើភស្តុតាងដោយ ក.ស.ច.ស តាមរយៈ -- ដែលធ្វើឡើងដោយមានសច្ចា ហើយមានការកត់ត្រាថតសំឡេងទៀត។ ទី២ គឺភស្តុតាងអំពីស្ថានភាពនៅមន្ទីរសន្តិសុខ គឺមានការគាំទ្រដោយសក្ខីកម្មផ្ទាល់បួននាក់ ហើយនិងការស្តាប់ចម្លើយ ក.ស.ច.ស ផ្សេងដទៃទៀត។ ហើយជាចុងក្រោយ ម្ចាស់បណ្តឹងសាទុក្ខមានឱកាសក្នុងការជំទាស់ទៅលើស្ថានភាពទាំងអស់ហ្នឹងនៅពេលជំនុំជម្រះ ប៉ុន្តែគាត់មិនជំទាស់នោះឡើយ។ ដោយផ្អែកទៅលើការវាយតម្លៃជារួមទៅលើភស្តុតាង ម្ចាស់បណ្តឹងសាទុក្ខមិនបានបង្ហាញថាជារឿងមិនសមស្របក្នុងការសម្រេចថាអ្នកទោសបានស្លាប់ដោយសារតែស្ថានភាពដែលអាក្រក់ ហើយប្រសិនបើសាលាដំបូងមានកំហុសក្នុងការសម្រេចហ្នឹង គឺកំហុសហ្នឹងគឺមិនបានធ្វើឲ្យប៉ះពាល់ទៅដល់ការផ្តន្ទាទោសម្ចាស់បណ្តឹងសាទុក្ខដោយសារអំពើមនុស្សឃាតឡើយ។ ការផ្តល់ -- ផ្តន្ទាទោសគាត់គឺផ្អែកទៅលើអំពើមនុស្សឃាតជាច្រើននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មិនមែនតែនៅភ្នំក្រោលនោះទេ។ ចុងក្រោយ ខ្ញុំនឹងនិយាយអំពីការធ្វើទុក្ខបុកម្នេញផ្អែកមូលដ្ឋាននយោបាយទៅលើប្រជាជនថ្មីនៅត្រាំកក់ ទំនប់១មករា និងទំនប់ត្រពាំងថ្ម។ នៅក្នុងមូលដ្ឋាន១០៧, ១១៤, ១១៨ ម្ចាស់បណ្តឹងសាទុក្ខ ដូចដែលលោកលោកស្រីចៅក្រមដឹងហើយថាជឿជាក់ថា ប្រជាជនថ្មីមិនអាចរើសអើងទេ ព្រោះពួកគេទទួលបានការប្រព្រឹត្តដូចគ្នានឹងប្រជាជនដែលដទៃៗទៀតដែរ។ គាត់បានធ្វើឲ្យអំពើឧក្រិដ្ឋហ្នឹងទៅជារឿងតូចតាចទៅលើប្រជាជនថ្មីទៅវិញ ដោយមិនគិតអំពីគោលនយោបាយធ្វើទុក្ខបុកម្នេញជារួមទៅលើពួកគាត់នោះឡើយ។ ហើយនេះ

គឺជាអ្វីដែលសាលាដំបូងបានរកឃើញថាស្របជាមួយនឹងគោលនយោបាយរបស់បក្សកុម្មុនីស្ដកម្ពុជាទៅលើការប្រព្រឹត្តទៅលើខ្មាំងជាក់ស្ដែង ឬក៏ខ្មាំងដែលគេចាត់ទុក។ គោលនយោបាយធ្វើទុក្ខបុកម្នេញដែលត្រូវបានអនុវត្តជាប្រព័ន្ធចាត់ចំណាត់ថ្នាក់ហ្នឹង ធ្វើឲ្យប្រជាជនថ្មីគាត់អន់ទាបជាងគេ គឺខុសពី -- គឺគេចាត់ទុកថាថ្នាក់ទាប ថ្នាក់អន់ដែលនៅក្រោមប្រជាជនមូលដ្ឋាន។

[១៤:០៥:២៦]

គឺប្រជាជនមូលដ្ឋានមានសិទ្ធិពេញលេញអនុញ្ញាតឲ្យពួកគេមានតួនាទីកាន់អំណាច ឬក៏គ្រប់គ្រងទៅលើសហករណ៍ និងការដ្ឋាន។ ចំណុចមួយទៀតនៃគោលនយោបាយធ្វើទុក្ខបុកម្នេញហ្នឹង គឺមានគោលនយោបាយ ឬក៏ការណែនាំរបស់បក្សកុម្មុនីស្ដកម្ពុជាឲ្យមានការអប់រំ រៀនសូត្រ ចាប់ខ្លួន និងកម្ទេចប្រជាជនថ្មី។ ហេតុដូច្នេះហើយប្រជាជនថ្មីទទួលនូវបទពិសោធន៍នៃអំពើរើសអើងជាច្រើន។ នៅសហករណ៍ត្រាំកក់ រួមមានទាំងការសម្រិតសម្រាំង ការបំបែកចេញពីប្រជាជនមូលដ្ឋាន និងបង្ខំឲ្យធ្វើការខ្លាំងជាងមុន ហើយទទួលបានអាហារតិចជាង។ នៅទំនប់ ១មករា រួមមានការតាមដានដោយឈ្លបទទួលរងការចោទប្រកាន់ថាធ្វើខុស ចាប់ខ្លួន ហើយបាត់ខ្លួនលែងឃើញសាជាថ្មី។ នៅទំនប់ត្រពាំងថ្មវិញ សិស្សនិស្សិត និងបញ្ញវន្តត្រូវបានគេកំណត់គោលដៅ ដើម្បីចាប់ខ្លួន ហើយសម្លាប់ ហើយបានកើតឡើងនូវស្ថានភាពនេះ។ សរុបមក ដោយមិនគិតថាអ្នកដទៃទៀតក៏ទទួលរងការប្រព្រឹត្តបែបណានោះប្រជាជនថ្មីគឺទទួលរងការកំណត់គោលដៅ ដោយសារតែពួកគេគឺជាប្រជាជនថ្មី ហើយដែលបក្សកុម្មុយនីស្ដកម្ពុជាចាត់ទុកថាជាខ្មាំង ដូច្នេះហើយត្រូវតែរើសអើង។ ខ្ញុំសូមបញ្ចប់សារណារបស់ខ្ញុំ ហើយឥឡូវនេះខ្ញុំសូមប្រគល់វេទិកាទៅលោកស្រី ដេវីល។

សូមអរគុណឯកឧត្ដមប្រធាន លោកលោកស្រីចៅក្រម។

[១៤:០៧:២៦]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធាន អស់លោក លោកស្រីចៅក្រមជាទីគោរព។ ទាក់ទងទៅនឹងការប្រព្រឹត្តទៅលើក្រុមជាក់លាក់នៅសាលាប៉ុន្មាននាទីទៀតនេះ ខ្ញុំនឹងឆ្លើយតបទៅនឹងបញ្ហាដែលលើកឡើងដោយអង្គជំនុំជម្រះនៅក្នុងរបាយការណ៍ ហើយនិងនិយាយអំពីគោលនយោបាយរបស់បក្ស ហើយនិងឆ្លើយតបទៅនឹងអំណះអំណាងរបស់មេធាវីការពារក្ដីកាលពីព្រឹកមិញ។ មេធាវីការពារក្ដីមិនបានឆ្លើយតបទៅនឹងអង្គជំនុំជម្រះទេ ទាក់ទងទៅនឹងការធ្វើទារុណកម្មអ្នកទោសចាមនៅក្នុងភូមិទ្រា។ អង្គជំនុំជម្រះសាលាដំបូង

អង្គជំនុំជម្រះបានចេញសេចក្តីសន្និដ្ឋានយ៉ាងត្រឹមត្រូវថាមានឧក្រិដ្ឋកម្មធ្វើទារុណកម្ម ដោយសារមាន សាក្សី អ៊ិត សែន នេះបាននិយាយយ៉ាងលម្អិតថាពួកចាមត្រូវបានគេវៃធ្វើបាបជាប្រព័ន្ធជាញឹកញាប់ ដើម្បីឲ្យដឹងថាពួកគេស្ថិតនៅក្រុមចាម។ ហើយមេធាវីការពារក្តីមិនបានបង្ហាញពីអ្វីឲ្យច្បាស់លាស់នោះ ទេ។ ហើយតាមច្បាប់អន្តរជាតិហ្នឹងគឺថាអង្គជំនុំជម្រះអាចទុកចិត្តលើសាក្សីមួយបាន ហើយបន្ទាប់មក ទៀតនៅកថាខណ្ឌ៣២៨០ គឺថាវិធីសាស្ត្រហ្នឹងគឺថាអង្គជំនុំជម្រះបានពិនិត្យយ៉ាងភស្តុតាងយ៉ាងលម្អិត ទៅលើបុគ្គលម្នាក់នុ៎ង។ ហើយសាក្សីហ្នឹងមាន អ៊ិត សែម ហើយនិង ស -- ម៉ាត់ ស និង នង សេត ផង ដែរ ដែលគេបានសួរគាត់ថា តើគាត់ចាម ឬខ្មែរ។ ហើយទី៤នុ៎ងគឺថា មេធាវីការពារបាន គាត់បានលើក ឡើងនៅក្នុងសារណារបស់គាត់គឺថារិះគន់តុលាការ ហើយនិងលើភាពទុកចិត្តបាននៃសាក្សី អ៊ិត សែម នៅកថាខណ្ឌ១៧៣៩ និងដល់ ៥០។ គាត់និយាយថា អ៊ិត សែម នេះនិយាយមានភាពជម្រោងជម្រះគ្នា ដោយសារត្រង់មានគេវៃមនុស្សមួយក្រុមនោះ ដើម្បីឲ្យដឹងថាតើពួកគេជាអ្នកកាន់សាសនាអ៊ីស្លាមឬក៏អត់។ ហើយម្យ៉ាងទៀតហ្នឹង អ្នកធ្វើទារុណកម្មនុ៎ងដឹងថា អ្នកសួរឆ្លើយ អ្នកធ្វើទារុណកម្មនោះដឹងថា ពួកគេ នុ៎ងជាជនជាតិចាមទៅហើយ។ អ៊ីចឹងគឺថាពួកនុ៎ងដឹងទាំងអស់ទៅហើយ ពីព្រោះថានៅក្នុងសវនាការ ពួកគាត់នុ៎ងត្រូវបានគេចាប់នៅក្នុងភូមិចាម គឺភូមិអំពិល និងភូមិសោយ។ ហើយនៅពេលទៅដល់ទ្រា នោះ ពួកគាត់ត្រូវបានគេចាត់ទុកថាជាពួកគេកំភូត ហើយត្រូវបានវៃថែមទៀត នៅពេលដែលអ្នកខ្លះ ឆ្លើយថា ពួកគាត់ជាខ្មែរ។ ចារី វៃពួកគាត់ដើម្បីឲ្យពួកគាត់បញ្ជាក់ថា ពួកគាត់នៅក្រុមចាមនោះ វាមិន មានភាពចម្រូងចម្រាសអ្វីនោះទេ។ ក៏ប៉ុន្តែវាមិនមានលក្ខណៈគ្រប់គ្រាន់ដើម្បីបង្ហាញថា មានកំហុសអង្គ ហេតុនោះទេ។ លើសពីបញ្ហាធ្វើទារុណកម្ម ដែលធ្វើនៅមន្ទីរសន្តិសុខទ្រានេះ អំណះអំណាងចម្បងរបស់ ម្ចាស់បណ្តឹងដែលអះអាងថា សាលាដំបូងហ្នឹងមិនគួរណាសន្និដ្ឋានថា មានគោលនយោបាយ មានបក្ស កុម្មុយនីស្តកម្ពុជាដែលតម្រូវឲ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម ហើយនិងមានជាប់ពាក់ព័ន្ធ *(ឮមិនច្បាស់)* ទៅនឹងផែនការរួមទាក់ទងទៅនឹងខ្មាំងជាក់ស្តែង និងស្រមើលស្រមៃ ទាក់ទងទៅនឹងពួកចាម ហើយនិង អតីតមេដឹកនាំសាធារណរដ្ឋខ្មែរ ពុទ្ធសាសនិក ហើយនិងជនជាតិវៀតណាម។ ប៉ុន្តែមូលដ្ឋានទាំង៤៥ នៃបណ្តឹងនោះគឺវាមានបរាជ័យ ពីព្រោះថា ម្ចាស់បណ្តឹងមិនបានវាយតម្លៃភស្តុតាងពេញលេញ និង ទាំងស្រុង ហើយជាទូទៅគឺតែងតែបំភ្លៃ ហើយនិងបកស្រាយខុសនូវភស្តុតាង ហើយនិងសេចក្តីសន្និដ្ឋាន ក្នុងសាលក្រម ហើយនិងមូលដ្ឋានបណ្តឹងឧទ្ធរណ៍របស់គាត់ហ្នឹង មានការចោទប្រកាន់ខុស ហើយនិង ភាពមិនត្រឹមត្រូវច្រើន។ ទាក់ទឹងនឹងជនជាតិចាម អង្គជំនុំជម្រះបានបង្ហាញភស្តុតាង បានបង្ហាញមូលដ្ឋាន

យ៉ាងគ្រប់គ្រាន់ដែលរកឃើញថាបក្សកុម្មុយនីស្តកម្ពុជា បានបង្កើតគោលនយោបាយឧក្រិដ្ឋដើម្បីធ្វើទុក្ខបុកម្នេញសម្លាប់ពួកក្រុមនេះ។ អង្គជំនុំជម្រះគឺថា ពួកចាមហ្នឹងដូចជាខ្មែរ ហើយដើម្បីបំបាត់ការប្រណិប័តន៍សាសនា និងវប្បធម៌ចាមទូទាំងប្រទេសតែម្តង។ នៅក្នុងចុងឆ្នាំ១៩៧៥ ពួកគាត់ត្រូវបានជម្លៀសដោយបង្ខំ ដើម្បីបំបែកពួកគាត់ចេញពីក្រុម។ ហើយដល់ពេលក្រោយមក ពួកគាត់ត្រូវបានចាប់ជាប្រព័ន្ធ ឃុំខ្លួន ហើយនិងសម្លាប់ជាទ្រង់ទ្រាយធំ ដោយមូលហេតុគាត់ គ្រាន់តែជាជនជាតិចាមតែប៉ុណ្ណោះ។ ម្ចាស់បណ្តឹងបានគេចវេះ មិនព្រមពិចារណាឧក្រិដ្ឋកម្មទាំងមូល ឧទាហរណ៍ដូចគាត់ធ្វើមិនដឹងមិនឮលើឯកសារផ្លូវការនៅសម័យនោះ ដូចជាតេឡេក្រាម ទី១៥ ដែល សោ ភឹម ផ្ញើទៅ ប៉ុល ពត នៅថ្ងៃទី៣០ វិច្ឆិកា ឆ្នាំ១៩៧៥ បន្ទាប់ពីមានការបះបោរជនជាតិចាម និងបង្ហាញពីគោលនយោបាយចាត់ទុកជនជាតិចាមជាគោលដៅត្រូវបានបង្កើតឡើងដោយបក្សកុម្មុយនីស្តកម្ពុជា។ ម្ចាស់បណ្តឹង គឺបានបដិសេធចោលនូវសក្ខីកម្ម ហើយនិងបំភ្លៃនូវការវាយតម្លៃរបស់អង្គជំនុំជម្រះដែលបានធ្វើទៅលើសក្ខី-កម្មរបស់ ប្រាក់ យុត ដែលសក្ខីកម្មរបស់ ប្រាក់ យុត នេះគឺសំខាន់ណាស់ ពីព្រោះពួកគាត់បានអះអាងថា គាត់នឹងលេខាស្រុកផ្សេងទៀត នៅស្រុកក្រាំងមាសហ្នឹង បានទទួលបញ្ជាពីតំបន់ ហើយតំបន់ដើម្បីបោសសម្អាតអតីតយោធា លន់ នល់ ហើយនិងអតីតមន្ត្រីរាជការសម័យ លន់ នល់។ ហើយដែលទទួលបញ្ជាឲ្យសម្លាប់ ឬក៏ចាប់ខ្លួនពី អោ អាន ជាញឹកញាប់។ ហើយគាត់ក៏បានអះអាងផងដែរ គាត់ថាបញ្ជាដែលខ្ញុំបានទទួលគឺច្បាស់ណាស់ គឺថាត្រូវតែសម្លាប់ពួកចាមទាំងអស់។ សូមបញ្ចប់ការដកស្រង់។

[១៤:១៣:៣៩]

ទាក់ទងនឹងជនជាតិវៀតណាម អង្គជំនុំជម្រះបាននិយាយថា បក្សកុម្មុយនីស្តកម្ពុជាបានបង្កើតគោលនយោបាយមជ្ឈិម ឧក្រិដ្ឋ ដើម្បីបំផ្លាញ និងបង្កព្យសនកម្មទៅដល់ក្រុមជាក់លាក់ដែលពាក់ព័ន្ធនឹងផែនការរួម។ នេះមិនមែនជារឿងចៃដន្យនោះទេ ដែលជនជាតិវៀតណាមត្រូវចោទថាជាសត្រូវស្លូតបូតនៅក្នុងទូទាំងប្រទេសកម្ពុជានេះ ដែលមានកំណត់អត្តសញ្ញាណប្រវត្តិរូប ហើយនិងការវាយការណ៍អំពីជនជាតិវៀតណាមទាំងអស់នេះ មុននឹងពេលជម្លៀសពួកគាត់ជាប្រព័ន្ធហើយ និងចាប់ និងសម្លាប់ពួកគាត់។ អង្គជំនុំជម្រះបានផ្តោតទៅលើឯកសារសម័យកម្ពុជាប្រជាធិបតេយ្យដើម្បីកំណត់ក្រុមវៀតណាមថាជាក្រុមជាក់លាក់ ហើយនិងត្រូវបានទទួលបានការការពារ ហើយនិងដើម្បីបង្ហាញថា ការសម្លាប់ជនជាតិវៀតណាមពិតជាត្រូវបានរាយការណ៍ទៅថ្នាក់ដឹកនាំនៃបក្សកុម្មុយនីស្តកម្ពុជា។ ម្ចាស់បណ្តឹងបានប្រើវិធីសាស្ត្រតែមួយជ្រុង ហើយធ្វើមិនដឹងមិនឮ ហើយនិងទៅដល់សុន្ទរកថា ខៀវ សំផន និង ប៉ុល

ពត ដែលនិយាយអំពីប្រជាជនវៀតណាមទាំងមូលតែម្តង មិនមែននិយាយតែពីកងទ័ពវៀតណាមនោះទេ ក្នុងក្របខ័ណ្ឌជម្លោះប្រដាប់អាវុធ។ នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៨ ខៀវ សំផន បានអំពាវនាវជាសាធារណៈថា ឲ្យបំបាត់ឲ្យអស់ខ្លាំងគ្រប់ប្រភេទពីទឹកដីកម្ពុជា ជាពិសេសពួកឈ្លានពានវៀតណាម។ នៅក្នុងគោលបំណងដើម្បីការពារពូជសាសន៍កម្ពុជា។ ទាក់ទងទៅនឹងអំពើមនុស្សឃាត នៅក្នុងដីកាដំណោះស្រាយមានធាតុផ្សំគ្រប់គ្រាន់ដើម្បីធ្វើឲ្យសាលាដំបូងសន្និដ្ឋានថា គឺយុត្តាធិការនេះគឺលើទូទាំងប្រទេសកម្ពុជាតែម្តង មិនមែនតែខេត្តស្វាយរៀង ព្រៃវែងនោះទេ។ ហើយអង្គជំនុំជម្រះហ្នឹងផ្អែកទៅលើតែសក្ខីកម្មរបស់ អ៊ុត សែម ទាក់ទងទៅនឹងខេត្តស្វាយរៀង។ ប៉ុន្តែទោះយ៉ាងណាក្តីគឺវាទាក់ទងទៅនឹងជនជាតិវៀតណាមជាង ១០០នាក់ ដែលសម្លាប់នៅមន្ទីរស-២១ ហើយនិងនៅអូរកន្សែងផងដែរ។

[១៤:១៦:០៨]

អង្គជំនុំជម្រះ បានបង្ហាញយ៉ាងត្រឹមត្រូវថា អំពើប្រល័យពូជសាសន៍ហ្នឹងត្រូវបានបង្ហាញថាមានមែន ដែលជាគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលមានរបៀបប្រតិបត្តិការហ្នឹងដូចៗគ្នានៅទូទាំងប្រទេស។ ការ -- អំពើប្រល័យពូជសាសន៍ ហើយនិងការធ្វើទុក្ខបុកម្នេញទៅលើជនស៊ីវិលវៀតណាមនោះ ហើយជនស៊ីវិល មានកូនក្មេង ហើយនិងមនុស្សចាស់ ដែលមិនមែនជាការគំរាមកំហែងអីដល់របបខ្មែរក្រហមនោះទេ។ ប៉ុន្តែពួកគាត់ត្រូវបានចាត់ទុកថាជាខ្មាំង ហើយនិងសម្លាប់ដូចជនជាតិវៀតណាមផ្សេងទៀតផងដែរនៅមន្ទីរស-២១ នៅសមុទ្រ នៅកន្លែងផ្សេងទៀត នៅក្នុងប្រទេសកម្ពុជាដូចជានៅវត្តខ្សាច់ជាដើមនៅក្នុងភូមិភាគឧត្តរ។ គាត់ម្ចាស់បណ្តឹងតែងតែបដិសេធសាក្សីរបស់មនុស្សមួយចំនួន ដូចជា មាស វឿន ជាដើម ដែលបានអះអាងនៅក្នុងសវនាការថា ពួកវៀតណាម គឺទោះបីជាចាស់ក៏ដោយ ឋានៈអីក៏ដោយ ត្រូវតែចាត់ទុកថាជាខ្មាំង ហើយត្រូវតែ ហើយយើងបានទទួលការណែនាំថា ពួកវៀតណាមត្រូវតែកម្ទេចចោល ពីព្រោះថាពួកវាមិនព្រមត្រឡប់ទៅស្រុកវាវិញ។

[១៤:១៧:២៦]

ខ្ញុំសូមត្រឡប់មកនិយាយអំពីសក្ខីកម្មរបស់ ស៊ិន ចែម -- ស៊ិន ឆែម ម្តងទៀតគឺថា មេធាវីការពារក្តីមិនព្រមមើលសក្ខីកម្មទាំងមូលនោះទេ ហើយនិងជោគវាសនា ដែលជនជាតិវៀតណាមទទួលរងពីគោលនយោបាយមជ្ឈិមដែលសំដៅសម្លាប់ពួកគាត់ចោលទាំងអស់នៅប្រទេសកម្ពុជា។ ស៊ិន ចែម នេះមិនបានចូលរួមក្នុងការសម្លាប់ក្រុមគ្រួសារ ទាំង៤ក្រុមគ្រួសារ និងកូនក្មេងវៀតណាមនោះទេ ក៏ប៉ុន្តែដឹងថា ក្រុមគ្រួសារទាំងអស់នោះត្រូវបានសម្លាប់មែន។ ឆ្លើយចម្លើយយើងទៅនឹងមេធាវីការពារក្តី គឺ

ឯកសារ F54/1 កថាខណ្ឌ៥៩៨ ស៊ិន ថែម ស្គាល់គ្រួសារនេះមុន ក្នុងឆ្នាំ១៩៧៥ ហើយរស់នៅក្បែរគ្នា ធ្វើការជាមួយគ្នា ហើយសំខាន់ជាងហ្នឹងទៅទៀតគាត់ឃើញថា គេចាប់គាត់ចងស្លាបសេក។ អ្នកសាក្សី និងការចាប់ខ្លួននេះបានរៀបរាប់អំពីការបាត់ខ្លួន ហើយនិងការសម្លាប់ពួកគាត់។ មេឃុំបានថា បាននិយាយថា ម្ដាយ ហើយនិងកូនទាំងអស់ដែលជាកូនកាត់ហ្នឹងត្រូវបាននាំទៅសម្លាប់ចោល។ ហើយសាក្សីនេះ បានឃើញថា ខ្មោចកូនក្មេងនេះ ហើយនិងស្ត្រីទាំងអស់នេះនៅវាលស្រែ ហើយគេប្រាប់គាត់ថា គេសម្លាប់គាត់មុននឹងមួយថ្ងៃ។ ហើយវៀតណាមផ្សេងទៀតដែលនៅកន្លែងផ្សេងទៀតហ្នឹងក៏ត្រូវបានសម្លាប់ផងដែរ។ អង្គជំនុំជម្រះបានពិចារណាដោយត្រឹមត្រូវថា អាស្រ័យនឹងបរិបទហើយនិងភាពច្បាស់លាស់នៃចម្លើយសាក្សីហ្នឹងគឺថា ក្រុមគ្រួសារទាំងបួននេះ សមាជិកក្រុមគ្រួសារទាំងបួននេះ ត្រូវបានសម្លាប់មែន។ ទាក់ទងទៅនឹងក្រុមជាក់លាក់នេះ គឺថា បរាជ័យដោយសារមិនបំពេញលក្ខខណ្ឌតម្រូវនៃស្តង់ដារបណ្ដឹងឧទ្ធរណ៍។

ខ្ញុំផ្តល់វេទិកានេះទៅសហភាគីរបស់ខ្ញុំដែលត្រូវការពេលវេលា ១១នាទី ដើម្បីនិយាយបន្ទាប់ទៀត។

[១៤:២០:០០]

**លោកស្រី រូថ ម៉ារី ហេកគ័រ៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម! ថ្ងៃនេះ ខ្ញុំនឹងផ្តោតទៅលើបញ្ហាពីរ គឺទី១ និយាយអំពីបណ្ដឹងសាទុក្ខរបស់ -- ការ -- ដើមបណ្ដឹងរបស់ -- នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺការរៀប -- ការជំទាស់ទៅលើភស្តុតាងជាក់លាក់របស់គាត់នេះគឺមានលើកឡើងនៅក្នុងផ្នែក៧(ឃ) នៃកំណត់ហេតុស្តាប់ចម្លើយសាក្សី ព្រមទាំងសារណាជាលាយលក្ខណ៍អក្សររបស់ដើម្បីបណ្ដឹងរដ្ឋប្បវេណី។ ដូចដែលលោក លោកស្រីចៅក្រមដឹង នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺខ្ញុំ -- មុននឹងខ្ញុំបន្តទៅទៀត ខ្ញុំចង់បញ្ជាក់ថា កាលពីព្រឹកមិញមេធាវីការពារក្តីបានបញ្ជាក់ដោយខុសឆ្គងអំពីអំពើអមនុស្សធម៌ដទៃទៀតដែលនិយាយថា តម្រូវឲ្យមានចេតនាក្នុងការបង្កឲ្យមានការឈឺចាប់ធ្ងន់ធ្ងរ។ ការពិតអានេះមិនមែនជាលក្ខណៈវាយតម្លៃឡើយ គឺនៅក្នុងកថាខណ្ឌ៥(ឃ) នៃសាលក្រមរបស់សាលាដំបូងគឺបានបញ្ជាក់ច្បាស់ថា លក្ខខណ្ឌនេះ គឺត្រូវធ្វើឡើងដោយមានចេតនាក្នុងការបំពេញ គឺក្នុងការបណ្ដាលឲ្យមានការឈឺចាប់ មិនមែន មិនចាំបាច់ថាមានចេតនា មិនមានចេតនានោះទេ។ ការបកស្រាយដោយខុសទៅលើបទដ្ឋានបែបនេះ គឺធ្វើឲ្យប៉ះពាល់ទៅដល់ការជំទាស់ទៅលើគោលនយោបាយ។ ដូចដែលលោក លោកស្រីចៅក្រមជ្រាបអ៊ីចឹង នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា

បានប្រើប្រាស់សិទ្ធិអំណាចផ្ដាច់ការ និងការគ្រប់គ្រងទាំងស្រុងទៅលើប្រជាជន។ មិនមានអ្វីដែលថាមិនស្ថិតក្រោមការគ្រប់គ្រងទេ រួមទាំងសកម្មភាពដែលមានលក្ខណៈផ្ទាល់ខ្លួនបំផុត គោលនយោបាយគ្រប់គ្រងទៅលើការរៀបអាពាហ៍ពិពាហ៍ គឺមានធាតុផ្សំពីរ៖ ទី១ គឺថាគេសម្រេចថាអ្នកណាត្រូវរៀបការជាមួយអ្នកណា ពេលណា ហើយនិងត្រូវរៀបការជាមួយគ្នាឬអត់? ដូចគ្នានឹងគោលនយោបាយបក្សកុម្មុយនីស្តដទៃទៀតដែរ អ្នកណាដែលបដិសេធ ឬក៏ជំទាស់ទៅលើធាតុផ្សំណាមួយនោះគឺ ត្រូវទទួលផលប៉ះពាល់ ទទួលផលវិបាកធ្ងន់ធ្ងរបំផុត។ ហេតុដូច្នេះហើយមិនមាននរណាម្នាក់ហ៊ានជំទាស់ទេ។ ការសម្រេចដែលថាការរៀបការដោយបង្ខំ និងការរួមភេទដោយបង្ខំនៅក្នុងការរៀបអាពាហ៍ពិពាហ៍ គឺជាផ្នែកនៃគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជានោះ គឺផ្អែកទៅលើភស្តុតាងយ៉ាងច្រើន មិនមែនផ្អែកទៅលើការវាយតម្លៃដោយលម្អៀង និងជ្រើសរើសដូចដែលមេធាវីការពារ ដូចដែលម្ចាស់ដើមបណ្ដឹងសាទុក្ខចោទប្រកាន់នោះទេ។ ចៅក្រមបង្ហាញថាអង្គជំនុំជម្រះបានពិចារណាដោយប្រុងប្រយ័ត្នទៅលើភស្តុតាង និងសក្ខីកម្មដោះបន្ទុកផងដែរ។ ប៉ុន្តែ ភស្តុតាងនិងសក្ខីកម្មដោះបន្ទុកហ្នឹង គឺវាមានតិចតួចបំផុតធៀបទៅនឹងភស្តុតាង ដែលនិយាយអំពីកម្រិតខ្ពស់បំផុតនៃបក្សកុម្មុយនីស្តកម្ពុជាដែលមានចេតនាបង្កើតគោលនយោបាយ ហើយនិងចេញសេចក្ដីណែនាំ។

[១៤:២៣:១១]

ភស្តុតាងដែលរឹងមាំបំផុតគឺ បង្ហាញអំពីគោលនយោបាយដែលចេញពីថ្នាក់លើ គឺឯកសារ E3/775 នេះគឺជាឯកសារ និងនិយាយអំពីគោលនយោបាយកសាងគ្រួសារដែលសំខាន់បំផុត ហើយវាបោះពុម្ពពីរដងនៅក្នុងទស្សនាវដ្ដីយុវជន-យុវនារីបដិវត្ត។ ឯកសារហ្នឹងបានសង្កត់ធ្ងន់ទៅលើការជ្រើសរើសគ្រួសារ គឺទៅលើអង្គការ មិនមែនផ្អែកទៅលើការជ្រើសរើសផ្ទាល់។ ខ្ញុំសុំដកស្រង់៖ "នៅក្នុងបញ្ហាកសាងគ្រួសារ លទ្ធផលនៃការសម្រេចរបស់អង្គការគឺថាត្រូវតែគោរពរាល់ការសម្រេចរបស់អង្គការ និងការសម្រេចសមូហភាពត្រូវគោរព មិនត្រូវមានអារម្មណ៍បដិសេធ មិនត្រូវពិបាកចិត្តឡើយ ព្រោះនេះគឺជាការសម្រេចរបស់អង្គការ និងសហ និងអង្គការសម្រេចរួម"។ សូមបញ្ចប់ការដកស្រង់។

សុន្ទរកថា និងរបាយការណ៍ពីថ្នាក់ដឹកនាំជាច្រើនក៏បានគាំទ្រផងដែរថា ការរៀបការ និងការផ្សំដំណេកគឺសម្របសម្រួល គឺជួយទៅដល់គោលដៅរបស់បក្ស។ នៅក្នុងសុន្ទរកថាមួយ ប៉ុល ពត បាននិយាយថា "ការពារ និងកសាងប្រទេសប្រកបដោយប្រសិទ្ធភាពដោយមហាលោតផ្លោះ មហាអស្ចារ្យ។ ប្រជាជនបច្ចុប្បន្នមានប្រហែលតែមិនដល់ ៨លានផង ដូច្នេះវាទាប វាតិចតួចបំផុតដើម្បីសម្រេចសក្ដានុពល

របស់ប្រទេស។ ដូច្នេះហើយយើងត្រូវការជាង ២០លាននាក់ឯណោះ។ ដូច្នេះហើយគាត់ប្រកាស ថា ដូច្នេះហើយ គោលដៅរបស់យើង គឺបង្កើនប្រជាជនឲ្យបានឆាប់បំផុតតាមតែអាចធ្វើទៅបាន។ ដោយការគាំទ្រផងដែរ ទៅដល់ការបង្កើនប្រជាជនកាន់តែឲ្យបានឆាប់រហ័សនោះ ខៀវ សំផន, អៀង សារី និងទស្សនាវដ្ដីឃោសនាការរបស់បក្ស ក៏បានផ្សព្វផ្សាយបែបនេះដែរ។ ម្ចាស់បណ្ដឹងសាទុក្ខមិនបានជំទាស់ទៅលើសេចក្ដីប្រកាសទាំងអស់នេះទេ ប៉ុន្តែគាត់គ្រាន់តែនិយាយថាបក្សកុម្មុយនីស្ដកម្ពុជា គ្រាន់តែបង្កើនប្រជាជនដើម្បី ដោយធ្វើឲ្យប្រសើរទៅដល់ស្ថានភាពរស់នៅរបស់ប្រជាជន ហើយការរៀបការ ការរៀបចំការនោះ គឺធ្វើឡើងដើម្បីតម្រូវការប្រជាជន។ អង្គជំនុំជម្រះពិចារណាទៅលើទឡ្ហីករណ៍នោះ ប៉ុន្តែពួកគេមិនអាចបដិសេធទៅលើភស្តុតាងជាច្រើនដែលថា ការរៀបការត្រូវបានរៀបចំសម្រាប់ផលប្រយោជន៍របស់បដិវត្តន៍ មិនមែនផលប្រយោជន៍របស់ប្រជាជនឡើយ។

[១៤:២៥:៣០]

សាក្សី ជួន ធី បានផ្ដល់ សក្ខីកម្មថា ប៉ុល ពត បានប្រាប់កម្មាភិបាលនូវការប្រជុំនៅកំពង់ឆ្នាំងថា ត្រូវរៀបចំការរៀបអាពាហ៍ពិពាហ៍ ដើម្បីឲ្យមានបង្កើនប្រជាជន។ ដើមបណ្ដឹងរដ្ឋប្បវេណី ជា ឌៀប ក៏ផ្ដល់ភស្តុតាងអំពីការប្រជុំនៅក្នុងកម្រិតក្រសួង ដែលថាត្រូវរៀបចំការរៀបអាពាហ៍ពិពាហ៍ទាំងបុរសទាំងនារីដើម្បីបង្កើតកូនឲ្យអង្គការ ហើយនិងដើម្បីការពារប្រទេស។ ការណែនាំទាក់ទងទៅនឹងគោលនយោបាយត្រូវបានផ្សព្វផ្សាយជាប្រព័ន្ធទៅថ្នាក់ក្រោមដើម្បីអនុវត្ត។ ហោចណាក៏មានកម្មាភិបាលខ្មែរក្រហមប្រាំពីររូបបានផ្ដល់សក្ខីកម្មថា កម្មាភិបាលនៅទូទាំងប្រទេសទទួលបានការប្រាប់នៅក្នុងការប្រជុំ ហើយនិងវគ្គរៀនសូត្រអំពីថ្នាក់លើទាក់ទងនឹងសេចក្ដីណែនាំពីការរៀបការ។ នៅទូទាំងប្រទេសទាំងបុរស ទាំងនារី ត្រូវបានគេបង្ខំឲ្យរៀបការនៅក្នុងពិធីបុណ្យ -- ពិធីរៀបអាពាហ៍ពិពាហ៍ជារួម។ ប្រាកដណាស់ថានៅពេលដែលបង្ខំឲ្យពួកគេរៀបការ វាមិនគ្រាន់តែជាធាតុផ្សំមួយនៃគោលនយោបាយនោះទេ ប៉ុន្តែសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីជាច្រើនបានផ្ដល់ភស្តុតាងថា នៅពិធីរៀបអាពាហ៍ពិពាហ៍កម្មាភិបាលដែលមកដឹកនាំ គឺបង្គាប់បញ្ជាប្ដីប្រពន្ធហ្នឹងឲ្យរួមដំណេក ហើយបង្កើតកូនឲ្យអង្គការ។ ដើម្បីធានាថាពួកគេធ្វើដូច្នេះ គឺពួកឈ្លបបានតាមដានអ្នកដែលរៀបការ ហើយរាយការណ៍ទៅថ្នាក់លើអំពីសកម្មភាពនៅពេលយប់ គឺមានសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណីជាង២០នាក់ ត្រូវបានដកស្រង់អំពីបញ្ហាត្រូវគេតាមដាន នៅកថាខណ្ឌ៣៦៤១ ដល់ ៣៦៤៦។ នៅពេលដែលកម្មាភិបាលរកឃើញថាពួកគេអត់ផ្សំដំណេកហ្នឹងមានផលវិបាកជាច្រើន រួមមានការអន្តរាគមន៍ផ្នែកផ្លូវកាយ ការកោះហៅ គំរាម

កំហែងប្រជាជនទៅរៀនសូត្រ ឬសូម្បីអាចឈានដល់ការសម្លាប់ក៏មានដែរ។

[១៤:២៧:២៦]

ម្ចាស់បណ្តឹងបានចោទប្រកាន់ថា ការរៀបការ ឬក៏ការផ្សំដំណេកដែលត្រូវបានគេបង្ខំគឺដោយ-សារតែកម្មាភិបាលមិនបានអនុវត្តគោលនយោបាយបក្សត្រឹមត្រូវនោះទេ មិនមែនជាលទ្ធផលនៃគោល-នយោបាយទូទាំងប្រទេសនោះទេ ប៉ុន្តែការរៀបការដោយបង្ខំ និងការរួមដំណេកដោយបង្ខំហ្នឹងគឺ កើតឡើងនៅគ្រប់ទីកន្លែងក្នុងប្រទេសនៅក្នុងរបបទាំងមូល។ អង្គជំនុំជម្រះបានកត់សម្គាល់ថាមានការ ប្រែប្រួលតិចតួចទៅលើការលម្អិតលើការអនុវត្ត ប៉ុន្តែជាក់ស្តែងនៅទូទាំងប្រទេសកម្ពុជាគឺថាវាមានលក្ខណៈប្រហាក់ប្រហែលគ្នា គឺមិនអាចពន្យល់ថារឿងចៃដន្យ ឬក៏ជាសកម្មភាពលទ្ធផលនៃកម្មាភិបាលមួយចំនួនតូចប៉ុណ្ណោះទេ គឺអ្វីដែលអាចធ្វើបាន គឺគ្រាន់តែពន្យល់បានថាវាជាផ្នែកមួយនៃការអនុវត្តជាប្រព័ន្ធជានយោបាយមជ្ឈិមពីថ្នាក់លើខ្ពស់បំផុត។ ចំពោះការសមស្រប គឺសាលាដំបូងបានសម្រេចថា គឺគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាបង្ខំឱ្យប្រជាជនរៀបការ ផ្សំដំណេក ហើយបង្កើតកូនដើម្បីអង្គការ។

ឥឡូវនេះយើងនិយាយពីបញ្ហាយល់ព្រម។ ម្ចាស់បណ្តឹងបានលើកទឡ្ហីករណ៍ដោយខុសថា ការរៀបការមិនមែនបង្ខំទេ គឺថាវាមានការស្វែងរក ការយល់ព្រម ហើយវាជាគោលការណ៍នៃការរៀបការដែលបក្សកុម្មុយនីស្តកម្ពុជាបានអនុវត្ត។ ប្រាកដណាស់ថា គឺវាអត់អាចថាមានរឿងបែបនេះបានទេ ជាផ្លូវច្បាប់ សេចក្តីសម្រេចដែលមានការឯកភាព គឺជាសេចក្តីសម្រេចដែលមិនមានការបង្ខំ ការគំរាមកំហែង ឬក៏ការកេងចំណេញដែលប្រើការបង្ខិតបង្ខំនោះទេ។ ការឯកភាពគឺជាសញ្ញាណមួយនៃការស្វ័យភាពបុគ្គល។ នៅពេលមនុស្សណាម្នាក់នៅក្នុងស្ថានភាពបង្ខំ គឺគាត់មិនអាចបញ្ចេញការបដិសេធបានទេ ព្រោះពួកគាត់ភ័យខ្លាចអំពើហិង្សា ឬក៏ការឃុំឃាំង។ ដូច្នេះ យើងមិនអាចចាត់ទុកថាជាការឯកភាពដែលពេញចិត្ត ដោយស្ម័គ្រចិត្តនោះទេ។

[១៤:២៩:១៧]

បន្ថែមពីលើនេះទៀត សាលាដំបូងក៏បានយល់ស្រប បានរកឃើញថាការឯកភាពនោះ គឺគ្រាន់តែជា ទោះបីថា សាលាដំបូងរកឃើញថាការឯកភាពហ្នឹងគឺជាផ្នែកនៃគោលនយោបាយរបស់បក្សមែន ប៉ុន្តែវាជាជាក់ស្តែងទៅគឺវាអត់មានការឯកភាពដោយពិតប្រាកដនោះទេ។ ការព្យាយាមគេច ឬក៏មិនព្រមរៀបការហ្នឹងគឺ ជាការ -- គឺបានន័យថាមិនទទួលបាននូវការគំរាមកំហែងអំពើហិង្សា ឬក៏អាចទទួលបានការដាក់ទណ្ឌកម្មពិតប្រាកដ។ មនុស្ស ឬក៏ប្រជាជនមិនអាចជំទាស់ដោយសេរីនោះឡើយ

ព្រោះពួកគេបារម្ភថាត្រូវបានគេចាត់ទុកថាជាខ្មាំង ហើយទទួលផលវិបាកធ្ងន់ធ្ងរ។ ចំពោះការយល់ស្រប ដែលថាគេតម្រូវឱ្យគូស្រករហ្នឹងយល់ស្របនៅក្នុងការរៀបការហ្នឹង វាគ្រាន់តែជាផ្លូវការអត់ប្រយោជន៍ប៉ុណ្ណោះ ដើម្បីនៅមានជីវិត ពួកគេមិនអាចបដិសេធបាននោះទេ ពួកគេត្រូវតែយល់ស្រប នេះគឺជាមិនមែនៗមិនមែនជាការយល់ស្របដោយស្ម័គ្រចិត្ត ដោយពេញចិត្តនោះទេ។ ទោះបីក្នុងករណីខ្លះដែលថា កម្មាភិបាលទាហានត្រូវបានអនុញ្ញាតឱ្យស្នើសុំរៀបការជាមួយនារី ដែលគេស្រឡាញ់ហ្នឹង ប៉ុន្តែសេចក្តីសម្រេចរបស់អង្គការ គឺត្រូវតែធ្វើឡើង ដាក់នៅមុខការសម្រេចរបស់បុគ្គល។ បុរសនុ៎ងអត់មានសិទ្ធិជ្រើសរើសថា តើរៀបការជាមួយអ្នកណាទេ គឺអង្គការជាអ្នកសម្រេច។

**ប្រធានអង្គជំនុំ៖**

ខាងសហព្រះរាជអាជ្ញាជិតចប់នៅ ហើយលើសរហូតដល់ ៥, ៦, ៧ នាទីហើយ។

**លោកស្រី រូថ ម៉ារី ហេគ្គ័រ៖**

សូមអភ័យទោសលោកប្រធាន នៅពេលដែលមានការឯកភាព គឺនិយាយឱ្យខ្លីទៅគឺថា មិនមានបញ្ហាណាមួយ ដែលមេធាវីការពារក្តីក៏អាចបង្ហាញថាវាជារឿងខុសឆ្គងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យឡើយ។ សូមអរគុណលោកប្រធាន។

ឥឡូវនេះ ខ្ញុំសូមប្រគល់វេទិកាជូនទៅដើមបណ្តឹងរដ្ឋប្បវេណី។

**ប្រធានអង្គជំនុំ៖**

បាទ ខ្ញុំសូមបញ្ជាក់ជូនថា សូមឱ្យគោរពនូវពេលវេលាឱ្យបានច្បាស់លាស់ផង ហើយអាចលើសតិចតួចបាន ដល់លើសច្រើនពេកគឺតុលាការ គឺកាត់ហើយ។ អ៊ីចឹងសូមអញ្ជើញសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីធ្វើសារណា។

[១៤:៣២:៣០]

**លោកស្រី មេហ្គិន ហ៊ីសត៍៖**

ជម្រាបសួរលោកប្រធាន លោក លោកស្រី ចៅក្រម ក៏ដូចជាភាគីទាំងអស់។ យើងខ្ញុំនឹងបែងចែកពេលវេលារបស់យើងមាននៅរសៀលនេះ ពេជ អង្គ នឹងលើកឡើងអំពីបញ្ហាពាក់ព័ន្ធទៅនឹងបទបញ្ជានៃការរៀបការ។ ប៉ុន្តែដំបូងខ្ញុំនឹងលើកឡើងអំពីចំណុចមួយចំនួន ដែលមេធាវីការពារក្តីលើកឡើងមុនពិសាបាយពាក់ព័ន្ធពិសេសទៅនឹងវិសាលភាពនៃសំណុំរឿង ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តមកលើជនជាតិវៀតណាម ការធ្វើទុក្ខបុកម្នេញ អំពើប្រល័យពូជសាសន៍។ ប៉ុន្តែចំណុចទាំងអស់នេះត្រូវបានសហ

ព្រះរាជអាជ្ញាលើកឡើងលម្អិតរួចទៅហើយ ខ្ញុំមិនចង់លើកឡើងចំណុចនេះឲ្យវាត្រួតគ្នាទៀតទេ។ អ៊ីចឹងខ្ញុំគិតឃើញថា យើងលើកឡើងតែចំណុចកុំឲ្យត្រួតគ្នា ហើយយើងបានលើកចំណុចទាំងអស់នោះនៅក្នុងសារណាបណ្តឹងសាទុក្ខរបស់យើងខ្ញុំផងដែរ។

ខ្ញុំផ្តោតទៅលើប្រធានបទបី ដែលខ្ញុំត្រូវនិយាយនៅរសៀលនេះ ទី១ គឺចំណុចទូទៅពាក់ព័ន្ធទៅនឹងមូលដ្ឋាននៃបណ្តឹងសាទុក្ខ, ២) ចំណុចខ្លះៗពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មផ្សេងៗទៀត, ទី៣ គឺនិយាយអំពីចំណុចខ្លះៗនៃឧក្រិដ្ឋកម្មធ្វើទុក្ខបុកម្នេញ និង-- ខ្ញុំសូមលើកយកចំណុចពាក់ព័ន្ធទៅនឹងប្រធានបទទាំងបី ដែលយើងលើកឡើងចំណុចខ្លះៗដែរ -- ប៉ុន្តែចំណុចលម្អិតមាននៅក្នុងសារណាបណ្តឹងសាទុក្ខរបស់យើងរួចមកហើយ ហើយជាពិសេសលើកយកឧក្រិដ្ឋកម្មណាដែលដើមបណ្តឹងរដ្ឋប្បវេណីបានជួបប្រទះផ្ទាល់។ ខ្ញុំលើកឡើងតែចំណុចពីរបីទេ អ៊ីចឹងដែលខ្ញុំយល់ឃើញថា វាជាចំណុចដែលសំខាន់ដែលត្រូវបញ្ជាក់។

[១៤:៣៤:៣១]

ទី១ ពាក់ព័ន្ធទៅនឹងបញ្ហាមូលដ្ឋានបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី តាមពិតមានចំណុចជាច្រើន ហើយចំណុចនីមួយៗហ្នឹងវាអាស្រ័យទៅលើអង្គសេចក្តីរបស់វា ក៏ប៉ុន្តែវាមានចំណុចខ្សោយខ្លះៗដែលអាចយកមកបញ្ជាក់ម្តងហើយម្តងទៀត នៅទូទាំងមូលដ្ឋានបណ្តឹងសាទុក្ខនេះ។ ចំណុចគន្លឹះមួយគឺថា ជាញឹកញាប់នោះមូលដ្ឋានអង្គហេតុគឺថា មិន -- ជាទូទៅមិនបានដោះស្រាយឆ្លើយតបទៅនឹងបទដ្ឋានត្រឹមត្រូវនៃការពិនិត្យឡើងវិញទេ វាតែងតែកើតមានឡើងដូចដែលមេធាវីធ្វើការជំទាស់តវ៉ាទៅលើអង្គសេចក្តីនៃភស្តុតាង ដោយមានបំណងចង់បង្ហាញជូនអង្គជំនុំជម្រះថាមានវិមតិសង្ស័យ។ ប៉ុន្តែសូមបញ្ជាក់ថា ពេលនេះយើងមិនមែនស្ថិតនៅក្នុងដំណាក់កាលជំនុំជម្រះទៀតទេ ហើយដូច្នេះវាមិនមែនជាបទដ្ឋានពីមុន -- មិនមែនបទដ្ឋានពាក់ព័ន្ធទេ។ មូលដ្ឋានបណ្តឹង -- មូលដ្ឋានអង្គហេតុនៅលើបណ្តឹងសាទុក្ខម្ចាស់បណ្តឹងសាទុក្ខត្រូវបង្ហាញថា វិមតិសង្ស័យនេះត្រូវតែមានកម្រិតខ្ពស់បំផុត។ ប៉ុន្តែជាទូទៅគាត់ហាក់បីដូចជាកែប្រែ ដោយគ្រាន់តែជំទាស់ទៅនឹងសេចក្តីសន្និដ្ឋានរបស់សាលាដំបូងដោយមិនបានបង្ហាញឲ្យឃើញអំពីថា មានៗហេតុផលនឹងអ្វីនោះទេ។ ហើយមូលដ្ឋានអង្គហេតុជាច្រើនរបស់មេ -- នៃបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីហ្នឹង គឺទៅសម្អាតទៅលើការយល់ខុសទៅលើច្បាប់ស្តីអំពីភស្តុតាងដែលអាចយកមកអនុវត្តបាន។

[១៤:៣៦:១៥]

ចំណុចទាំងពីរនេះគឺខកខានមិនបានបង្ហាញឲ្យឃើញច្បាស់ អំពីការកាប់សម្លាប់ទៅលើជនជាតិវៀតណាមនោះទេ។ ភស្តុតាងស៊ីសង្វាក់គ្នានៅទូទាំងរឿងក្តីនោះគឺ វាថាប្រជាជនវៀតណាមត្រូវបានកំណត់អត្តសញ្ញាណ និងបំបែកចេញពីប្រជាជនខ្មែរ ហើយគេយកនាំខ្លួនចេញទៅបាត់ទៅហើយមិនមែនឃើញត្រឡប់មកវិញទេ។ ហើយយោងទៅលើមូលដ្ឋាននៃភស្តុតាងនេះ ខៀវ សំផន ត្រូវបានផ្តន្ទាទោសអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល។

មេធាវីការពារក្តីហាក់បីជាមានបំណងធ្វើការ គឺថាច្រានចោលភស្តុតាងអំពីថាបានមកដោយសារតែពាក្យចចាមអារ៉ាម។ ប៉ុន្តែទឡ្ហីករណ៍ទាំងអស់នេះមិនបានបកស្រាយអំពីទស្សនៈនៃពាក្យចចាមអារ៉ាមហើយនិងភាពពាក់ព័ន្ធទាំងអស់នោះទេ។ អ៊ីចឹងដើមបណ្តឹងរដ្ឋប្បវេណី ប្រាក់ ខឿន នេះ គឺក្នុងសារណារបស់យើងខ្ញុំកថាខណ្ឌ៣០១ ដល់ ៣០៣ គាត់បានរៀបរាប់អំពីដំណើរការមួយ ដែលថាក្រុមគ្រួសារចម្រុះគ្នា មានទាំងខ្មែរវៀតណាមហ្នឹងត្រូវបានកំណត់អត្តសញ្ញាណ ហើយគេបង្ខំឲ្យធ្វើដំណើរទៅមុខ។ គាត់រៀបរាប់ថា នៅត្រង់ចំណុចមួយសមាជិកជនជាតិវៀតណាមនេះ ត្រូវបានបំបែកក្នុងនោះរួមមានប្រពន្ធរបស់គាត់ ម្តាយក្មេក និងកូន។ ហើយគាត់ក៏បានរៀបរាប់ថា អ្នក -- គ្មានអ្នកណាម្នាក់ក្នុងចំណោមអ្នកទាំងនោះហ្នឹងត្រឡប់មកវិញទេ។ ពាក់ព័ន្ធទៅនឹងបញ្ហាថា តើមានការសម្លាប់ប្រជាជនដែរអត់? ពេល ប្រាក់ ខឿន ផ្តល់សក្ខីកម្មដែលថាមេកងរបស់គាត់ប្រាប់គាត់ថា ប្រជាជនវៀតណាមត្រូវបានគេកម្ទេចចោលហើយ។ ប៉ុន្តែភស្តុតាងដទៃទៀតនៃរបស់គាត់ហ្នឹងមិនមែនជាពាក្យចចាមអារ៉ាមទេ គាត់ផ្តល់សក្ខីកម្មអំពីការកត់សម្គាល់ផ្ទាល់របស់គាត់ អំពីសមាជិកគ្រួសាររបស់គាត់ ដែលគេកំណត់អត្តសញ្ញាណថាជាវៀតណាម យកខ្លួន នាំខ្លួនយកទៅបាត់ ហើយមិនដែលបានឃើញត្រឡប់មកវិញទេ។

[១៤:៣៨:២៧]

នៅក្នុងព្រឹត្តិការណ៍ណាក៏ដោយ បើសិនណាជាភស្តុតាងចចាមអារ៉ាមហ្នឹង គឺមិនមានការហាមឃាត់ថាមិនឲ្យប្រើទេនៅក្នុងតុលាការអន្តរជាតិ។ ជំហររបស់មេធាវីការពារក្តីហ្នឹងហាក់បីដូចធ្វើការសន្និដ្ឋានរបស់ខ្លួនឲ្យថាវាមានសមហេតុផលថា សាលាដំបូងត្រូវតែកោះហៅសាក្សីផ្ទាល់ភ្នែក ដើម្បីមកបង្ហាញថាមានការកាប់សម្លាប់បែបនេះកើតមានឡើងមែន។

ជំហរនេះគឺដូចគ្គងណាស់ បើគិតពីការយល់ឃើញជាទូទៅ នៅពេលដែលការសម្លាប់ទ្រង់ទ្រាយធំត្រូវបានរៀបចំឡើងរបៀបនេះ តាមធម្មតាមិនមានអ្នករស់រានមានជីវិតទេ ដែលអាចមកផ្តល់សក្ខីកម្មស្តីអំពីបទពិសោធន៍របស់គាត់ទេ។ ក្នុងរឿងក្តីយើងនេះមានតែដើមបណ្តឹងរដ្ឋប្បវេណីជាជនជាតិវៀត-

ណាមម្នាក់គត់ដែលចូលខ្លួនមកបង្ហាញភស្តុតាង។ ដើមបណ្តឹងរដ្ឋប្បវេណី ជឿង យ៉ាំងចែត គឺសាល-ក្រម កថាខណ្ឌ៣៤៦៨ ដល់ ៦៩ គឺគេយកនាំខ្លួនគាត់ចេញពីភូមិ ដើរចេញបំបែកពីគ្រួសារ និងបំបែកចេញពីប្រជាជនវៀតណាមដទៃទៀតទាំងនោះ។ ពួកគេត្រូវបានចងដៃទៅក្រោយ ហើយបណ្តើរទៅកាន់ទីតាំងមួយក្នុងព្រៃ ហើយពួកគេបានគេសម្លាប់ដោយវ៉ៃជាមួយ -- កាប់នឹងពូថៅ។ ហើយ ជឿង យ៉ាំងចែត គាត់អត់បានស្លាប់ទេ គាត់ជាលទ្ធផលហ្នឹងគឺថាគាត់អាចមកផ្តល់ភស្តុតាងស្តីអំពីបទពិសោធន៍របស់គាត់។ ប៉ុន្តែភស្តុតាងរបស់គាត់ហ្នឹងក៏បានបញ្ជាក់ច្បាស់ថា ហេតុអ្វីដែលថាភស្តុតាងបែបនេះ វាកម្រនឹងរកបានអ៊ីចឹង។ នៅពេលដែលការកាប់សម្លាប់ប្រព្រឹត្តទៅក្នុងរបៀបនេះ តាមធម្មតា នឹងមិនមានអ្នកសាក្សីរស់រានមានជីវិតក្រៅពីឃាតករនោះទេ។ ការទាមទារឲ្យមានការរៀបរាប់ពីសាក្សីផ្ទាល់វិញក្នុងករណីអន្តរជាតិដែលសាលាដំបូងបានយោងនៅក្នុងកថាខណ្ឌ៦២៨ សាលាដំបូង អាយ.ស៊ី.ធី.វ៉ាយ នៅក្នុងរឿងក្តី ក្វចេឡាក និងសាលាឧទ្ធរណ៍របស់តុលាការ អាយ.ស៊ី.ធី.វ៉ាយ នៅក្នុងរឿង ក្វកកា និងនៅក្នុង តូលីមៀរ បានសម្រេចថា វាមិនចាំបាច់ត្រូវថា ដល់ទៅឃើញសាកសពនោះទេ ហើយក៏មិនចាំបាច់ថា ឲ្យមានសាក្សីផ្ទាល់ភ្នែកនោះដែរ។ អាយ.ស៊ី.ធី.វ៉ាយ បាននិយាយថា ការសន្និដ្ឋានហ្នឹងអាចដកចេញពីឧទាហរណ៍ដូចខាងក្រោម។ លំនាំនៃការធ្វើបាបប្រជាជន ការបាត់ខ្លួនបុគ្គលដទៃទៀត អំឡុងនៃពេលវេលា ដែលវាកន្លងហួសទៅយូរហើយ តាំងពីបុគ្គលនោះបាត់ខ្លួន ហើយនិងអង្គហេតុដែលថាអ្នកទាំងអស់នោះ គឺថា មិនអាចទាក់ទងជាមួយនឹងគ្រួសាររបស់ខ្លួនបានដូចជាគ្រួសារជាដើម។ នេះគឺជា ប្រភេទនៃភស្តុតាងនៃសាលាដំបូងបានស្តាប់ពាក់ព័ន្ធទៅនឹងការសម្លាប់ជនជាតិវៀតណាម។ ខ្ញុំបានលើកឡើងពីឈ្មោះសាក្សី ឈ្មោះ ប្រាក់ ឌឿន ម្នាក់ទៀតគឺសាក្សី អ៊ុច ស៊ុនឡាយ គាត់បានលើកឡើងនៅក្នុងកថាខណ្ឌ៣០៤ ដល់៣០៧។ អ៊ុច ស៊ុនឡាយ នេះបានរៀបរាប់ថា គាត់ត្រូវបានគេបញ្ជូនទៅឲ្យប្រមូលដើមឫស្សីជាមួយប្រុសៗជាច្រើនៗទៀតពីភូមិរបស់គាត់។ ហើយពួកគេក៏បានបង្ខំឲ្យរៀបការទៅនឹងជនជាតិវៀតណាមដែរ។ ហើយគាត់ក៏បានរៀបការជាមួយស្ត្រីជនជាតិវៀតណាមម្នាក់។ នៅពេលត្រលប់មកវិញ ពួកគេបានប្រធានសហករណ៍ប្រាប់ ហើយឲ្យរៀបចំខ្លួនទៅ អ៊ុច ស៊ុនឡាយ ហ្នឹងគាត់ឃើញខោអាវរបស់សមាជិកក្រុមគ្រួសាររបស់គាត់ និងប្រពន្ធគាត់ ប៉ុន្តែមិនដែលឃើញអ្នកទាំងនោះត្រឡប់មកវិញទេ។

[១៤:៤២:៥០]

ភស្តុតាងគឺបានរៀបរាប់ហើយ គឺគ្មានអ្នកណាបានឃើញការសម្លាប់នោះទេ ប៉ុន្តែអង្គជំនុំជម្រះ

បានសម្រេចថា ជនជាតិវៀតណាមទាំងនេះ ត្រូវបានកាប់សម្លាប់។ មេធាវីការពារក្តីមិនបានលើកឡើងមូលដ្ឋានសមហេតុផលណាមួយ សម្រាប់ឲ្យអង្គជំនុំជម្រះធ្វើការពិចារណាឈានទៅដល់ការសន្និដ្ឋានថា វាមិនសមហេតុផលនោះទេ។ ហើយខ្ញុំក៏បាននិយាយថាការជំទាស់តវ៉ារបស់មេធាវីទាក់ទងទៅនឹងប្រជាជនវៀតណាម ប៉ុន្តែបញ្ហាខ្លះៗដែលបានអនុវត្តទៅនឹងមូលដ្ឋានអង្គហេតុរបស់ ខៀវ សំផន។ ភស្តុតាងហើយមេធាវីការពារក្តីសុំឲ្យស្វែងយល់អំពីចំណុចនេះ។ ប៉ុន្តែមិនបានបង្ហាញឲ្យឃើញបានច្បាស់ថា វាមិនសមហេតុផលនោះទេ។ ខ្ញុំបានលើកឡើងពីព្រឹកមិញនេះ ពាក់ព័ន្ធទៅនឹងសាក្សីម្នាក់ទៀត ហើយខ្ញុំយល់ស្របជាមួយសហការីមកពី ក.ស.ព ជាពិសេសពាក់ព័ន្ធទៅនឹងមូលដ្ឋានអង្គហេតុដែលថា ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះត្រូវបានឃុំខ្លួន សាលក្រមលើកឡើងនៅក្នុងកថាខណ្ឌ៣០៩៣។ នៅត្រង់កថាខណ្ឌ៣១០៤ មេធាវីការពារក្តីប្រហែលជាមិនយល់ស្របទៅនឹងការសម្រេចនេះ ក៏ប៉ុន្តែមានហេតុផលហើយចំណុចនេះមិនមែនមានន័យថា មិនសមហេតុផល។ យើងស្នើសុំឲ្យលោក លោកស្រីចៅក្រមអនុវត្តទៅលើបទដ្ឋានស្តង់ដារនៃភស្តុតាងឲ្យបានសមស្របបំផុត។

ហើយឥឡូវនេះ ខ្ញុំសូមបន្តទៅចំណុចទី -- ចំណុចពាក់ព័ន្ធទៅនឹងក្របខ័ណ្ឌច្បាប់ ពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃអំពើអមនុស្សធម៌មួយផ្សេងទៀត។ មុននឹងចូលនិយាយអំពីការបាត់ខ្លួន និងការបង្ខំឲ្យរៀបការនោះ ចំណុចគន្លឹះរបស់យើងខ្ញុំគឺអំពើអមនុស្សធម៌ផ្សេងទៀត វាមាននៅក្នុងកថាខណ្ឌ៥៨០ នៃសាលដីកាសំណុំ០២/១។ ហើយនៅក្នុងសារណារបស់យើងខ្ញុំ គឺក្នុងកថាខណ្ឌ៥២០។ ទី១ និយាយពីធាតុផ្សំ អំពីស្ថានទម្ងន់នេះ គឺអំពើ ឬក៏ការខកខាននៃភាពធ្ងន់ធ្ងរស្រដៀងគ្នាចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលវាកើតមានឡើងនៅពេលវេលាពាក់ព័ន្ធ។ ទី២ ធាតុផ្សំនៃការឈឺចាប់។ អំពើ ឬការខកខានដែលបណ្តាលឲ្យមានការរងការឈឺចាប់ផ្លូវចិត្ត ឬផ្លូវកាយ ឬក៏ការរងរបួស។ ទី៣ និយាយអំពីធាតុផ្សំនៃធាតុចេតនា។

[១៤:៤៦:៣០]

ខ្ញុំដោយសារតែវាមានការច្របូកច្របល់ហ្នឹង គឺលើកឡើងពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មទាំងនេះ។ អ៊ីចឹងហើយបានខ្ញុំលើកឡើងនេះ។ ក្រៅពីការអនុវត្តចំណុចធាតុផ្សំទាំងបីនេះ គឺថា វាហាក់ដូច មាននិន្នាការមួយចង់ទៅមើលទៅលើប្រភេទផ្សេងទៀត ហើយចាត់ទុកថា វាជាធាតុផ្សំបន្ទាប់បន្សំ ទាក់ទងទៅនឹងធាតុផ្សំទាំងបី ដូចខ្ញុំបានបញ្ជាក់អ៊ីចឹង។ ខ្ញុំសូមលើកឡើងអំពីប្រភេទបន្ទាប់បន្សំ។ វិធីសាស្ត្រហ្នឹងគឺជាវិធីសាស្ត្រស្នូលពាក់ព័ន្ធទៅនឹង ដែលនិយាយថា ធាតុផ្សំនេះ មិនពាក់ព័ន្ធទៅនឹងធាតុផ្សំនៃអំពើ

អមនុស្សធម៌ដទៃទៀតនេះ ក៏ប៉ុន្តែដូចដែលបានកំណត់ ដូចជាការបាត់ខ្លួនដោយបង្ខំ ការជម្លៀសខ្លួនដោយបង្ខំ ឬការរៀបការដោយបង្ខំ។ល។ យើងអាចឃើញថា វិធីសាស្ត្រនេះ បានបញ្ជាក់នៅក្នុងផ្នែកខ្លះនៃសារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារ ហើយខ្ញុំនឹងត្រឡប់មកនិយាយចំណុចនេះ។ ប៉ុន្តែទី១ គឺថា យើងយល់ឃើញថា វិធីសាស្ត្រនេះ គឺថាអាចត្រូវបាន យើងមើលឃើញវិធីសាស្ត្រនេះ ត្រូវបានអង្គជំនុំជម្រះប្រើប្រាស់ដូចជានៅក្នុងកថាខណ្ឌ៧២៧ និយាយឡើងអំពីក្របខ័ណ្ឌគតិយុត្ត សាលាដំបូងនិយាយថា ខ្លួនយោងទៅលើធាតុផ្សំសំខាន់ៗពាក់ព័ន្ធទៅនឹងអំពើដែលចោទជាបញ្ហានេះ។ ហើយនៅក្នុងកថាខណ្ឌ៧៥៤ សាលាដំបូងនិយាយលើកឡើងអំពីធាតុផ្សំនៃអំពើនៃការបាត់ខ្លួនដោយបង្ខំ។ ទី១ គឺការដកហូតសេរីភាព។ ទី២ ការបដិសេធមិនបានផ្តល់ព័ត៌មាន ឬក៏ការដឹងឮអំពីការដកហូតសេរីភាពនេះ ហើយនិងទី៣ ពាក់ព័ន្ធទៅនឹងគឺថា រដ្ឋនេះតែម្តង។ អ៊ីចឹងអង្គជំនុំលោកបានលើកឡើង បានអនុវត្តធាតុផ្សំទាំងបី ទៅលើអង្គហេតុទាំងអស់។ ការមិនដកហូតសេរីភាព ការមិនប្រាប់ព័ត៌មានឲ្យដឹងជាមុន ដូចជានៅក្នុងនិយាយពីស្រុកត្រាំកក់ កថាខណ្ឌ១២២០ ដល់១២០៣ កថាខណ្ឌ ១៤២៥ ដល់ ១៤២៦។ ហើយសម្រាប់ផ្នែកទូទៅដែលវាមិនពាក់ព័ន្ធទៅនឹងកំហុសនៅក្នុងបណ្តឹងឧទ្ធរណ៍នោះទេ។ ដល់អ៊ីចឹងហើយបានជាសាលាដំបូងបានអនុវត្តនូវធាតុផ្សំសំខាន់ទាំងបីពាក់ព័ន្ធទៅនឹងអំពើអមនុស្សធម៌ដទៃទៀត។ ដូច្នេះមិនមានផលប៉ះពាល់ទៅលើលទ្ធផលនៃសេចក្តីសម្រេចនោះទេ។

មានករណីលើកលែងមួយគឺសាលាឧទ្ធរណ៍ គឺព្រះរាជអាជ្ញាបានប្តឹងឧទ្ធរណ៍ទាក់ទងទៅនឹងចំណុចនេះតែម្តង។ ហើយគោលការណ៍ដ៏ទូលំទូលាយ គឺពាក់ព័ន្ធទៅលើអំពើទាំងអស់ដែលត្រូវបានចោទប្រកាន់ថា ជាអំពើអមនុស្សធម៌ដទៃទៀត។ នៅពេលសាលាដំបូងបានប្រើប្រាស់វិធីសាស្ត្រប្រភេទជាប្រភេទរងនេះ នៅក្នុងសំណុំរឿង០០២/១ លោក លោកស្រីចៅក្រមបាន -- តុលាការកំពូលបានសម្រេចគឺថា មិនត្រឹមត្រូវទេ នៅក្នុងកថាខណ្ឌ៥៨៩។ សាលដីកា បានពន្យល់ថា មានបញ្ហាដែលពាក់ព័ន្ធគឺអំពើដែលចោទជាបញ្ហានេះ គឺពិតជាបានបំពេញទៅលើនិយមន័យនៃអំពើអមនុស្សធម៌ដទៃទៀតហើយ។

[១៤:៥០:០០]

ខ្ញុំសូមបញ្ជាក់ទៅលើចំណុចពីរ៖ ទី១ គឺថាយើងមិនអាចនិយាយថា វាមិនមានការអនុញ្ញាតក្នុងការប្រើប្រាស់អំពើនេះ។ ពេលយើងនិយាយអំពីអំពើអមនុស្សធម៌ផ្សេងទៀតតាមរយៈការរៀបការដោយបង្ខំ ឬការបាត់ខ្លួនដោយបង្ខំ គឺយើងប្រើប្រាស់ពាក្យពេចន៍ជាក់លាក់មួយដើម្បីសង្ខេបទៅលើអំពើជារួមតែម្តង។ គឺថាវាមិនមែនជាការកំណត់ចរិតលក្ខណៈផ្លូវច្បាប់ទាក់ទងទៅនឹងធាតុផ្សំ ដែលយើងត្រូវតែ

បំពេញនោះទេ។ ទី២ យើងខ្ញុំមិននិយាយថា វាមិនមានការពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬក៏មិនពាក់ព័ន្ធដូចដែលតុលាការដទៃទៀតបានលើកឡើង អំពីការឈឺចាប់ ដែលបណ្ដាលមកពីអំពើប្រភេទនេះនោះទេ។ ចំណុចនេះគឺថាវាជាលិខិតតូបករណ៍វិភាគដើម្បីជួយទៅដល់ការវាយតម្លៃទៅលើភស្តុតាងដើម្បីឆ្លើយតបទៅនឹងបញ្ហាជាមូលដ្ឋានទាំងបីនេះ ធាតុផ្សំមូលដ្ឋានទាំងបី។ តើអំពើហ្នឹងគឺថាមានភាពធ្ងន់ធ្ងរគ្រប់គ្រាន់ទេ? តើអំពើហ្នឹងបណ្ដាលឲ្យមានការឈឺចាប់ទេ? តើអំពើហ្នឹងធ្វើឡើងដោយចេតនាទេ? អ៊ីចឹងធាតុទាំងអស់ហ្នឹងវានៅតែជាធាតុផ្សំបី ដែលយើងខ្ញុំបានលើកឡើង គឺស្ថានទម្ងន់ ការឈឺចាប់ និងចេតនា។

[១៤:៥១:២៨]

ឥឡូវខ្ញុំនិយាយអំពីការបាត់ខ្លួន។ ស្របទៅនឹងចំណុចដែលខ្ញុំបានលើកឡើង នៅពេលដែលយើងប្រើប្រាស់ពាក្យថា "ការបាត់ខ្លួនដោយបង្ខំ" គឺថាយើងត្រូវតែចងចាំផងដែរថាអំពើនេះត្រូវបានយកមកចោទប្រកាន់ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើមនុស្សធម៌ដទៃទៀត។ នៅក្នុងចំណុចជាច្រើននៃការជំទាស់តវ៉ារបស់ ខៀវ សំផន សេចក្ដីសន្និដ្ឋានរបស់សាលាដំបូងទាក់ទងទៅនឹងការបាត់ខ្លួននេះ ប៉ុន្តែហាក់ដូចជាមានការយល់ច្រឡំពាក់ព័ន្ធទៅនឹងធាតុផ្សំពាក់ព័ន្ធនៃឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់។ តាមពិតទៅដោយសារតែអំពើហ្នឹង ឧក្រិដ្ឋកម្មត្រូវបានយកមកចោទប្រកាន់ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បញ្ហានៅពេលការជំនុំជម្រះថាតើ អំពើហ្នឹងវាឆ្លើយតបទៅនឹងចំណុចទាំងបីទេ? គឺស្ថានទម្ងន់ ការឈឺចាប់ និងចេតនា។ បើនិយាយអំពីធាតុផ្សំនៃការឈឺចាប់ទាក់ទងទៅនឹងការបាត់ខ្លួន គឺវាចំណុចសំខាន់ណាស់ គឺថាវាមិនមែនតែវាការឈឺចាប់ចំពោះអ្នកដែលបាត់ខ្លួននោះទេ។ សាលាដំបូងបានពន្យល់ចំណុចនេះច្បាស់ហើយនៅក្នុងសេចក្ដីសម្រេចរបស់ខ្លួនពាក់ព័ន្ធទៅនឹងមន្ទីរសន្តិសុខភ្នំក្រោល ត្រង់កថាខណ្ឌ៣១៦៤។ អ្នកទោសមិនត្រឹមតែប្រឈមទៅនឹងការបាត់ខ្លួនដោយបង្ខំ ក៏ប៉ុន្តែក៏ត្រូវប្រឈមមុខទៅនឹងស្ថានភាពមិនជាក់លាក់ ហើយការនាំខ្លួនយកចេញពីមន្ទីរសន្តិសុខ ហើយនាំខ្លួនទៅកាន់ទីកន្លែងណាមួយ ហើយមានជោគវាសនាដោយគ្មានអ្នកណាអាចដឹងបានឡើយ។ សមាជិកគ្រួសាររបស់ខ្លួន មិត្តភក្តិ អ្នកជិតដិតទាំងអស់ អ៊ីចឹងវាច្បាស់មកហើយ មិនមានការពន្យល់ណាមួយមកដល់ពួកគាត់។ ហើយចំណុចទាំងអស់នេះវាកន្លងមកជាង៣០ឆ្នាំ ៤០ឆ្នាំមកហើយ អ៊ីចឹងពាក់ព័ន្ធ -- ឬក៏ថាមិនបានផ្ដល់ព័ត៌មានណាមួយ ហើយមិនមានអ្នកណាដឹងថាអ្នកទាំងអស់ហ្នឹងត្រូវបានគេនាំខ្លួនទៅកាន់សេចក្ដីស្លាប់នោះទេ។

[១៤:៥៣:៤៧]

សេចក្តីឈឺចាប់របស់អ្នកដែលនៅរស់នេះ ក៏បានកត់សម្គាល់ គាត់ក៏បានឆ្លងកាត់បទពិសោធន៍នៅការដ្ឋាន និងនៅតាមសហករណ៍។ ដើមបណ្តឹងរដ្ឋប្បវេណី យ៉ែម ឃុនទី បានផ្តល់សក្ខីកម្មអំពីម្តាយរបស់គាត់ ហើយនិងសមាជិកគ្រួសាររបស់គាត់ដទៃទៀតត្រូវបានគេនាំខ្លួនយកចេញទៅបាត់តាមរយៈឡានកាំម៉ុងនៅស្រុកត្រាំកក់ លោកស្រីបានផ្តល់សក្ខីកម្មអំពីការឈឺចាប់របស់គាត់។ សូមដកស្រង់៖ “ខ្ញុំមិនដឹងថាមានអ្វីកើតឡើង ឬក៏ជោគវាសនារបស់គាត់យ៉ាងណា ពួកគាត់យ៉ាងណាទេ តើពួកគាត់ឈឺ ឬពួកគាត់ត្រូវបានបញ្ជូនទៅកន្លែងណាផ្សេង? តើពួកគាត់បាត់ខ្លួនទាំងអស់នោះដោយសារតែឈឺ ឬក៏យ៉ាងណានេះ? ក្នុងឯកសារ E1/287.1 បន្ទាប់ពីម៉ោង ១៥:៤៩:៤៩វិនាទី។ អ៊ីចឹងផ្នែកសំខាន់នៃការឈឺចាប់ដែលទទួលរងដោយសមាជិកគ្រួសារ ដោយសហគមន៍ ដោយមិត្តភក្តិ ដោយអ្នកណាពាក់ព័ន្ធទៅនឹងអ្នកដែលបានបាត់ខ្លួននេះ។ ខ្ញុំលើកឡើងចំណុចនេះដោយសារវាច្បាស់ហើយថា ដើម្បីឈានដល់ការផ្តន្ទាទោសខៀវ សំផន គឺមិនតម្រូវឱ្យបង្ហាញអំពីការបាត់ខ្លួនបុគ្គលទាំងអស់នេះទេ។ យើងក៏មិនតម្រូវថាតើ ពួកគាត់ទាំងអស់ហ្នឹងត្រូវបានគេយកទៅសម្លាប់ ឬក៏យកទៅឃុំខ្លួន ឬក៏ស្លាប់ដោយហេតុផលណាមួយនោះទេ។ តែផ្ទុយទៅវិញ ការឈឺចាប់ហ្នឹងវាកើតមានឡើងដោយសារតែជោគវាសនារបស់បុគ្គលទាំងអស់នេះ អត់មានអ្នកណាដឹងថាគាត់បាត់ទៅណា! លើសពីនេះទៅទៀត ខៀវ សំផន គឺថាគាត់បានជំទាស់តវ៉ាទៅការផ្តន្ទាទោសរបស់គាត់ពាក់ព័ន្ធទៅនឹងការបាត់ខ្លួនដោយសំអាងទៅលើថា ជោគវាសនាអ្នកទាំងអស់ហ្នឹងមិនត្រូវបានគេបង្ហាញឱ្យដឹងទេ។ ឧទាហរណ៍នៅក្នុងមូលដ្ឋាន១៣៥ ត្រង់កថាខណ្ឌ ៨៨៨(ក)(ខ) គាត់ជំទាស់តវ៉ាការផ្តន្ទាទោសមកលើរូបគាត់ទាក់ទងទៅនឹងការបាត់ខ្លួននៅមន្ទីរសន្តិសុខភ្នំក្រោល ពាក់ព័ន្ធទៅនឹងភស្តុតាងដោយសារតែអតីតអ្នកទោស ហើយគាត់ថាព័ត៌មានហ្នឹងវាងអាចជាពាក្យចចាមអារ៉ាមទេ។

[១៤:៥៦:១៦]

ក្រៅពីការបកស្រាយខុសទៅលើទស្សនៈស្តីអំពីភស្តុតាងចចាមអារ៉ាមនេះ អង្គជំនុំជម្រះសាលាដំបូង បានសម្រេចហើយពាក់ព័ន្ធទៅនឹងជោគវាសនារបស់លោកទាំងអស់នោះ។ អង្គជំនុំជម្រះសាលាដំបូង ក៏បានធ្វើការសម្រេចអំពីធាតុផ្សំនៃឧក្រិដ្ឋកម្ម អំពើអមនុស្សធម៌ដទៃទៀតដោយមិនដឹងអំពីជោគវាសនារបស់គេ។ ពួកគាត់ទាំងអស់ប្រឈមទៅនឹងភាពរន្ធត់ ហើយពួកគាត់ក៏បានឆ្លងកាត់បទពិសោធន៍ឈឺចាប់។ ខៀវ សំផន ក៏បានលើកឡើងថា មានកំហុសនៅក្នុងមូលដ្ឋានបណ្តឹងសាទុក្ខ មូលដ្ឋាន១១១

ត្រង់កថាខណ្ឌ៧៥៦ ជាពិសេសពាក់ព័ន្ធទៅនឹងការបាត់ខ្លួនប្រជាជនវៀតណាមពីស្រុកត្រាំកក់។ ហើយគាត់បានលើកឡើងពីសេចក្ដីសន្និដ្ឋានរបស់សាលាដំបូងថា ពីជនជាតិវៀតណាមទាំងអស់ហ្នឹង សុំដកស្រង់៖"អាចត្រូវបានបញ្ជូន ខ្លួន និង/ឬក៏ត្រឡប់ទៅវិញ"។ ទឡ្ហីករណ៍នេះហាក់បីដូចជាបង្ហាញឲ្យឃើញថា ជោគវាសនារបស់ជនជាតិវៀតណាមទាំងអស់នេះមិនសុទ្ធតែត្រូវបាននរណាបានដឹងទេ។ អ៊ីចឹងអាចចាត់ទុកថា វាអាចជាវិមតិសង្ស័យ។

នៅក្នុងមូលដ្ឋាន១២៧ ត្រង់កថាខណ្ឌ៨៣៧ ដល់៨៤០ ខៀវ សំផន ខកខានមិនបានចង្អុលបង្ហាញពីកំហុសនេះទេ។ គាត់ជំទាស់តវ៉ាថា -- ជាពិសេសការបាត់ខ្លួនពីមន្ទីរសន្ដិសុខក្រាំងតាចាន់។ គាត់និយាយថា ឧក្រិដ្ឋកម្មស្ដីអំពីការបាត់ខ្លួនដោយបង្ខំ គឺជាឧក្រិដ្ឋកម្មដែលបន្តកើតជាហូរហែ ដែលមិនមែនត្រឹមតែប្រព្រឹត្តពីរដងទេពាក់ព័ន្ធទៅនឹងបុគ្គលម្នាក់នោះ។ អ៊ីចឹងសេចក្ដីសន្និដ្ឋានសំអាងទៅលើការអនុវត្តធាតុផ្សំនៃឧក្រិដ្ឋកម្មនេះតែមួយដែលមិនបាន -- ការបាត់ខ្លួនដែលថា -- ហើយ ខៀវ សំផន នោះគឺមិនត្រូវបានផ្ដន្ទាទោស ឬក៏ចោទប្រកាន់ចំណុចនេះទេ។

[១៤:៥៨:២៨]

ជាថ្មីម្ដងទៀត វាពាក្យចចាមអារ៉ាមនោះគឺថា ការឈឺចាប់វាមិនមែនកើតមានឡើងទៅលើអ្នកបាត់ខ្លួនទេ ប៉ុន្តែចំពោះអ្នកដែលនៅជុំវិញខ្លួនដែល គឺថាគាត់មានការភ័យរន្ធត់តក់ស្លុត។ អ៊ីចឹងគឺថាវាអាចសមស្របទាំងស្រុងសម្រាប់ដែលជាពិសេសកើតមានឡើងទៅលើសមាជិកគ្រួសារ ក៏ដូចសហគមន៍របស់ខ្លួននៅក្នុងសហករណ៍ត្រាំកក់ ហើយក្រោយមកទៀតសហការីនៅគុកក្រាំងតាចាន់។ កំហុសជាធម្មតានៅក្នុងមូលដ្ឋានទាំងអស់នេះគឺការខកខានមិនបាន កំណត់អំពីឧក្រិដ្ឋកម្មតាមរយៈមូលដ្ឋានធាតុផ្សំចំនួនបីនៃឧក្រិដ្ឋកម្មទាំងបីនេះ គឺស្ថានទម្ងន់ ការឈឺចាប់ និងចេតនា។ អ៊ីចឹងអមនុស្សធម៌នេះ គឺត្រូវបានធ្វើឡើងពាក់ព័ន្ធទៅនឹងការបាត់ខ្លួនប្រជាជនដ៏ច្រើនពីស្រុកត្រាំកក់ ពីមន្ទីរសន្ដិសុខក្រាំងតាចាន់ ក៏ដូចជាទីតាំងដទៃទៀតដែរ។ ហើយការផ្ដន្ទាទោស ខៀវ សំផន សម្រាប់ចំពោះឧក្រិដ្ឋកម្មទាំងអស់នេះត្រូវតែតម្កល់ទុក។

នេះជាសេចក្ដីសន្និដ្ឋានបញ្ចប់នៃសារណាផ្ទាល់មាត់របស់យើងខ្ញុំ ហើយខ្ញុំសុំប្រគល់វេទិការនេះទៅលោក ពេជ អង្គ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមសម្រាកបន្តិច! លោកសហមេធាវីនាំមុខ ទុកឲ្យអ្នកបច្ចេកទេសប្ដូរឌីវីឌីបន្តិចសិនបាទ។

*(សម្រាករយៈពេលខ្លី ប្តូរឌីវីឌី)*

[១៥:០០:៣៤]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញចាប់ផ្តើម។

**លោក ពេជ អង្គ៖**

បាទ សូមគោរពឯកឧត្តមប្រធានអង្គសវនាការ ឯកឧត្តម លោក លោកស្រី ដែលជាចៅក្រមប្រឹក្សា តំណាងសហព្រះរាជអាជ្ញា ភាគីការពារជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ និងសាធារណជន។ ខ្ញុំបាទ ពេជ អង្គ សូមលើកពាក់ព័ន្ធទៅនឹងបញ្ហាដែលមេ -- បណ្តឹងរបស់មេធាវីរបស់លោក ខៀវ សំផន បានលើកអំពីករណីដែលថា ចៅក្រមនៃសាលាដំបូងបានពិចារណាដោយមិនត្រឹមត្រូវទៅលើធាតុផ្សំនៃបទល្មើសពាក់ព័ន្ធទៅនឹងករណីអាពាហ៍ពិពាហ៍ដោយបង្ខំ។ ខ្ញុំសូមលើកបីចំណុច៖ ចំណុចទី១ ពាក់ព័ន្ធទៅនឹងធាតុច្បាប់ ចំណុចទី២ ពាក់ព័ន្ធទៅនឹងការព្រមព្រៀង ចំណុចទី៣ ពាក់ព័ន្ធទៅនឹងភាពធ្ងន់ធ្ងរនៃអំពើ និងការឈឺចាប់របស់ជនរងគ្រោះ ដើមបណ្តឹងរដ្ឋប្បវេណី។

មេធាវីលោក ខៀវ សំផន បានលើកថា គ្មានទេធាតុច្បាប់ គ្មានច្បាប់ចែងអំពីករណីជាបទល្មើសទេ ហើយបានលើកនិយាយ -- បាននិយាយថា មិនអាចធ្វើការបែងចែកពីគ្នារវាងអំពើអាពាហ៍ពិពាហ៍ដោយបង្ខំ និងករណីរំលោភនៅក្នុងគ្រួសារ។ ហើយដោយសារថាគ្មានការកំណត់ថាជាបទល្មើសចំពោះអំពើនៃការរំលោភរវាងប្តីប្រពន្ធ អំពើនៃអាពាហ៍ពិពាហ៍ដោយបង្ខំ ក៏មិនអាចមានផងដែរ។

យើងខ្ញុំសូមបញ្ជាក់ថា ច្បាប់របស់ព្រះរាជាណាចក្រកម្ពុជានៅមុនសម័យកម្ពុជាប្រជាធិបតេយ្យ ជាពិសេសក្រមព្រហ្មទណ្ឌនៃឆ្នាំ១៩៥៦ បានចែងអំពីករណីនេះ ហើយបានចែងថា ជាករណីកំហែងរួមបវេណីដល់ទីជម្រៅ។ ត្រង់មាត្រា៤៤៣ ដោយនិយាយមិនមានករណីលើកលែងចំពោះប្តីប្រពន្ធ ហើយក៏គ្មានមាត្រាណាមួយនៃក្រមនេះចែងថាមានករណីលើកលែងថា ប្តីអាចរំលោភប្រពន្ធ ហើយគ្មានច្បាប់ចែងនោះដែរ។ មាត្រា៤៤៣ បាននិយាយថា ជនណាដែល -- ពាក្យកន្លែងនេះមានន័យថា គ្រប់បុគ្គលដែលរំលោភទៅលើបុគ្គលផ្សេងទៀត ហើយក៏គ្មានករណីលើកលែងផងដែរ។

[១៥:០៣:៣៨]

ចំពោះបញ្ហាដែលថា ពេលនោះគ្មានច្បាប់អន្តរជាតិចែងអំពីករណីរំលោភរវាងប្តីប្រពន្ធ ឬក៏ច្បាប់ប្រទេសផ្សេងៗទៀតគ្មានចែងអំពីករណីនេះ។ មេធាវីការពារជនជាប់ចោទបានលើកករណីច្បាប់

ជាច្រើន ហើយខាងសហព្រះរាជអាជ្ញាក៏លើកអំពីបញ្ហានេះ ខ្ញុំនឹងមិនលើកអំពីបញ្ហានេះដើម្បីចំណេញពេល ហើយក៏មិនចង់ឲ្យជាន់ជាមួយអ្វីដែលសហព្រះរាជអាជ្ញាបានលើកផងដែរ។

មួយទៀតពាក់ព័ន្ធទៅនឹងបញ្ហាដែលថា អាពាហ៍ពិពាហ៍ដោយការផ្សំផ្គុំ ហើយនិងអាពាហ៍ពិពាហ៍ដែលរៀបចំឡើងដោយកម្ពុជាប្រជាធិបតេយ្យគឺតែមួយ គ្មានអ្វីខុសគ្នានោះទេ។ ត្រង់ចំណុចនេះក្រុមការពារក្ដីបានលើកថា ការរៀបចំឲ្យរៀបការមិនអាចជាឧក្រិដ្ឋកម្មនោះទេ ពីព្រោះការមានដ៏ច្រើននៃការរៀបការដោយផ្សំផ្គុំដោយឪពុកម្ដាយ ហើយអង្គការគ្រាន់តែជាអ្នកដើរតួនាទីជំនួសឪពុកម្ដាយតែប៉ុណ្ណោះ។

ទី១ ខ្ញុំសូមជម្រាបថា ក្របខ័ណ្ឌច្បាប់នៅកម្ពុជា ដែលខ្ញុំលើកអម្បាញ់មិញពាក់ព័ន្ធទៅនឹងច្បាប់ព្រហ្មទណ្ឌ តែនៅក្នុងរឿងច្បាប់រដ្ឋប្បវេណី ក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ ត្រង់មាត្រា១១៤ ក៏បានផ្ដល់និយមន័យនៃការរៀបអាពាហ៍ពិពាហ៍ថា ជាការព្រមព្រៀង ជាការប្រកាសឱឡារិកថាពួកគាត់ប្ដេជ្ញារួមរស់ជាមួយគ្នា ដែលជាការសម្ដែងនូវការព្រមព្រៀងរវាងមនុស្សប្រុស និងមនុស្សស្រីនៅក្នុងការទទួលគ្នារៀបការជាមួយគ្នា ហើយគ្មានកន្លែងណាមួយនៃក្រមរដ្ឋប្បវេណីបាននិយាយថា ត្រូវតែមានការព្រមព្រៀងពីឪពុកម្ដាយ ឬក៏និយាយថា ឪពុកម្ដាយមានសិទ្ធិនៅក្នុងការបង្ខំកូនឲ្យរៀបការជាមួយអ្នកណាបានឡើយ។ គ្មានកន្លែងណាមួយនៃបទប្បញ្ញត្តិនៃរដ្ឋប្បវេណីនិយាយយ៉ាងដូច្នេះឡើយ លើកលែងតែករណីអនីតិជនដែលជាអាចកម្មវត្ថុនៃអត្ដាធីនភាព ហើយដែលឪពុកម្ដាយដែលកូនមានអាយុក្រោម --អាយុនៅក្នុងការរៀបការបន្តិចបន្តួច ហើយឪពុកម្ដាយអាចអនុញ្ញាតឲ្យមានការរៀបការតែប៉ុណ្ណោះ ក្រៅពីនោះគ្មានកន្លែងណាមួយនៃក្រមរដ្ឋប្បវេណីតម្រូវថា ត្រូវមានការយល់ព្រមពីឪពុកម្ដាយទាល់តែសោះ។

ហើយការនិយាយថា ការរៀបការផ្សំផ្គុំដោយឪពុកម្ដាយគឺជាវប្បធម៌នៃកម្ពុជាពីមុន ហើយអង្គការគ្រាន់តែដើរតួនាទីជំនួសឲ្យឪពុកម្ដាយនេះ គឺមិនអាចប្រៀបធៀបគ្នាបានទេរវាងអ្វីដែលជាវប្បធម៌របស់កម្ពុជា ហើយនិងអ្វីដែលជាការធ្វើរបស់អង្គការដែលជាការបង្ខំឲ្យរៀបការ។

[១៥:០៦:៣២]

ចំពោះពាក្យវប្បធម៌នេះ ខ្ញុំសូមជម្រាបថា វាមិនមែនជាវប្បធម៌ល្អ ឬក៏មិនមែនជាវប្បធម៌ បើនិយាយឲ្យចំទៅមិនមែនជាវប្បធម៌ទេនៅក្នុងការបង្ខំកូនឲ្យរៀបការ វាគឺជាការអនុវត្តដែលជាក់លាក់ដែលមានមួយចំនួននៅមុនសម័យកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះ ហើយដែលការអនុវត្តនេះជាការអនុវត្ត

មិនល្អ ហើយដែលយើងមិនអាចចាត់ទុកថា ជាច្បាប់ទម្លាប់របស់ប្រជាជនកម្ពុជានៅក្នុងការតម្រូវឲ្យកូនរៀបការដោយឪពុកម្តាយយូរហើយ។ ហើយម៉្យាងទៀត វប្បធម៌នោះគឺវាខុសអំពីការបង្ខំឲ្យរៀបការយ៉ាងដូចម្តេច? នៅក្នុងវប្បធម៌កម្ពុជា គឺឪពុកម្តាយគឺជាអ្នកជួយមើលកូន ជាអ្នកផ្តល់យោបល់ទៅកូន ជាអ្នកស្រឡាញ់កូន ហើយគាត់មិនៗឲ្យកូន -- គាត់មើលថាតើសេចក្តីសុខរបស់កូននោះយ៉ាងណា? នៅចំពោះមុខដែលការបង្ខំរួមសេពសេន្ថវៈពីប្តី គឺឪពុកម្តាយគាត់មានការឈឺចាប់ ជាការឈឺឆ្អាល គាត់មិនបង្ខំកូនឲ្យរៀប រួមផ្សំសេពសន្ថវៈនោះឡើយ។

ហើយការរៀបការនៅក្នុងវប្បធម៌កម្ពុជា គឺជាតម្លៃមួយដ៏ខ្ពង់ខ្ពស់របស់ប្រជាជនកម្ពុជា ដោយប្រជាជនកម្ពុជាចង់ឃើញផ្កាស្លា នារីរបស់កម្ពុជា ឬក៏បុរសកម្ពុជាចង់ឃើញផ្កាស្លាដែល -- ហើយចង់មានការចូលរួម ចង់មាន -- ទទួលបាននូវប្រពៃណីដែលត្រូវបានអនុវត្តនៅក្នុងពេលដែលខ្លួនរៀបការហើយវាជាប្រពៃណីដ៏ល្អរបស់កម្ពុជា។ វាមិនមែនជាការបង្ខំនោះឡើយ ហើយការចូលរួមរបស់ញាតិមិត្ត ដែលជាការផ្តល់កិត្តិយសដល់គ្រួសារដែលជាអ្នករៀបការគឺមានតម្លៃខ្លាំងណាស់។ ចំពោះអង្គការមិនដូចគ្នាទេ។ ក្រៅអំពីពេលបន្ទាប់ពីបានកាន់កាប់អំណាច អង្គការបានប្លន់ផ្ទះ ប្លន់ទ្រព្យសម្បត្តិ រហូតទៅដល់ផ្ទាល់ប្លន់សិទ្ធិនៅក្នុងការគ្រប់គ្រងអំ -- ទៅលើកូនចៅ ប្លន់អំណាចមេបាពីឪពុកម្តាយថែមទៀតក្រៅពីនោះអង្គការតម្រូវឲ្យមានការរួមភេទ តម្រូវឲ្យ បើនារីមិនព្រម ឲ្យបុរសរំលោភទៅលើនារី។ ហើយរហូតទៅដល់ការមិនព្រមចំពោះការរៀបការនេះ មានទណ្ឌកម្ម ការអប់រំរហូតទៅដល់មានការបាត់ខ្លួនរហូតទៅដល់ការស្លាប់ យកទៅសម្លាប់ជាដើម។

ហើយមានការតម្រូវឲ្យមានការទៅលបស្តាប់ថា តើនារី ហើយនិងបុរសដែលដែលបានរៀបការជាមួយគ្នានោះ ដែលត្រូវកំណត់ឲ្យប្តេជ្ញាចិត្តជាមួយគ្នានោះ ថាតើគាត់រួមបវេណីឬអត់? ការលបស្តាប់នេះគ្មានទេក្នុងប្រពៃណីល្អរបស់ខ្មែរ។

[១៥:០៩:៤៤]

មេធាវីការពារក្តីបានលើកថា គ្មានទេ -- គ្មានភស្តុតាងថា ប្តីប្រពន្ធមិនព្រមព្រៀងនៅក្នុងការរៀបអាពាហ៍ពិពាហ៍ រៀបការជាមួយគ្នាក្នុងពេលដែលរៀបការដោយអង្គការនោះទេ។ ខ្ញុំនឹងលើកយកចំណុចមួយចំនួនដែលថា ជាការពិតគឺបង្កើតឲ្យមានបរិយាកាសភ័យខ្លាចនៅក្នុងការរៀបការនៅសម័យនោះ។ តាមការពិត ការព្រមព្រៀងគឺគ្មានទេ គឺមានតែការភ័យខ្លាច ហើយគាត់បង្ខំចិត្តនៅក្នុងការរៀបការបង្ខំចិត្តនៅក្នុងការប្តេជ្ញាចិត្តរស់ជាមួយគ្នាជាប្តីប្រពន្ធ។ ខ្ញុំសូមលើកឧទាហរណ៍អំពីករណីដើមបណ្តឹង

រដ្ឋប្បវេណី ជឹម សាមឿន។ គាត់បានលើកថា គាត់ត្រូវបានគេគំរាមកំហែងដោយប្រាប់ថា “ប្រសិនបើលោកស្រីបដិសេធមិនព្រមរៀបការទេ លោកស្រីនឹងមិនអាចយកបុរសណាធ្វើជាប្តីឡើយ ហើយថា ប្រសិនបើលោកស្រីត្រូវបានគេឃើញថា ញញឹមដាក់បុរសណាផ្សេង លោកស្រីនឹងត្រូវគេសម្លាប់” ឯកសារ E1/321.1។ ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុខឿន បានបញ្ជាក់ថា “ប្រសិនបើនរណាម្នាក់មិនគោរពតាមបញ្ជាអង្គការ ពួកគេនឹងត្រូវបានសម្លាប់ចោលដូចសត្វធាតុ”។ លោកស្រីត្រូវបានគេគំរាមកំហែងថា “បើមិនរៀបការទេ លោកស្រីនឹងត្រូវគេយកទៅដាក់គុក ឬក៏យកទៅសម្លាប់” ឯកសារ E1/487.1។ ដូចគ្នាដែរ ដើមបណ្តឹងរដ្ឋប្បវេណី ជា ឌៀប បានបញ្ជាក់ថា បន្ទាប់ពីការបដិសេធពីរបីដងរួចមកលោកស្រីត្រូវបានគេបញ្ជូនទៅធ្វើការនៅកន្លែងផ្សេង។ ហើយលោកស្រីគិតថា លោកស្រីមិនអាចបដិសេធមិនរៀបការបន្តទៀតបានទេ។ ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន ត្រូវបានក្រុមឈ្លបចាប់រំលោភក្រោយពីលោកស្រីបានបដិសេធមិនរៀបការ។ ពីរបីថ្ងៃបន្ទាប់ពីគេរំលោភ គាត់ក៏រៀបការ ហើយលោកស្រីបាននិយាយថា ខ្ញុំនៅតែត្រូវរៀបការព្រោះគេគំរាមខ្ញុំ ត្រូវតែរៀបការ។ ហើយរឿងរ៉ាវដែលកើតឡើងនោះ គេថា បើសិនជាខ្ញុំនិយាយគឺស្លាប់។ សំដៅទៅលើការដែលគេរំលោភគាត់។ ខ្ញុំមិនរៀបការក៏ស្លាប់ ខ្ញុំខ្លាចស្លាប់ ដើម្បីកូនខ្ញុំ ខ្ញុំសុខចិត្តរៀបការទាំងទឹកភ្នែកតែម្តង។ ដើមបណ្តឹងរដ្ឋប្បវេណី លោកស្រី ជា ឌៀប បានផ្តល់សក្ខីកម្មថា លោកស្រីបានរួមរស់ជាមួយប្តីលោកស្រី ដោយសារតែលោកស្រីខ្លាចគេធ្វើ គេចោទថា លោកស្រីធ្វើខុសសីលធម៌ ឬក្បត់ ឯកសារE1/466.1។ លោកស្រី បានបញ្ជាក់ថា លោកស្រីត្រូវបានគេតាមដាន ហើយលោកស្រីមានការភ័យខ្លាចទាំងប្តី ហើយក៏ខ្លាចឈ្លបទៀតផង។ លោកស្រីបានបន្ថែមថា មនុស្សបានបាត់ខ្លួនដោយសារតែប្រព្រឹត្តខុសសីលធម៌។ ខ្ញុំអត់ដែលឃើញទេ តាំងពីសួរហ្នឹងឮថា សីលធម៌ ហើយសីលធម៌បាត់ខ្លួន។ ចំពោះខ្លួនខ្ញុំផ្ទាល់ក៏មិនបានឃើញដែរ គ្រាន់តែឮថា តែសីលធម៌គឺបាត់ខ្លួនហើយ។

[១៥:១៣:៤៤]

ចំណុចចុងក្រោយដែលខ្ញុំលើកចំពោះចំណុចនេះ គឺលោកស្រីអ្នកជំនាញ កាស៊ូមិ ណាហ្កាការ៉ាបានផ្តល់សក្ខីកម្មថា ប្រជាជនបានដឹងថា ការមិនព្រមរៀបការអាចត្រូវបានគេសម្លាប់។ ដូច្នេះពួកគេមិនហ៊ានបដិសេធទេ ឯកសារ E1/472.1។

អង្គជំនុំជម្រះជាទីគោរព! សាលាដំបូងបានយល់ឃើញថា ភស្តុតាងភាគច្រើនលើសលប់បង្ហាញថា ពួកគេមិនបដិសេធក្នុងការរៀបការក៏ដោយសារតែមានការបង្ខំ មានការភ័យខ្លាច នៅទោះ --

ថានៅក្នុងទីកន្លែងណានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យគឺមានលក្ខណៈដូចគ្នា។ ដូច្នេះពួកគាត់គ្មានជម្រើសអ្វីក្រៅអំពីការសម្រេចចិត្តរៀបការនោះឡើយ។ ចំពោះបញ្ហាថាតើ ការរៀបការដោយបង្ខំនោះមានលក្ខណៈធ្ងន់ធ្ងរឬទេ? កន្លែងនេះ មេធាវីការពារក្តីលើកថា វាមិនមានលក្ខណៈធ្ងន់ធ្ងរទេ ក៏ប៉ុន្តែយើងសូមលើកថា វាមានលក្ខណៈធ្ងន់ធ្ងរណាស់ ហើយដែលត្រូវតែចូលជាករណីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រង់ចំណុចអំពើផ្សេងទៀត។ ខ្ញុំលើកអំពីករណីដើមបណ្តឹងរដ្ឋប្បវេណី គល់ ណែម លោកបានផ្តល់សក្ខីកម្មថា លោកមានក្តីបារម្ភខ្លាំងណាស់ដោយទិដ្ឋភាពនៃការបង្ខំឱ្យរៀបការ ដល់ថ្នាក់លោកហូបបាយមិនចូល ហើយលោកនិយាយថា លោកបានយល់ព្រមគឺដើម្បីរស់តែប៉ុណ្ណោះ។ ដើម្បីមើលមេឃមើលផ្កាយម្តងទៀត។ នេះគឺជាកម្រិតដ៏ធ្ងន់ធ្ងរមួយដែលមិនអាចទទួលយកបាន។

[១៥:១៥:៤៨]

លើសពីនេះទៅទៀត ដើមបណ្តឹងរដ្ឋប្បវេណី កែវ ធារី ក៏បញ្ជាក់ផងដែរថា លោកស្រីខ្លាចនៅក្នុងពេលដែលលោកស្រីនិយាយឆ្លើយទៅនឹងអ្នកស៊ើបសួរ ដែលសួរអំពីការអាពាហ៍ពិពាហ៍ដោយបង្ខំរបស់គាត់។ ហើយរហូតដល់គាត់មានការលំបាកនៅក្នុងការនិយាយ គាត់មានការអៀនខ្មាស់នៅក្នុងការនិយាយអំពីបញ្ហាដែលគាត់ត្រូវរួមដំណេកជាមួយនឹងអ្នកដែលសួរគាត់។ នេះគឺជាចំណុចដែលបញ្ជាក់អំពីភាពធ្ងន់ធ្ងរនៃអំពើ ឬក៏អារម្មណ៍របស់ជនរងគ្រោះ ដែលទទួលរងដោយការបង្ខំឱ្យរៀបការ។ ដើមបណ្តឹងរដ្ឋប្បវេណី យស់ ផល ក៏បាននិយាយអំពីការឈឺចាប់របស់គាត់ដែលគាត់មានគូដណ្តឹងរួចទៅហើយ មានបំណងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា មានអនុស្សាវរីយ៍ជាច្រើនជាមួយគ្នា ហើយទីបញ្ចប់លោកត្រូវបានបង្ខំឱ្យរៀបការជាមួយគ្នាក្នុងពេលនេះ។ នេះជាការឈឺចាប់ដ៏ច្រើន។ លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី ប្រាក់ សុខឿន បានលើកថា ហើយចំណុចមួយទៀត គឺក្រោយមកខ្ញុំរៀបការ ចាសយកខ្ញុំទៅរៀបការហើយឱ្យខ្ញុំ បង្ខំខ្ញុំឱ្យរួមរក្សទាំងឈឺចាប់ ដែលខ្ញុំមិនពេញចិត្ត ដែលខ្ញុំមិនចង់ឱ្យខ្ញុំចុកចាប់ក្នុងផ្លូវចិត្ត ចុកចាប់ក្នុងរូបរាងកាយ ខ្ញុំផង។ លោក មាន លឿយ ដែលជាដើមបណ្តឹងរដ្ឋប្បវេណីបានលើកថា ហេតុអ្វីបានជាអង្គការបង្ខំឱ្យមនុស្សរៀបការជាហ្វូងៗហើយពួកលោកមិនដែលស្គាល់ហើយមិនស្គាល់គ្នាទាល់តែសោះនោះ ហើយតម្រូវឱ្យយើងស្រឡាញ់គ្នា។ លោកស្រី ប៉ាន់ សុចាន់ ដែលត្រូវបានតម្រូវឱ្យរៀបការទាំងលោកស្រីមិនដែលមានរដូវទាល់តែសោះ ហើយដែលលោកស្រីបដិសេធនៅក្នុងការរួមភេទ ហើយជាទីបញ្ចប់ នៅយប់ទី៣ ត្រូវបានកងឈ្លបតម្រូវឱ្យប្តីរបស់លោកស្រីរំលោភលោកស្រី ដែលកងឈ្លបបានចងលោកស្រីនឹងសសរ ហើយបន្ទាប់មកលោកស្រីរត់ៗ ហើយលោកស្រី

មានការឈឺចាប់ជាខ្លាំង លោកស្រីមិនដែលមានរដូវទេ តែទីបំផុត លោកស្រីបានធ្លាក់ឈាមរហូតទៅដល់មួយខែជាងឯណោះ។ ហើយនេះឬដែលអ្វីដែលមេធាវីការពារក្ដីនិយាយថា ជនរងគ្រោះមិនមានការឈឺចាប់ទេ។

បាទសូមឯកឧត្ដមប្រធាន ខ្ញុំសូមអនុញ្ញាត ៣នាទី បើឯកឧត្ដមប្រធានអនុញ្ញាត។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទសូមអញ្ជើញ!

[១៥:១៨:៤៨]

**លោក ពេជ អង្គ៖**

សូមអរគុណឯកឧត្ដមប្រធាន។ ចំពោះបញ្ហាផ្សេងទៀត មេធាវីការពារក្ដីបានលើកថា អង្គជំនុំជម្រះសាលាដំបូងមិនបានពិនិត្យអំពីករណីឈឺចាប់តិចតួចរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ហើយថា ជាករណីធ្ងន់ធ្ងរ។ ខ្ញុំសូមលើកថា អ្វីដែលមេធាវីការពារក្ដីបានលើកនោះ គឺជាការមើលឃើញចំណុចមួយផ្នែកនៃសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ឬក៏ភស្ដុតាងឯកសាររបស់ដើមបណ្ដឹងរដ្ឋប្បវេណីតែប៉ុណ្ណោះ។ គួរតែមើលទិដ្ឋភាពទូទៅ រាល់ឯកសារទាំងអស់ដែលដើមបណ្ដឹងរដ្ឋប្បវេណីបានលើក។ ចំពោះករណីដើមបណ្ដឹងរដ្ឋប្បវេណី មុំ វុន មេធាវីការពារក្ដីបាននិយាយថា ការរៀបការរបស់គាត់គឺគ្មានអ្វីធ្វើឱ្យគាត់ឈឺចាប់ធំដុំឡើយ។ ការអះអះនេះ មិនគិតដល់ថា អំពីអ្វីដែលដើមបណ្ដឹងរដ្ឋប្បវេណីបាននិយាយទាំងអស់នៅក្នុងពេលសវនាការ ហើយនៅក្នុងឯកសាររបស់គាត់ទេ។ លោកស្រី មុំ វុន បានលើកថា គាត់មានភាពអាម៉ាសជាខ្លាំងនៅក្នុងអាពាហ៍ពិពាហ៍របស់គាត់។ គាត់មានការភ័យខ្លាចនៅក្នុងការបដិសេធ ហើយគាត់ខ្លាចគេសម្លាប់។ ហើយទាំងអស់នេះ គឺជាការបង្ហាញនូវការឈឺចាប់របស់គាត់ ហើយចំពោះដើមបណ្ដឹងរដ្ឋប្បវេណី វ៉ា លឹមហាន់ នៅក្នុងឯកសារនៃកិច្ចសម្ភាសរបស់គាត់ ក៏គាត់បាននិយាយថា គាត់ភ័យខ្លាចដោយអាជ្ញាធរ ខ្លាចអាជ្ញាធរយកគាត់ទៅសម្លាប់ផងដែរ។ ដូច្នេះហើយ ទើបគាត់រៀបអាពាហ៍ពិពាហ៍ ហើយត្រូវទ្រាំរស់នៅជាមួយប្ដីរបស់គាត់ ទោះជាមានការឈឺចាប់ក៏ដោយ។ ដូចគ្នាដែរ ចំពោះដើមបណ្ដឹងរដ្ឋប្បវេណី មាស សារ៉ាន់ នៅក្នុងរបាយការណ៍ស្ដីពីការសាកសួររបស់គាត់លេខ E3/9.736 ក៏បាននិយាយអំពីការឈឺចាប់របស់ខ្លួនផងដែរ ហើយដូចគ្នាដែរ ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ៅ គ្រឿន ក៏សុទ្ធតែបញ្ជាក់ថា ខ្លួនមានការឈឺចាប់យ៉ាងធ្ងន់ធ្ងរចំពោះការបង្ខំឱ្យខ្លួន រៀបអាពាហ៍ពិពាហ៍ផងដែរ។

ឯកឧត្ដម លោក លោកស្រីចៅក្រមជាទីគោរព ការលើកឡើងរបស់មេធាវីការពារក្ដីអំពីថា ចៅក្រមសាលាដំបូងមិនបានពិចារណាឲ្យត្រឹមត្រូវអំពីធាតុផ្សំនៃបទល្មើស អាពាហ៍ពិពាហ៍ដោយបង្ខំ នេះ មិនត្រឹមត្រូវ យើងខ្ញុំលើកថា អ្វីដែរលើកដោយមេធាវីការពារក្ដី សុទ្ធតែជាការភាន់ច្រឡំ ហើយនិង ជាការពិចារណាដែលមិនគ្រប់ជ្រុងជ្រោយ។ អ្វីដែលលើកឡើងនេះ គឺជាការពិត ធាតុផ្សំនៃច្បាប់មានដូច ខាងសហព្រះរាជអាជ្ញាបានលើក ហើយយើងខ្ញុំក៏លើកតាមច្បាប់កម្ពុជាក៏មានដែរ។ ហើយការរៀបការ នៅសម័យខ្មែរក្រហម គឺជាការរៀបការដោយប៉ះពាល់ទៅដល់សេរីភាពនៅក្នុងការសម្រេច ហើយនិង មានភាពប៉ះពាល់ធ្ងន់ធ្ងរទៅដល់ដើមបណ្ដឹងរដ្ឋប្បវេណី ហើយក៏ដូចជាជនរងគ្រោះផ្សេងទៀត ហើយ បង្កើតឲ្យមានការឈឺចាប់ដោយធ្ងន់ធ្ងរ ដែលគួរតែត្រូវចាត់ទុកថា ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រង់ ចំណុចអំពើឧក្រិដ្ឋកម្មផ្សេងទៀត។ សូមអរគុណឯកឧត្ដមប្រធាន។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងដោយសារយើងដល់ពេលសម្រាកហើយ សូមសម្រាក។ អ៊ីចឹងយើងចូលវិញនៅម៉ោង ដប់ ប្រាំហាសិប អ៊ីចឹងសូមសម្រាកបាទ។

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកនៅម៉ោង ១៥:២៣ នាទី ដល់ម៉ោង ១៥:៤៨ នាទី)*

[១៥:៤៨:២៥]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោមឈរ!

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

ជាបន្ត សូមអញ្ជើញចៅក្រមអង្គជំនុំជម្រះដើម្បីធ្វើសំណួរទៅលើភាគី។ សូមអញ្ជើញ!

**ចៅក្រម ម៉ូរីន ហាឌីង ក្លាក៖**

ខ្ញុំគិតថាតើខ្ញុំកំពុងតែគិតថាតើខ្ញុំសួរបែបណា។ ឥឡូវនេះ ខ្ញុំសួរទៅទាំងអស់ ព្រោះថាលោក លោកស្រីមួយចំនួនបានលើកឡើងអំពីទស្សនៈដែលខ្ញុំមិនដែលនឹកទៅដល់ ប្រសិនបើខ្ញុំនិយាយដដែលៗ គឺសូមកុំប្រកាន់ ប៉ុន្តែតាមដែលខ្ញុំយល់ អ្វីដែលលោក លោកស្រីមួយចំនួនធ្វើឲ្យចាប់អារម្មណ៍។ ទី១ ថា

តើអំពើមួយចំនួន ដែលឈានទៅដល់កម្រិតធ្ងន់ធ្ងរនៃអំពើអមនុស្សធម៌ដទៃទៀតនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ថា។តើតុលាការគួរគិតពិចារណាអំពីគោលការណ៍នីត្យានុកូលភាពដែរឬទេ?

លោក លោកស្រីបានជជែកអំពីចំណុចនេះ ប៉ុន្តែខ្ញុំចង់ឲ្យអស់លោក លោកស្រីជួយដល់ខ្ញុំ ហើយប្រហែលជាភាគីដទៃអាចចូលរួមបានដែរ ថាតើវាមិនគ្រប់គ្រាន់ទេឬ គ្រាន់តែពិនិត្យមើលទៅលើភាពធ្ងន់ធ្ងរនៃព្យសនកម្ម និងការឈឺចាប់នៅពេលដែលយើងកំណត់អត្តសញ្ញាណនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ធៀបជាមួយនឹងគោលការណ៍នីត្យានុកូលភាព គឺធៀបទៅនឹងអំពើ ឬក៏ការប្រព្រឹត្តនៅមន្ទីរស-២១ ឬការប្រព្រឹត្តិទៅក្នុងអំពើ -- នៅក្នុងឆ្នាំ១៩៧០ជាងហ្នឹង ថាតើខ្ញុំនិយាយអ៊ីចឹង អស់លោក លោកស្រីយល់អ្វីដែលខ្ញុំចង់សួរទេ?

[១៥:៥១:៣០]

**លោកស្រី អង់តា ហ្គីសសេះ**

លោកស្រី លោកស្រីមិនបានបញ្ជាក់ទៅថា ផ្នែកណាដែលត្រូវចាប់ផ្ដើមនោះទេ។ មេធាវី ខៀវ សំផន បានលើកឡើងបញ្ហានេះដែរ មុនគេនៅក្នុងបណ្ដឹងឧទ្ធរណ៍របស់ខ្លួន។

**ចៅក្រម ម៉ូរីន ហាឌីង ក្លាក៖**

អ៊ីចឹងខ្ញុំសូមអញ្ជើញលោកស្រីឡើងមានប្រសាសន៍តែម្ដងទៅ។

**លោកស្រី អង់តា ហ្គីសសេះ**

ខ្ញុំបាននិយាយយូរមកហើយនៅថ្ងៃនេះ ថាគោលការណ៍យុត្តធម៌នីត្យានូលភាពនោះ ត្រូវតែអនុវត្តនៅក្នុងការពិនិត្យជំពូកដែលនៅសល់ទាំងប៉ុន្មាននោះ ដែលអំពើអមនុស្សធម៌នោះ ខ្ញុំគិតថាវាសំខាន់ណាស់ក្នុងការពិនិត្យនេះ ជាពិសេសពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយនិងឧក្រិដ្ឋកម្មផ្សេងទៀតដែលទាក់ទងទៅនឹងសំណុំរឿង០០២ យើងនេះ /២ នេះ ដែល ខៀវ សំផន កំពុងប្ដឹងឧទ្ធរណ៍នេះ។

អ៊ីចឹងគោលការណ៍នីត្យានុកូលភាពនេះគឺវាធាតុសំខាន់បំផុត ពីព្រោះថាត្រូវតែយោងទៅនឹងច្បាស់ដែលអាចអនុវត្តបាននៅសម័យអង្គហេតុនោះ ដែលគេចោទប្រកាន់ពីអង្គហេតុនោះទៅគាត់។

**លោកស្រី រូថ ម៉ារី ហេគ្គ័រ៖**

សូមគោរពលោក លោស្រីចៅក្រម យើងយល់ស្របជាមួយនឹងគោលការណ៍នីត្យានុកូលភាព ដែលត្រូវអនុវត្តទៅលើឧក្រិដ្ឋកម្មដែលយើងកំពុងតែពិចារណាទាំងអស់ចំពោះអំពើអមនុស្សធម៌ដទៃទៀត។

ខ្ញុំសូមលើកឡើងថា ថាតើវាជាអំពើឧក្រិដ្ឋកម្មដែរឬអត់នៅឆ្នាំ៧៥ គឺមិនមានការជំទាស់អ្វីទាំងអស់ គឺយើងយល់ស្របទាំងអស់គ្នា។ ចំពោះអំពើជាមូលដ្ឋានវិញ ដូចដែលយើងបង្ហាញនៅក្នុងសារណារួចទៅហើយ គឺថាយើងមិនចាំបាច់កំណត់ជាបទល្មើស បទឧក្រិដ្ឋនោះទេ ហើយខ្ញុំអាចយោងទៅលើសេចក្តីប្រកាស ឬក៏នៅក្នុងចម្លើយ នៅក្នុងបណ្តឹងសាទុក្ខសំណុំរឿង០២/០១ គឺបានន័យថានិយាយថា ប្រសិនបើអំពើជាក់លាក់មួយចំនួន ដែលរកឃើញថាជាអំពើអមនុស្សធម៌ដទៃទៀតរំលោភបំពានទៅលើឧក្រិដ្ឋកម្ម ហើយមានលក្ខណៈប្រហាក់ប្រហែល ឬក៏ស្ថានទម្ងន់ប្រហាក់ប្រហែលគ្នា គឺយើងអាចចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

ដូច្នេះចំពោះសំណួររបស់លោកស្រីចៅក្រម នៅពេលដែលពិនិត្យមើលទៅលើភាពធ្ងន់ធ្ងរ ទើបយើងត្រូវវាយតម្លៃផងដែរទៅលើនីត្យានុកូលភាព។ សូមអរគុណ។

[១៥:៥៤:៣៨]

**ចៅក្រម ម៉ូរីន ហាឌីង ក្លាក៖**

មានភាគីដទៃទៀតចង់ចូលរួមឆ្លើយ សូមអញ្ជើញ!

**លោកស្រី មេហ្គិន ហ៊ីសត៍៖**

ខ្ញុំមិនមានអ្វីបន្ថែមច្រើនទេ ព្រោះសហការីរបស់ខ្ញុំនៅខាង ក.ស.ព បានឆ្លើយ ហើយយើងយល់ស្របជាមួយនឹងអ្វីដែលគាត់ឆ្លើយ។ នៅក្នុងកថាខណ្ឌ៥២០ និងបន្តបន្ទាប់ទៀងហ្នឹង គឺថាវិធីសាស្ត្រត្រឹមត្រូវ គឺជាវិធីសាស្ត្រដែលលោក លោកស្រីចៅក្រមកំពូលបានអនុវត្តរួចទៅហើយនៅក្នុងបណ្តឹង -- នៅក្នុងសាលដីកា២/១ គឺថា ទស្សនៈនៃនីត្យានុកូលភាពគឺត្រូវអនុវត្តនៅក្នុងឧក្រិដ្ឋកិច្ចប្រឆាំងមនុស្សជាតិ គឺអំពើអមនុស្សធម៌ដទៃទៀត។ ហើយធាតុផ្សំសំខាន់ទី១ ក្នុងការវាយតម្លៃ គឺការពិនិត្យមើលទៅលើអំពើដែលមានលក្ខណៈ ឬក៏មានភាពធ្ងន់ធ្ងរប្រហាក់ប្រហែលទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់នៃអំពើអមនុស្សធម៌ដទៃទៀតដែរឬអត់។ ដូច្នេះនៅពេលដែលយើងប្រើវិធីសាស្ត្រនៅក្នុងការពិនិត្យទៅលើធាតុផ្សំទាំងអស់នេះ គឺលក្ខខណ្ឌតម្រូវក្នុងការការពារ ឬក៏ក្នុងការវាយតម្លៃថាតើជនជាប់ចោទហ្នឹង គាត់មានលទ្ធភាពអាចប្រមើលមើលដឹងថាមានច្បាប់ ឬក៏អាចដឹងថាមានថាជាបទឧក្រិដ្ឋដែរ ឬក៏អត់។

[១៥:៥៦:០០]

**ចៅក្រម យ៉ា ណារិន៖**

បាទសូមអរគុណ។ ខ្ញុំមានសំណួរមួយពាក់ព័ន្ធទៅនឹងការរៀបអាពាហ៍ពិពាហ៍។ ដោយសារ

យើងឃើញថា នៅក្នុងសារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារជនជាប់ចោទបានធ្វើសារណាជាច្រើន ពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍នេះ។ ហើយគាត់អះអាងថា ការរៀបអាពាហ៍ពិពាហ៍ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺធ្វើឡើងដោយស្ម័គ្រចិត្ត មិនមានការបង្ខិតបង្ខំអ្វីទេ ហើយនេះជាគោលការណ៍របស់បក្សកុម្មុយនីស្តកម្ពុជា។ អ៊ីចឹងនៅពេលនេះ ខ្ញុំចង់ឲ្យខាងមេធាវីបញ្ជាក់បន្តិច អំពីការអនុវត្តគោលការណ៍ស្ម័គ្រចិត្តនេះ តើអនុវត្តនៅពេលណា លក្ខខណ្ឌយ៉ាងម៉េច? ដោយសារខ្ញុំស្តាប់ភាគីខាងសហព្រះរាជអាជ្ញាក៏បានលើកឡើងដែរ ហើយខាងដើមបណ្តឹងរដ្ឋប្បវេណី ក៏គាត់បានលើកឡើងដែរ គឺគាត់បដិសេធទាំងអស់អំពីគោលការណ៍ស្ម័គ្រចិត្តនេះ។ អ៊ីចឹងខ្ញុំចង់ឲ្យបង្ហាញបន្តិច ប្រសិនបើអាច តើអនុវត្តគោលការណ៍ស្ម័គ្រចិត្តតាមការអះអាងមេធាវីហ្នឹងប្រព្រឹត្តឡើងនៅពេលណា? តើភាគីទាំងពីរនេះ ដែលមុនរៀបអាពាហ៍ពិពាហ៍នេះ គាត់មានឱកាសស្ម័គ្រចិត្តនៅពេលណា? អ៊ីចឹងសូមបង្ហាញតិច ព្រោះដោយសារការអះអាងរបស់ភាគីថាមិនដែលស្គាល់មុខផង គោលការណ៍ស្ម័គ្រចិត្តវាកើតនៅពេលណា? សូមអរគុណ។

**លោកស្រី អង់តា ហ្គីសសេះ**

លោកចៅក្រម ខ្ញុំឆ្លើយសំណួរហ្នឹងជាពីរវគ្គ។ ជាបឋមទាក់ទងនឹងរឿងគោលនយោបាយ គោលការណ៍គឺថាមេធាវីយើងហ្នឹង យើងមិននិយាយពីគោលនយោបាយនោះទេ ការរៀបការនោះទេ គឺនិយាយពីបទបញ្ជាពីការរៀបការ ដូចដែលខ្ញុំបានលើកឡើងនៅក្នុងសារណាបណ្តឹងឧទ្ធរណ៍របស់យើងហើយ យើងបាននិយាយអំពីបញ្ជាពីអត្ថបទមួយចំនួន ដែលត្រូវសរសេរឡើងចេញនៅក្នុងកម្ពុជាប្រជាធិបតេយ្យ ដែលនៅក្នុងអត្ថបទទាំងអស់នោះគឺមានគោលការណ៍ទាំង១៤ គោលការណ៍សីលធម៌ទាំង ១៤ ដែលសរសេរសម្រាប់កម្ពុជាប្រជាធិបតេយ្យ ហើយគោលការណ៍នេះគេអប់រំទៅនឹងសមាជិកបក្សកុម្មុយនីស្តកម្ពុជា ហើយពេលរៀបការនោះ គឺត្រូវតែគោរពតាមគោលការណ៍ស្ម័គ្រចិត្តរបស់សាមីជនទាំងពីរនាក់ ហើយសាក្សីជាច្រើន កម្មាភិបាលច្រើនក៏បានផ្តល់សក្ខីកម្មនិយាយថាអ៊ីចឹងដែរ ថាអាទិភាពនៃការព្រមព្រៀងគ្នានេះមានមែន ហើយនៅក្នុងទង់បដិវត្តអ៊ីជាដើមមានលើកឡើងពីហ្នឹងពីគោលការណ៍សីលធម៌នោះ ថា អត្ថបទហ្នឹងមិនមានតម្លៃទេ ប៉ុន្មានទេ ប៉ុន្តែអត្ថបទហ្នឹងត្រូវបានប្រើនៅទីនេះ ហើយរំឭកទៅដល់កម្មាភិបាល ហើយនិងសាក្សីមួយចំនួនផងដែរ ថាការព្រមព្រៀងគ្នានេះ ត្រូវបានលើកឡើងជាញឹកញាប់នៅក្នុងក្របខ័ណ្ឌនៃដែលមកផ្តល់សក្ខីកម្មទាក់ទងនឹងការរៀបការ ហើយនិងដែលគេធ្វើការប្តេជ្ញាទាំងគ្នា។ នៅក្នុងពិធីការរួម ហើយគេសុំឲ្យអ្នករៀបការហ្នឹងឲ្យស្រឡាញ់គ្នាប្តេជ្ញាស្រឡាញ់គ្នា ហើយនិងប្តេជ្ញាចំពោះមុខសហករណ៍ហ្នឹង។ នេះគឺជាបទបញ្ជាស្តីពីការរៀបការ។ ហើយទាក់ទងទៅ

នឹងថា តើពួកគាត់ស្គាល់គ្នាជាមុន ដែរឬអត់នោះគឺ មានបទពិសោធន៍ផ្សេងៗពីគ្នា មេធាវីការពារក្តីមិនដែលបាននិយាយថា -- យើងមិនដែលនិយាយ តើយើងដឹងថា តើវាជាគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលបង្ខំឱ្យមនុស្សរៀបការហ្នឹងដែរឬអត់? មនុស្សពេញចិត្តការ មិនពេញចិត្តការនោះ យើងមិនដែលបានលើកឡើងពីរឿងហ្នឹងទេ ប៉ុន្តែឥឡូវហ្នឹងទាក់ទងទៅនឹងសាក្សីផ្សេងៗដែលបានមកផ្តល់សក្ខីកម្មនៅទីនេះៗ ខ្ញុំមិនអាចបង្ហាញសក្ខីកម្មទាំងអស់ហ្នឹងភ្លាមៗនោះទេ ក៏ប៉ុន្តែខ្ញុំអាចយោងទៅនឹងសារណារបស់យើង កថាខណ្ឌ៥៩២ ដែលនិយាយពីការរៀបការនោះ ពន្យល់ថាតាមករណីមួយៗនោះគឺថា មានអ្នកដែល -- មានភស្តុតាងដែលបង្ហាញថាការរៀបការជាមួយគ្នាហ្នឹង ហើយចុះអ្នកដែលមានអាយុស្របាលៗគ្នា ហើយសាក្សីមួយចំនួនបានប្រាប់ថាមានមួយក្រុមជាស្ត្រី មួយក្រុមជាបុរសអ៊ីចឹងទៅ ហើយគេឱ្យជួបគ្នាណែនាំគ្នាខ្លួនឱ្យស្គាល់ទៅ ហើយដើម្បីរៀបការជាមួយគ្នា ហើយមាន -- គេមានបទពិសោធន៍ដោយឡែកៗពីគ្នា។ ហើយបើតាមបទពិសោធន៍ទាំងអស់ហ្នឹងគឺថាមានភាពសំខាន់មួយគឺថា ដោយសារមានភាពខុសគ្នាទៅតាមកន្លែងទៅតាមបុគ្គល សាមីជនហើយនិងក្របខ័ណ្ឌហ្នឹងគឺវាផ្ទុះបញ្ជាំងឱ្យឃើញថាពុំមានការ -- គោលនយោបាយបង្ខំឱ្យរៀបការនោះទេ គ្រាន់តែមានបទបញ្ជាពីរបៀបរៀបចំគ្រួសារតែប៉ុណ្ណោះ។

[១៦:០២:៣៦]

ចំណុចសំខាន់មួយទៀតនៅក្នុងសារណាបណ្តឹងឧទ្ធរណ៍របស់យើងហ្នឹង យើងបានលើកឡើងនូវកថាខណ្ឌ១២១០ ដែលនិយាយអំពីភស្តុតាងនៅក្នុងសំណុំរឿងហ្នឹង យើងបានធ្វើជាស្ថិតិហ្នឹង យើងឃើញថា ពេលដែលយើងនិយាយអំពីភស្តុតាងទាក់ទងនឹងការរៀបការដោយបង្ខំនោះ យើងឃើញថាមានដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងសាក្សីនិយាយពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់គាត់ហ្នឹងគឺថា គាត់ត្រូវបានគេបង្ខំឱ្យរៀបការ ហើយចួនកាលហ្នឹងគឺបើមានប្រើអំពើហិង្សាទៀតផង។ ដូចអម្បាញ់មិញហ្នឹង ហើយដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងព្រះរាជអាជ្ញាបាននិយាយដែរ ពីបទពិសោធន៍គឺប្រើអំពើហិង្សាហ្នឹង មុំ វឿន គាត់ -- លោកស្រីហ្នឹងនិយាយថា ពន្យល់ថាគាត់ត្រូវបានរំលោភសេពសន្ថវៈ ដោយកម្មាភិបាល ដោយសារតែគាត់ជំទាស់មិនព្រមរៀបការនេះគឺជាភស្តុតាង ជាឧទាហរណ៍ភស្តុតាងមួយថា កម្មាភិបាលនេះរំលោភទៅនឹងបទបញ្ជានៃការរៀបការ ពីព្រោះថាតាមបទបញ្ជានេះគឺថាត្រូវឱ្យមានការព្រមព្រៀងគ្នាពីសាមីជន។

[១៦:០៤:០០]

ហើយនៅក្នុងដីកាដំណោះស្រាយក៏មានលើកឡើងពីចំណុចហ្នឹងដែរ។ ខ្ញុំសូមរំឭកផងដែរថា យើងបានបញ្ជាក់ថា នៅពេលដែលយើងនិយាយអំពីបទបញ្ជានៃការរៀបការនេះគឺថា មានការតាមដាន ហើយការតាមដានអ្នកដែលទើបនឹងរៀបការនេះ មិនមែនជាបញ្ជារបស់បក្សកុម្មុយនីស្តកម្ពុជាទេ មិនមែនអ្នកដឹកនាំទេ គឺថា ឧទាហរណ៍ដូចជាសាក្សី ឌុច ហ្នឹងគាត់ពន្យល់ គាត់ថាអ្នកកម្មាភិបាល ដូច ប៉ង់ អ៊ីចឹងគាត់ត្រូវបានគេចាប់ហ្នឹងគឺគាត់ហ្នឹងពីមុនមក ប៉ង់ ហ្នឹងគាត់បានទៅតាមដានគ្រួសារមួយហ្នឹង អ៊ីចឹងទៅក៏គេចាប់ ដោយសារមូលហេតុហ្នឹង។ ហ្នឹងគ្រាន់តែជាឧទាហរណ៍ដើម្បីឱ្យលោកស្រី អស់លោក លោកស្រី ចៅក្រមនោះយល់ថាវាមានភាពខុសគ្នា បទពិសោធន៍ខុសៗគ្នា ហើយអាការដែលសាលាដំបូងសន្និដ្ឋានថាមានគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍នេះគឺមិនត្រឹមត្រូវទេ ដោយសារបទពិសោធន៍ខុសៗគ្នាទាំងអស់។

**ប្រធានអង្គជំនុំ៖**

បាទ អ៊ីចឹងបើគ្មានចម្លើយ ហើយមិនមានសំណួរបន្តទៅទៀតទេ ខ្ញុំសូមជម្រាបថា យើងបញ្ចប់សវនាការនៅថ្ងៃនេះត្រឹមពេលនេះ ហើយនិងបន្តនាថ្ងៃស្អែកនៅវេលាម៉ោងប្រាំបួនព្រឹក។ ដូច្នេះ គឺសូមឱ្យខាងអនុរក្សពន្ធនាគារហ្នឹងនាំជនជាប់ចោទហ្នឹងទៅពន្ធនាគារវិញ ហើយស្អែកនៅម៉ោងប្រាំបីសែសិបប្រាំនាទី ត្រូវនាំជនជាប់ចោទ -- ខាងៗសហព្រះរាជអាជ្ញាមានយោបល់យ៉ាងម៉េច?

**លោកស្រី វូថ ម៉ារី ហេគ័រ៖**

សូមអរគុណឯកឧត្តមប្រធាន។ យើងចង់បន្ថែមបន្តិច គឺថាមិនមានលក្ខខណ្ឌតម្រូវដែលថាបទពិសោធន៍ជនរងគ្រោះត្រូវតែដូចតែគ្នាបេះបិទនោះទេ សាលាដំបូងបានសម្រេចរួចទៅហើយទៅលើធាតុផ្សំនេះ គឺថាធាតុផ្សំនៃឧក្រិដ្ឋកម្មហ្នឹង វានៅតែជាឧក្រិដ្ឋកម្ម -- នៅធាតុផ្សំបទល្មើសដដែល។ ហើយបន្ថែមពីលើនេះទៀត ដូចដែលយើងដឹងអ៊ីចឹងគឺថា ការឃោសនារបស់ខ្មែរក្រហម គឺគេនិយាយរឿងមួយផ្សេងគឺថា ជាគោលការណ៍អ៊ីចឹងទៅ គឺថាមិនត្រូវជំនុំជម្រះដោយគ្មានច្បាប់តុលាការអីទេ ប៉ុន្តែការអនុវត្តជាក់ស្តែងគឺវាខុសទាំងស្រុងតែម្តង គឺថាអ្វីដែលបង្ហាញនៅលើក្រដាសហ្នឹងគឺវាអត់ដូចទៅលើការអនុវត្តជាក់ស្តែងទេ។ អានេះខ្ញុំចង់បន្ថែមប៉ុណ្ណោះ ឯកឧត្តមប្រធាន លោក លោកស្រី ចៅក្រម សូមអរគុណ។

[១៦:០៧:៣៤]

**លោក ពេជ អង្គ៖**

សូមគោរព សូមអនុញ្ញាតឯកឧត្តមប្រធាន ខ្ញុំចង់គ្រាន់តែចង់សុំបញ្ជាក់បន្តិចពាក់ព័ន្ធទៅនឹងអ្វី

ដែលមេធាវីការពារក្តីលោកស្រី អង់តា ហ្គីសសេ លើកពាក់ព័ន្ធទៅនឹងដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន។ ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន នេះមិនត្រូវបានរំលោភដោយមនុស្សម្នាក់ទេ គឺគាត់បានលើកថា គាត់ត្រូវបានរំលោភដោយឈ្លបប្រាំនាក់ ហើយការរំលោភនេះ គឺដោយសារតែគាត់បដិសេធនៅក្នុងការទទួលរៀបការ វាជាទណ្ឌកម្ម ដែលគេធ្វើតាមវិធីផ្សេងៗ។ ហើយនៅក្នុងករណីនេះគឺឈ្លបទាំងអស់នោះ ដែលតម្រូវឱ្យពួកគេរៀបការបានធ្វើទណ្ឌកម្មទៅលើគាត់តាមរយៈការរំលោភគ្នាប្រាំនាក់ ហើយបន្ទាប់មកបីថ្ងៃក្រោយមក គាត់គ្មានអ្វីក្រៅពីឯកភាពនៅក្នុងការទទួលរៀបការជាមួយអ្នកដែលគាត់មិនពេញចិត្តនោះទេ។ សូមអរគុណឯកឧត្តម។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងមានអីថែមមកទៀតទេ?

**លោក គង់ សំអុន៖**

សូមអនុញ្ញាតឯកឧត្តមប្រធាន។ ទី១ ខ្ញុំចង់កត់សម្គាល់បន្ថែមទៅលើអ្វីដែលសហភាតាយើងបានលើកកន្លងមកទៅលើបញ្ហារឿងរៀបការដោយបង្ខំនេះ ហើយដែលយើងកំពុងតែគិតថាវាជាផ្នែកមួយនៃបទល្មើសដែលយើងចាត់ទុកថានៅក្នុងអំពើអមនុស្សធម៌ផ្សេងៗ ឬដទៃទៀត។ ទាក់ទងទៅនឹងគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យទាក់ទងទៅនឹងការរំលោភផ្លូវភេទនេះ យើងឃើញថា ជាគោលការណ៍ទណ្ឌកម្មមួយយ៉ាងធំចំពោះអ្នកដែលល្មើសទៅនឹងបទបញ្ជាដែលអាចថាជាអ្នកទៅប្រព្រឹត្តអំពើរំលោភផ្លូវភេទអីជាដើមនេះ។ មិនមែនជាគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យហ្នឹង ទៅគាំទ្រឱ្យកម្មាភិបាលរបស់ខ្លួនទៅប្រព្រឹត្តអំពើរំលោភសេពសន្ថវៈនេះទេ អានេះជាគោលនយោបាយដែលយើងទទួលស្គាល់នៅក្នុងអង្គជំនុំជម្រះកន្លងមកហើយ តុលាការទទួលស្គាល់រួចហើយ។ ហើយទាក់ទងនឹងវិធានការក្នុងការរៀបអាពាហ៍ពិពាហ៍នេះ យើងឃើញថាចំណាត់ការវាអត់ដូចគ្នា ពីតំបន់មួយទៅតំបន់មួយ ពីគូមួយទៅគូមួយ គឺមានលក្ខណៈខុសគ្នាដូចការលើកឡើងរបស់សហភាតាយើងខាងដើម។ ក៏ប៉ុន្តែភាពខុសគ្នានេះវាមិនមែនជាគោលនយោបាយ ដែលថាខ្មែរក្រហមនិយាយអ្វីនៅក្នុងក្រដាសនោះផ្សេង អាសរសេរនោះផ្សេង ដល់តែធ្វើនោះធ្វើផ្សេងមួយទៀត។ វាមិនទូទៅទាំងអស់អ៊ីចឹងទេ។ ក៏ប៉ុន្តែនៅក្នុងសង្គមណាក៏ដូចសង្គមណាដែរ គឺមានដូចគ្នាអ៊ីចឹង នៅពេលក្រដាសសរសេរក្នុងច្បាប់សរសេរផ្សេងទៅ ការអនុវត្តនោះផ្សេងទៅ គឺវាមាន។ នេះដោយសារអី ដោយសារតែប្រព័ន្ធអប់រំ ដោយសារប្រព័ន្ធផ្សព្វផ្សាយអីទាំងអស់ហ្នឹងដែលធ្វើឱ្យមានការលំបាក។ បើសិនជាយើងប្រៀបធៀបពីអ្វីដែលកើត

ឡើងកាលពី៤០ឆ្នាំជាងមុន ហើយនិងពេលបច្ចុប្បន្នគឺថាគឺយើងឃើញថាវានៅតែខុសគ្នាអ៊ីចឹង។ ពីមុន ការផ្សព្វផ្សាយ ការផ្ដល់នូវព័ត៌មានពីមួយទៅមួយហ្នឹងគឺមានការលំបាកណាស់ ពីព្រោះយើងគ្មានប្រព័ន្ធទូរស័ព្ទ គ្មានអីគ្រប់គ្រាន់ផង។ ឥឡូវប្រព័ន្ធតេឡេក្រាមអីគ្រប់បែបយ៉ាង នៅតែមានការលំបាក។ អ៊ីចឹង ការដែលអនុវត្តខុសគ្នាក្នុងសម័យ៤០ឆ្នាំជាងមុននោះ មិនអាចជាមូលដ្ឋានថាការធ្វើខុសហ្នឹងធ្វើផ្សេង និយាយផ្សេង។ នោះមិនអាចជាមូលដ្ឋានធំទេ។ សំខាន់គឺយើងផ្ដោតទៅលើនយោបាយ ជាគោលការណ៍។ បើគោលការណ៍មិនឱ្យធ្វើអាក្រក់ មិនឱ្យធ្វើអ្វីដែលជាបទល្មើស ហើយមានអំពើហ្នឹង បានន័យថាវាមិនមែនជានយោបាយទេ។ នោះគឺជាបុគ្គលៗដែលគាត់យកគោលនយោបាយ ឬក៏បកស្រាយគោលនយោបាយ ឬក៏ធ្វើស្អីមួយដែលមិនស្របនឹងនយោបាយ។ អ៊ីចឹងជាការទទួលខុសត្រូវរបស់បុគ្គលផ្សេងទៀតនៅក្នុងចំណោមកម្មាភិបាលដែលទទួលខុសត្រូវ ដូចលោកស្រីមេធាវី អង់តា លើកអំពីករណី ប៉ង់ ដែល ឌុច បានរាយការណ៍ជូនអង្គសវនាការហ្នឹង បាទ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អ៊ីចឹងយើងបញ្ចប់សវនាការនៅពេលនេះ។ អ៊ីចឹងដូចខ្ញុំបានជម្រាបជូន ស្អែកហ្នឹងគឺយើងបន្តនៅម៉ោងប្រាំបួនព្រឹក ហើយសូមឱ្យមន្ត្រីពន្ធនាគារហ្នឹងនាំជនជាប់ចោទទៅពន្ធនាគារវិញ ហើយព្រឹកស្អែកនៅម៉ោងប្រាំបី និងសែសិបប្រាំនាទី សូមនាំជនជាប់ចោទមកសាលសវនាការនៅទីកន្លែងដែលរបស់ជនជាប់ចោទវិញ។

ហើយដូច្នេះ គឺអង្គជំនុំជម្រះប្រកាសសម្រាក៕

*(សវនាការផ្អាកនៅម៉ោង ១៦:១៣នាទី)*